ព្រះរាជាណាចក្រកម្ពុជា

ជាត សាសនា ព្រះមហាក្សត្រ

វទ្យាស្ថានជាតអប់រំ

# និក្ខេបបទ

# ការគ្រប់គ្រង និងដឹកនាំការអប់រំផ្នែកបច្ចេកទេស

# កម្រិតមធ្យមសិក្សាទុតយភូមិនៅកម្ពុជា

# ករណីសិក្សា៖ វទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ព្រះបាទសម្តេច

# ព្រះបរមនាថ នរោត្តមសីហមុនី ខេត្តកំពង់ឆ្នាំង

# The Management and Leadership of Technical Education

# at Upper Secondary School

# Case Study: Preah Bath Samdech Preah Borromneat Norodom Sihamoni General and Technical Education High School, Kampong Chhnang Province.

**ដោយ / By**

**ប៊ែល ប៊ុណ្ណារិទ្ធិ**

**BEL BUNNARITH**

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៥

ឯកទេស គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៦☞២០១៨

ឧបត្ថមដោយ៖ មូនិធិគាំទ្រការអប់រំអន្តរជាតនៅកម្ពុជា

**Supported By: Cambodia International Education Support Foundation (CIESF)**

# គណៈកម្មការវាយតម្លៃ

# នៃការការពារនិក្ខេបបទសម្រាប់កម្មវិធីសិក្សា

# ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ

## និក្ខេបបទ

## ការគ្រប់គ្រង និងដឹកនាំការអប់រំផ្នែកបច្ចេកទេស

## កម្រិតមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា

## ករណីសិក្សា៖ ខេត្តកំពង់ឆ្នាំង

**និក្ខេបបទនេះត្រូវបានឯកភាពដោយ**

(១)- សាស្ត្រាចារ្យណែនាំ ៖

**លោកស្រីបណ្ឌិត ឃួន វច្ឆិកា**

(២)- តំណាងវិទ្យាស្ថានជាតិអប់រំ ៖

**លោកអនុបណ្ឌិត សៀង វាសនា**

(៣)- តំណាងគណៈកម្មការវាយតម្លៃ ៖

**ឯកឧត្តមបណ្ឌិត ជ័យ សារិន**

# និក្ខេបបទ

## ការគ្រប់គ្រង និងដឹកនាំការអប់រំផ្នែកបច្ចេកទេស

## កម្រិតមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា

## ករណីសិក្សា៖ វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស

## ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី ខេត្តកំពង់ឆ្នាំង

**The Management and Leadership of Technical Education**

**at Upper Secondary School**

Case Study: Preah Bath Samdech Preah Borromneat Norodom Sihamoni General and Technical Education High School, Kampong Tralach District, Kampong Chhnang Province.


**ដោយ / BY**

**ប៊ែល ប៊ុណ្ណារិទ្ធិ**

**BEL BUNNARITH**


**ឆ្នាំសិក្សា ២០១៦ ☞ ២០១៨**


**សាស្ត្រាចារ្យណែនាំ** **បណ្ឌិត ឃួន វឌ្ឍិកា**

**សាស្ត្រាចារ្យជំនួយ** **អនុបណ្ឌិត សៀង វាសនា**

**វិទ្យាស្ថានជាតិអប់រំ ភ្នំពេញ កម្ពុជា**

**National Institute of Education (NIE)**

**Phnom Penh – Cambodia**

# សេចក្តីប្រកាស

ខ្ញុំបាទសូមអះអាង និងបញ្ជាក់ជូនថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា“ **ការគ្រប់គ្រង និងដឹកនាំការអប់រំផ្នែកបច្ចេកទេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅកម្ពុជាករណីសិក្សា ខេត្តកំពង់ឆ្នាំង** ” សម្រាប់បំពេញលក្ខខណ្ឌដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ (NIE) គឺជាស្នាដៃពិតរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់មាននរណាម្នាក់បានសិក្សាស្រាវជ្រាវ និងប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសម្រាប់ទទួលសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅវិទ្យាស្ថានជាតិអប់រំនេះ ឬនៅសាកលវិទ្យាល័យណាមួយ ឬវិទ្យាស្ថានថ្នាក់ស្មើ ឬខ្ពស់ជាងណាមួយឡើយ។ ខ្ញុំបាទសូមបញ្ជាក់ជូនផងដែរថា ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារត្រង់ណានីមួយ ឬការចុះបញ្ជីឯកសារយោងណាមួយដែលត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធឡើយ។

ខ្ញុំបាទសូមអះអាងថា និក្ខេបបទសិក្សាស្រាវជ្រាវខាងលើនេះ ពិតជាស្នាដៃរបស់ខ្ញុំបាទប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**ប៉ែល ប៊ុណ្ណារិទ្ធិ**

## សេចក្តីបញ្ជាក់ពីសាស្ត្រាចារ្យដឹកនាំ

ក្នុងនាមខ្ញុំជាសាស្ត្រាចារ្យដឹកនាំការសរសេរនិក្ខេបបទស្រាវជ្រាវ សូមបញ្ជាក់ថាបេក្ខជនឈ្មោះ **ប៉ែល ប៊ុណ្ណារិទ្ធិ** ពិតជាបានសិក្សាស្រាវជ្រាវ និងតាក់តែងសរសេរនិក្ខេបបទនេះពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**ហត្ថលេខា**

**បណ្ឌិត ឃួន ចន្ថិភា**

# សេចក្តីថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទសូមអនុញ្ញាតគោរពថ្លែងអំណរគុណយ៉ាងអនេកចំពោះថ្នាក់ដឹកនាំប្រទេសគ្រប់លំដាប់ថ្នាក់ ដែលបានខិតខំកសាងសន្តិភាព និងការអភិវឌ្ឍប្រទេសនាពេលបច្ចុប្បន្ននេះ(ប្រទេសមានសន្តិភាព និងការអភិវឌ្ឍ ទើបការសិក្សាមានភាពសំបូរបែប បរិយាប័ន្ន និងការប្រគួតប្រជែង)។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងក្រៃលែងចំពោះក្រសួងអប់រំ យុវជន និងកីឡា និងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ នៃក្រសួងអប់រំ យុវជន និងកីឡា ដែលបានខិតខំយ៉ាងសស្រាក់សស្រាំក្នុងការកសាងវិស័យអប់រំ យុវជន និងកីឡា (ពោលគឺការកសាងធនធានពេញលេញជូនជាតិមាតុភូមិ)

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងក្រៃលែងដល់វិទ្យាស្ថានជាតិអប់រំ ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់នៃវិទ្យាស្ថានជាតិអប់រំ និងពិសេសអង្គការមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា (Cambodia International Education Support Foundation CIESF) ដែលបានរៀបចំកម្មវិធីអាហារូបករណ៍ និងជាឱកាសសម្រាប់ខ្ញុំបាទបានប្រលងជាប់ ហើយចូលសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ក្នុងឆ្នាំសិក្សា(២០១៦-២០១៨) នាពេលកន្លងទៅថ្មីៗនេះ។

ខ្ញុំបាទសូមគោរពថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ គណៈកម្មការគ្រប់គ្រង និងដឹកនាំការបណ្តុះបណ្តាលវគ្គសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំគ្រប់លំដាប់ថ្នាក់ ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រីជាសាស្ត្រាចារ្យទាំងអស់ ដែលបានចំណាយនូវពេលវេលាដ៏មានតម្លៃ ក្នុងការផ្ទេរចំណេះដឹង បំណិន និងឥរិយាបទ ព្រមទាំងគុណតម្លៃ និងបទពិសោធន៍ មេរៀនជីវិតល្អៗជាច្រើន ពិសេសលើផ្នែកគ្រប់គ្រង និងដឹកនាំ ការរៀបចំ ការធ្វើផែនការក្នុងវិស័យអប់រំ មកដល់ខ្ញុំបាទផ្ទាល់ និងមកដល់មិត្តរួមជំនាន់ដ៏ទៃទៀតដូចៗគ្នា និងស្មើៗគ្នា។ ជាពិសេសជាងនេះទៀត ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងអនេករកអ្វីមកប្រៀបផ្ទឹមពុំបាន គោរពជូនចំពោះលោកស្រីសាស្ត្រាចារ្យ**បណ្ឌិត ឃួន ទិច្ឆិកា** ជាសាស្ត្រាចារ្យណែនាំ និងលោកសាស្ត្រាចារ្យ **សៀង ទាសនា** ជាសាស្ត្រាចារ្យជំនួយ ដែលលោកទាំងទ្វេតែងតែចំណាយពេលដ៏មានតម្លៃ ការពន្យល់ណែនាំ ពីចំណុចគន្លឹះល្អៗ ពីដំណាក់កាលមួយទៅដំណាក់កាលមួយ និងគ្រប់ជំហានទាំងអស់ រហូតទើបធ្វើឲ្យការសិក្សាស្រាវជ្រាវរបស់ខ្ញុំបានសម្រេច និងបញ្ចប់យ៉ាងរលូន និងប្រកបដោយគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល សម្រាប់បម្រើឲ្យការអភិវឌ្ឍក្នុងវិស័យអប់រំកម្ពុជា។ មួយចំណែកទៀត ខ្ញុំបាទសូមថ្លែងអំណរគុណចំពោះ លោក លោកស្រីជាមិត្តរួមជំនាន់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំទាំងអស់ ខ្ញុំពិតជាមានមោទនភាពដែលមានលោក លោកស្រីជាមិត្ត ព្រោះលោកអ្នកទាំងអស់គ្នា ជាមនុស្សដែលមានសមានចិត្តល្អ ក្នុងការចែករំលែកនូវចំណេះដឹង បំណិន ឥរិយាបទ គុណតម្លៃ បទពិសោធន៍ និងមេរៀនជីវិតល្អៗសម្រាប់ខ្ញុំ។

ខ្ញុំបាទសូមថ្លែងអំណរគុណដល់ គណៈគ្រប់គ្រង លោក លោកស្រីជាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ បុគ្គលិកទីចាត់ការ ព្រមទាំងប្អូនៗសិស្សានុសិស្សនៃវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី ស្ថិតក្នុងភូមិសាលាលេខប្រាំ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដែលបានសហការ និងសម្របសម្រួលយ៉ាងល្អប្រសើរក្នុងដំណើរការចុះសិក្សាស្រាវជ្រាវ និងប្រមូលទិន្នន័យ ដែលជាកត្តារួមចំណែកមួយយ៉ាងធំក្នុងការធ្វើឲ្យការសិក្សាស្រាវជ្រាវរបស់ខ្ញុំទទួលបានលទ្ធផលជោគជ័យមួយរយភាគរយ។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះឧត្តមភរិយារបស់ខ្ញុំ គឺលោកស្រី **ណៃ ផល្លាឧត្តី** និងលោកឪពុក អ្នកម្តាយ បង្កើត ប្រសារ បងប្អូន មិត្តភក្តិទាំងអស់ដែលបានឧបត្ថម្ភគាំទ្រទាំងផ្នែកថវិកា ចិត្តគំនិត ប្រាជ្ញា និងផ្នែកស្មារតីដល់ខ្ញុំបាទក្នុងខណៈពេលសិក្សានាពេលកន្លងមក។

ខ្ញុំបាទសូមឧទ្ទិសនូវស្នាដៃស្រាវជ្រាវនេះ ជូនចំពោះដួងវិញ្ញាណក្ខន្ធបុព្វបុរសខ្មែរគ្រប់សម័យកាល ដែលបានពលីក្នុងការតស៊ូដើម្បីបុព្វហេតុជាតិមាតុភូមិ និងជូនចំពោះដួងវិញ្ញាណក្ខន្ធញាតិការប្រាំពីរសន្តានដែលបានបែកកាយរំលាយក្ខន្ធទៅកាន់បរលោកហើយ សូមលោកទាំងនោះទទួលនូវមហាកុសលពីខ្ញុំ និងបែរភ័ក្ត្រាងាកក្រោយឲ្យពរជ័យដល់ប្រទេសកម្ពុជាប្រកបដោយសន្តិភាព និងការអភិវឌ្ឍជានិច្ចនិរន្តរ៍តទៅ។

ជាទីបញ្ចប់ ខ្ញុំបាទបួងសួងដល់អស់វត្ថុស័ក្តិសិទ្ធិក្នុងលោក ពិសេសក្នុងព្រះរាជាណាចក្រកម្ពុជា សូមប្រសិទ្ធពរជ័យសិរីបវរមហាប្រសើរ ជូនចំពោះលោកអ្នកទាំងអស់គ្នា សូមមានសុខភាពល្អបរិបូរណ៍កម្លាំងកាយមាំមួន ប្រាជ្ញា ស្មារតីភ្លឺថ្លា សេចក្តីសុខ សេចក្តីចម្រើន រកទទួលទានមានបាន កើតកាលវាលគុម្ព ត្រជាក់ត្រជុំ សុខដុមរមនា និងម្រេចបានជោគជ័យគ្រប់កាតព្វកិច្ច ភារកិច្ចជានិច្ចនិរន្តរ៍ និងជួបប្រសព្វនូវពុទ្ធបួនប្រការគឺ អាយុ  វណ្ណៈ សុខៈ ពលៈ កុំបីក្លាយជាប្រការឯណាដ៏ទៃឡើយ។

**សូមអរគុណ!**

Table of Contents


សេចក្តីប្រកាស ............ i

សេចក្តីថ្លែងអំណរគុណ ............ ii

មាតិកា ............ vii

បញ្ជីតារាងអក្សរកាត់ ............ viii

មូលន័យសង្ខេប ............ ix

ជំពូកទី១

សេចក្តីផ្តើម

១.១- លំនាំបញ្ហានៃការស្រាវជ្រាវ ............ 1

១.២- ចំណោទបញ្ហា ............ 3

១.៣- គោលបំណងនៃការស្រាវជ្រាវ ............ 4

១.៤- សំណួរស្រាវជ្រាវ ............ 4

១.៥- ដែនកំណត់ និងវិសាលភាព ............ 5

១.៦- សារសំខាន់នៃការសិក្សាស្រាវជ្រាវ ............ 5

១.៧- គម្រោងនៃការសិក្សាស្រាវជ្រាវ ............ 6

១.៨- វេចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ ............ 6

ជំពូកទី២

រំលឹកទ្រឹស្តី

២.១- អត្ថន័យនៃពាក្យគន្លឹះ ............ 8

២.២- ការគ្រប់គ្រង ដឹកនាំ និងការអភិវឌ្ឍ ............ 11

*២.២.១- ការគ្រប់គ្រង* ............ 12

*២.២.២- ការគ្រប់គ្រងអប់រំ* ........ 12
*២.២.៣- ការដឹកនាំ* ........ 13
*២.២.៤- ភាពដូចគ្នា និងភាពខុសគ្នា រវាងអ្នកគ្រប់គ្រង និងអ្នកដឹកនាំ* ........ 15
*២.២.៥- ការអភិវឌ្ឍ* ........ 17
**២.៣- ទស្សនាទាន នៃការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ** ........ 21
*២.៣.១- សាវតានៃការអប់រំបច្ចេកទេស និងវិជ្ជាជីវៈកម្រិតមធ្យមសិក្សា* ........ 21
*២.៣.២- ស្ថានភាពទូទៅនៃវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ព្រះបាទសម្តេចព្រះបរមនាថ នរោត្តមសីហមុនី ខេត្តកំពង់ឆ្នាំង* ........ 22
*២.៣.៣- សារៈសំខាន់នៃការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ* ........ 23
*២.៣.៤- ចក្ខុវិស័យនៃគ្រប់គ្រង និងដឹកនាំការអភិវឌ្ឍលើការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ* ........ 25
ផ្នែកទី១៖ ការគ្រប់គ្រង និងដឹកនាំការអភិវឌ្ឍការអប់រំបច្ចេកទេស និងវិជ្ជាជីវៈរបស់ប្រទេសជប៉ុន ........ 25
*២.៣.៥- ទិសដៅនៃការអភិវឌ្ឍការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ* ........ 30
**២.៤- យុទ្ធសាស្រ្តអភិវឌ្ឍវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស** ..**Error! Bookmark not defined.**
*២.៤.១- យុទ្ធសាស្រ្តអភិវឌ្ឍរបស់* ........ **Error! Bookmark not defined.**
*២.៤.២- យុទ្ធសាស្រ្តអភិវឌ្ឍប្រទេសសិង្ហបូរី* ........ **Error! Bookmark not defined.**
*២.៤.៣- យុទ្ធសាស្រ្តអភិវឌ្ឍប្រទេសកម្ពុជា* ........ **Error! Bookmark not defined.**
**២.៥- សេចក្តីសង្ខេបការរំលឹកទ្រឹស្តី** ........ **Error! Bookmark not defined.**

**ជំពូកទី៣**

**វិធីសាស្រ្តស្រាវជ្រាវ**

**៣.១- គម្រោងវិភាគ** ........ 32

**៣.២- ការជ្រើសរើសសំណាក** 33

**៣.៣- វិធីសាស្ត្រប្រមូលទិន្នន័យ** 33

*៣.៣.១- ទិន្នន័យបន្ទាប់បន្សំ* 34

*៣.៣.២- ទិន្នន័យចម្បង* 34

**៣.៤- ឧបករណ៍ប្រមូលទិន្នន័យ** 34

**៣.៥- ឧបករណ៍ស្ថិតិ** 35

**៣.៦- ដំណើរការក្នុងការប្រមូលទិន្នន័យ** 35

**៣.៧- វិធីសាស្ត្រវិភាគទិន្នន័យ** 36

## ជំពូកទី៤

## លទ្ធផល និងការពិភាក្សាបកស្រាយ

**៤.១- វិភាគព័ត៌មានទូទៅ** 37

*៤.១.១- ភេទ និងមុខរបរ* 37

*៤.១.២- ស្ថានភាពគ្រួសារ* 38

*៤.១.៣- ប្រាក់ចំណូល* 38

*៤.១.៤- ការអប់រំ* 39

**៤.២- វិភាគលើការគ្រប់គ្រង និងដឹកនាំរបស់នាយកសាលា តាមក្របខណ្ឌសមត្ថភាពគោលនាយកសាលាអាស៊ីអាគ្នេយ៍** 41

*៤.២.១- គំនិតជាយុទ្ធសាស្ត្រ និងនវានុវត្តន៍* 41

*៤.២.២- ភាពជាអ្នកដឹកនាំ និងគ្រប់គ្រង* 42

*៤.២.៣- ភាពជាអ្នកដឹកនាំការបង្រៀន និងរៀន* 43

*៤.២.៤- ឧត្តមភាពបុគ្គល* 44

*៤.២.៥- ការចូលរួមពីភាគីពាក់ព័ន្ធ* 45

**៤.៣- វិភាគជារួមលើសមត្ថភាពគោលទាំង៥របស់នាយកវិទ្យាល័យ** .. 46

**៤.៤- វិភាគលើភាពពេញចិត្តរបស់ទាក់ទងទៅនឹងការបណ្តុះបណ្តាលរបស់សិស្ស នៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី** ...... 48

*៤.៣.១- QII.4 - 9* ...... 48

*៤.៤.១- QII.10 - 15* ...... 50

*៤.៤.១- QII.16 - 21* ...... 51

**៤.៤- វិភាគលើភាពពេញចិត្តរបស់សិស្សទាក់ទងទៅនឹងសាលារៀន នៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី** ...... 52

*៤.៤.១- QIII.23.1 – 23.6* ...... 53

*៤.៤.១- QIII.23.7 – 23.12* ...... 54

**ជំពូកទី៥**

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍**

**៥.១- សេចក្តីសន្និដ្ឋាន** ...... 55

**៥.២- អនុសាន៍ និងសំណូមពរ** ...... 57

**ឧបសម្ព័ន្ធ** ...... 52

# មាតិកា

ទំព័រ

ឯកសារវាយតម្លៃនិក្ខេបបទរបស់គណៈកម្មការ i

សេចក្តីប្រកាសរបស់បេក្ខជន ii

សេចក្តីថ្លែងអំណរគុណ iii

មាតិកា iv
បញ្ជីរូបភាព និងតារាង ឬសេចក្តីបញ្ជាក់ v
បញ្ជីតារាងអក្សរកាត់ vi
មូលន័យសង្ខេប vii
Abstract viii

# បញ្ជីតារាងអក្សរកាត់

**MoEYS** **Ministry of Education Youth and Sport**
ក្រសួងអប់រំ យុវជន និងកីឡា

**VOD** **Vocational Orientation Department**
នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ

**TVET** **Technical Vocational Education Training**
អប់រំបច្ចេកទេស និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**SWOT** **Strengths Weakness Opportunity Threats**
ចំណុចខ្លាំង ចំណុចខ្សោយ ឱកាស ហានិភ័យ

# មូលន័យសង្ខេប

ការកសាង និងការអភិវឌ្ឍធនធានមនុស្សពេញលេញ ឬហៅថាធនធានផលិត ប្រកបដោយគុណភាព ប្រសិទ្ធភាព និងប្រសិទ្ធផល ជាបញ្ហាសំខាន់របស់រាជរដ្ឋាភិបាលកម្ពុជាកំពុងបានគិតគូរ និងរៀបចំ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារក្នុងប្រទេស តំបន់ និងពិភពលោក ពិសេសតម្រូវការនាយុគ្គសម័យបដិវត្តន៍ឧស្សាហកម្ម **4.0** របស់ពិភពលោកនៃការីកចម្រើនបច្ចេកវិទ្យា។ ហេតុនេះហើយទើបក្រសួងអប់រំ យុវជន និងកីឡា បានខិតខំធ្វើការកែលម្អគុណភាពវិស័យអប់រំឡើងវិញ ដោយផ្តោតលើការពង្រឹងគុណភាព សមត្ថភាព ជំនាញទន់ និងជំនាញរឹង ពិសេសការគ្រប់គ្រង និងដឹកនាំ និងភាពអាចឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃទីផ្សារការងារសម្រាប់ប្រជាជនកម្ពុជា។ ដើម្បីសម្រេចគោលបំណងនេះ ក្រសួងអប់រំ យុវជន និងកីឡាសហការជាមួយដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ បានរៀបចំឲ្យមានការផ្តល់សេវាអប់រំចំណេះទូទៅនិងបច្ចេកទេសកម្រិតមធ្យមសិក្សាទុតិយភូមិដល់សិស្សានុសិស្សទាំងពីរភេទដែលបានបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ នៅតាមបណ្តាខេត្តមួយចំនួន និងបន្តឱ្យគ្រប់ខេត្តក្រុងក្នុងប្រទេសកម្ពុជានាពេលអនាគត។

ការសិក្សាស្រាវជ្រាវនេះស្វែងរកពីស្ថានភាព និងរបៀបនៃការគ្រប់គ្រង និងដឹកនាំការអប់រំផ្នែកបច្ចេកទេសកម្រិតមធ្យមសិក្សាទុតិយភូមិ នៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ព្រះបាទសម្តេចព្រះបរមនាថ នរោត្តមសីហមុនី ខេត្តកំពង់ឆ្នាំង ចំពោះការវាយតម្លៃរបស់គ្រូបង្រៀនស្របតាមក្របខណ្ឌនៃសមត្ថភាពគោលរបស់នាយកសាលាអាស៊ីអាគ្នេយ៍ កម្រិតនៃការពេញចិត្តរបស់សិស្សលើការរៀន និងបង្រៀន និងស្ថានភាពទូទៅនៃការគ្រប់គ្រង និងដឹកនាំរបស់នាយកវិទ្យាល័យ។ ការសិក្សានេះកំណត់សំណាក នាយកសាលារៀនចំនួន១នាក់ នាយករង នាយិការងចំនួន០៣នាក់ គ្រូបង្រៀនផ្នែកអប់រំបច្ចេកទេសចំនួន១៧នាក់ គ្រូបង្រៀនលើមុខវិទ្យាចំណេះទូទៅផ្នែកអប់រំបច្ចេកទេសចំនួន១០នាក់ និងសិស្សានុសិស្សផ្នែកអប់រំបច្ចេកទេសលើជំនាញក្សេត្រសាស្ត្រ និងអគ្គិសនី សម្រាប់ឆ្នាំទី១ ឆ្នាំទី២ និងឆ្នាំទី៣ សរុបចំនួន៧២នាក់។ ឧបករណ៍ស្រាវជ្រាវតាមបែបបរិមាណវិស័យត្រូវបានបង្កើតឡើងតាមលំនាំសូចនាករនៃក្របខណ្ឌស្តង់ដាសមត្ថភាពគោលរបស់នាយកអាស៊ីអាគ្នេយ៍( **SEAMEO INNOTECH, 2016** )។ រីឯបែបគុណវិស័យ គឺប្រើប្រាស់កម្រងសំណួរបន្ថែមសួរទៅលើកម្រិតនៃការយល់ឃើញទៅលើទិដ្ឋភាពទូទៅនៃការដឹកនាំ និងគ្រប់គ្រង និងភាពពេញចិត្តលើស្ថានភាពទូទៅនៃការរៀន និងបង្រៀនផ្នែកបច្ចេកទេសនៅវិទ្យាល័យ។ ការវិភាគទិន្នន័យបង្ហាញពី តម្លៃមធ្យម ( **Mean** ) គម្លាតស្តង់ដា ( **SD** )។ ព្រមទាំងបញ្ជាក់បន្ថែមតាមរយៈព័ត៌មានដែលបានមកពីទិន្នន័យគុណវិស័យ។ ការសិក្សានេះបានរកឃើញថា នាយកសាលាបានគ្រប់គ្រង និងដឹកនាំការអប់រំបច្ចេកទេសកម្រិតមធ្យម

សិក្សាទុតិយភូមិបានល្អក្នុងកម្រិតខ្ពស់ បើយោងទៅលើលទ្ធផលនៃការវិភាគតាមបែប **Discreptive Statistices Analysis** លើសមត្ថភាពគោលទី១ ( **គំនិតជាយុទ្ធសាស្ត្រ និងនវានុវត្តន៍** ) មានតម្លៃមធ្យមសរុប **M = 3.81** សមត្ថភាពគោលទី២ ( **ភាពជាអ្នកដឹកនាំ និងគ្រប់គ្រង** ) មានតម្លៃមធ្យមសរុប **M = 3.83** សមត្ថភាពគោលទី៣ ( **ភាពជាអ្នកដឹកនាំការបង្រៀន និងរៀន**) មានតម្លៃមធ្យមសរុប **M = 4.03** សមត្ថភាពគោលទី៤ (**ឧត្តមភាពបុគ្គលរបស់នាយកសាលា**) មានតម្លៃមធ្យមសរុប **M =4.02** និងសមត្ថភាពគោលទី៥ (**ការចូលរួមពីភាគីពាក់ព័ន្ធ**) មានតម្លៃមធ្យមសរុប **M = 3.92** និងតម្លៃមធ្យមសរុបលើសមត្ថភាពគោលតាមក្របខណ្ឌស្តង់ដានាយកអាស៊ីអាគ្នេយ៍ **M = 3.90** ។ ក្នុងនោះផងដែរក៏បានរកឃើញថា ភាពពេញចិត្តទៅលើចំណេះដឹងទូទៅរបស់សិស្ស **M = 1.75** និងបំណិនទន់ **M = 2.14** ដែលសិស្សទទួលបាននៅមានកម្រិតទាបខ្លាំង បើធៀបទៅនឹងចំណេះដឹងលើមុខវិជ្ជាផ្នែកបច្ចេកទេស។ ការរៀបចំប្រព័ន្ធប្រកាសអាសន្ន និងការពារសុវត្ថិភាព **M = 3.13** ការៀបចំនិងប្រើប្រាស់ប្រអប់សង្គ្រោះបឋម និងថ្នាំ **M = 3.13** ស្ថិតនៅក្នុងកម្រិតមធ្យម។

ឆ្លងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវអាចសន្និដ្ឋានបានថា ការគ្រប់គ្រង និដឹកនាំការអប់រំបច្ចេកទេសរបស់នាយកវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ព្រះបានទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី ខេត្តកំពង់ឆ្នាំងទទួលបានលទ្ធផលល្អ ទន្ទឹមនឹងនោះផងដែរ ក៏មានចំណុចខ្វះខាតមួយចំនួនត្រូវកែលម្អទៅលើលទ្ធផលសិក្សារបស់សិស្សផ្នែកចំណេះដឹងទូទៅ បំណិនទន់ ការរៀបចំប្រព័ន្ធប្រកាសអាសន្ន និងការពារសុវត្ថិភាព និងការៀបចំ និងប្រើប្រាស់ប្រអប់សង្គ្រោះបឋម និងថ្នាំព្យាបាល ដើម្បីឱ្យកាន់តែមានការអភិវឌ្ឍប្រកបដោយចីរភាព។

# ជំពូកទី១

# សេចក្តីផ្តើម

# ជំពូកទី១

# សេចក្តីផ្តើម

## ១.១- លំនាំបញ្ហានៃការស្រាវជ្រាវ

ការអប់រំ គឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំនៃការកសាងធនធានមនុស្សក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ប្រកបដោយនិរន្តរភាព។ ការអប់រំ គឺអាចផ្លាស់ប្តូរគ្រប់យ៉ាង ទាំងអត្តចរិត គំនិត ជីវភាពបុគ្គល គ្រួសារ និងសង្គមជាតិ ។ ការអប់រំ គឺធ្វើឱ្យមនុស្សរកឃើញវិធីការងាយ និងប្រសិទ្ធភាពខ្ពស់ក្នុងការដឹកនាំមនុស្សទៅរកការប្រែប្រួលកាន់តែល្អប្រសើរ ។ ការផ្តល់សេវាអប់រំ ត្រូវធានាដល់គុណភាពនៃចំណេះដឹង បំណិន ឥរិយាបថ និងគុណតម្លៃដល់អ្នកសិក្សាគ្រប់រូប (គោលដៅអប់រំជាតិ របស់ក្រសួងអប់រំ យុវជន និងកីឡា)។ បច្ចុប្បន្នការអប់រំនៅព្រះរាជាណាចក្រកម្ពុជាអនុវត្តប្រព័ន្ធអប់រំ ១២ឆ្នាំ គឺការអប់រំនៅកម្រិតបឋមសិក្សា ៦ឆ្នាំ (ថ្នាក់ទី១ដល់ទី៦) ការអប់រំនៅកម្រិតមធ្យមសិក្សាបឋមភូមិ ៣ឆ្នាំ (ថ្នាក់ទី៧ ដល់ទី៩) និងការអប់រំនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ៣ឆ្នាំ (ថ្នាក់ទី១០ ដល់ទី១២) (ប្រព័ន្ធអប់រំកម្ពុជាឆ្នាំ ១៩៩៦-បច្ចុប្បន្ន)។ ការអប់រំនៅកម្រិតមធ្យមសិក្សាទុតិយភូមិចែកចេញជាពីរផ្នែក គឺផ្នែកចំណេះទូទៅ និងផ្នែកអប់រំបច្ចេកទេស។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលមានក្រសួងអប់រំ យុវជន និងកីឡា ដែលជាសេនាធិការលើវិស័យអប់រំ បានដាក់ចេញនូវយុទ្ធសាស្ត្រដ៏ទូលំទូលាយ ដើម្បីបង្កើនសក្តានុពលធនធានមនុស្សឱ្យមានជំនាញបច្ចេកទេសគ្រប់កម្រិត ដែលអាចឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងតម្រូវការនៃទីផ្សារពលកម្មបានពេញលេញ មានគំនិតច្នៃប្រឌិតខ្ពស់ មានស្មារតីទទួលខុសត្រូវ សំដៅលើកកម្ពស់ការអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ។ ក្រសួងអប់រំ យុវជន និងកីឡា **(MoEYS)** បាននឹងកំពុងអនុវត្តការផ្តល់សេវាផ្នែកអប់រំបច្ចេកទេសនៅតាមវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ក្នុងគោលបំណងអភិវឌ្ឍសិស្សមធ្យមសិក្សាឱ្យមានសមត្ថភាពជំនាញបច្ចេកទេស មានគំនិតច្នៃប្រឌិតប្រកបដោយគុណធម៌ និងស្មារតីសហគ្រិនភាព ដើម្បីរួមចំណែកឆ្លើយតបនឹងតម្រូវការទីផ្សារការងារ និងមានសមត្ថភាពបន្តការសិក្សាពេញមួយជីវិត។ ក្រសួងអប់រំ យុវជន និងកីឡា បានកសាងស្តង់ដា និងសូចនាករគុណភាពវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ដើម្បីកំណត់លក្ខណៈវិនិច្ឆ័យដែលជាគំរូ ឬជាខ្នាតគំរូក្នុងការសន្មត ឬកំណត់ឱ្យបំពេញលក្ខខណ្ឌ មុននឹងចាប់ផ្តើមដំណើរការផ្តល់សេវាផ្នែកអប់រំបច្ចេកទេសដល់សិស្សានុសិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិ (ក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ស្តង់ដាវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ២០១៨)។

តាមរយៈការសិក្សាស្រាវជ្រាវពីបណ្តាប្រទេសជាមហាមិត្ត ប្រទេសជាដៃគូអភិវឌ្ឍ អង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ការដកស្រង់បទពិសោធន៍ អ្នកធ្វើគោលនយោបាយដឹកនាំប្រទេស ពោលគឺរាជរដ្ឋាភិបាលកម្ពុជា ថ្នាក់ដឹកនាំស្ថាប័នអប់រំ និងស្ថាប័នពាក់ព័ន្ធនានាបានសម្លឹង និងប្រមើលមើលឃើញពីលទ្ធភាពនៃការអភិវឌ្ឍប្រទេសឱ្យក្លាយជាអរិយប្រទេសបានដូចប្រទេសនៅលើពិភព

លោក (ប្រទេសសិង្ហ បុរី ប្រទេសជប៉ុន ប្រទេសចិន ប្រទេសកូរ៉េខាងត្បូង ប្រទេសអាមេរិក....) មានការអភិវឌ្ឍជឿនលឿនទៅបានគឺអាស្រ័យដោយប្រទេសទាំងនោះកសាង និងអភិវឌ្ឍប្រទេសដោយផ្តើមចេញពីការកសាងធនធានមនុស្ស ដោយផ្តោត និងយកចិត្តទុកដាក់លើការអប់រំចំណេះទូទៅ និងការអប់រំបច្ចេកទេស និងបណ្តុះបណ្តាលវិជ្ជាជីវៈដល់ប្រជាជនគ្រប់រូប ប្រកបដោយតម្លាភាព និងបរិយាប័ន្ន ម្យ៉ាងវិញទៀតបច្ចុប្បន្ននេះប្រទេសកម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍ មានកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំប្រមាណ៧% ឬលើសពីនេះ គឺស្ថិតក្នុងស្ថានភាពល្អ ហើយនឹងកំពុងបោះជំហានសន្សឹមៗទៅរកការក្លាយខ្លួនទៅជាសមាជិកនៃប្រទេសផលិត ឬហៅថាប្រទេសឧស្សាហកម្ម នៅឆ្នាំ២០២៥ ប្រទេសទទួលបានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍនាឆ្នាំ២០៥០ (គោលដៅអភិវឌ្ឍជាតិរបស់រាជរដ្ឋាភិបាល ) ដើម្បីឆ្លើយតបទៅនឹងសម័យសកលភាវូបនីយកម្មនៃវិស័យសេដ្ឋកិច្ច រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងអប់រំ យុវជន និងកីឡា បាននឹងកំពុងយកចិត្តទុកដាក់លើការអភិវឌ្ឍវិស័យអប់រំ ជាអាទិ៍ដោយបានដាក់ចេញនូវ គោលនយោបាយអប់រំជាតិចំនួនពីរគឺ៖ (១)-ធានាការអប់រំប្រកបដោយគុណភាព សមធម៌ បរិយាប័ន្ន និងឱកាសសិក្សាពេញមួយជីវិត និង(២)-ធានាភាពស័ក្តិសិទ្ធិ និងប្រសិទ្ធិភាព ប្រសិទ្ធផលនៃមន្ត្រីគ្រប់លំដាប់ថ្នាក់ (ក្រសួងអប់រំ យុវជន និងកីឡា របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០១៦ ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨ និងការធ្វើចំណោលដល់ឆ្នាំ២០២០) និងបានកំណត់នូវគោលដៅអប់រំជាតិ គឺការកសាងនូវធនធានមនុស្សពេញលេញ (ឯកសារយោង) កម្មវិធីកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ចំនួន១៥ចំណុច ព្រមទាំងកំណត់គោលការណ៍អប់រំសហស្សវត្សថ្មី ឈ្មោះថា " ចតុស្តម្ភ " វិស័យអប់រំ ដែលផ្អែកលើការរៀនបួនយ៉ាងគឺ (១)- រៀនដើម្បីចេះដឹង(learn to know)៖ រៀនចំណេះទូទៅ ទ្រឹស្តីវិទ្យាសាស្ត្របច្ចេកទេស អរិយធម៌ វប្បធម៌ ទស្សនវិជ្ជា និងចំណេះដឹង រៀនឱ្យចេះពីរបៀបរៀនបន្តពេញមួយជីវិត (២)- រៀនដើម្បីចេះធ្វើ (learn to do)៖ រៀនយកទ្រឹះស្តីមកអនុវត្តជាក់ស្តែងបណ្តុះសម្បទាប្រតិបត្តិជាគោល ឬជាក្រុមបំណិនជីវិតធម្មតា បំណិនជីវិតបុរេវិជ្ជាជីវៈ បំណិនជីវិតអាជីពដោយផ្សារភ្ជាប់ទៅនឹងការអនុវត្តការងារនៅក្នុងសង្គមតាមរយៈការកសាងសមត្ថភាពលើមូលដ្ឋានពិសេស និងការសាកល្បងជាមួយជីវភាពប្រចាំថ្ងៃជាក់ស្តែង (៣)-រៀនដើម្បីមានឥរិយាបថល្អក្នុងសង្គម (learn to be)៖ រៀនរៀបចំខ្លួនឱ្យចុះសម្រុងជាមួយសង្គម រៀនរស់ដោយប្រើបញ្ញា ស្មារតី និងបត់បែនទៅតាមកាលៈទេសៈ បត់បែនតាមសភាពការណ៍ និងនិន្នាការតំបន់ និងសាកលលោក រៀនរស់ដោយមានការទទួលខុសត្រូវ មានសោភ័ណភាពក្នុងគំនិតស័ក្តិសមជាមនុស្សថ្លៃថ្នូរ រៀនរស់ដោយស្វ័យម្ចាស់ការ និងស្វ័យអភិវឌ្ឍខ្លួន គ្រួសារ និងសង្គមជាតិជានិច្ច (៤)- រៀនរស់ជាមួយគ្នា( learn to live together)៖រៀនស្គាល់ប្រពៃណី វប្បធម៌ប្រវត្តិសាស្ត្រមនុស្សជាតិជុំវិញខ្លួន ពោលគឺសិក្សាពហុវប្បធម៌ រៀនអត់អោន យោគយល់ អធ្យាស្រ័យ ស្មារតីសាមគ្គីភាព ជួយគ្នា ស្រលាញ់គ្នា មិនប្រកាន់រើសអើងពូជសាសន៍ ពណ៌សម្បុរ ឋានៈវណ្ណៈ ពោលគឺសីលធម៌ពិភពលោក ដោះស្រាយបញ្ហាដោយសន្តិវិធី ធម៌អហិង្សា។ (របាយការណ៍របស់ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើជូនអង្គការយូណេស្កូ)។ ព្រមទាំងបង្កើតឱ្យមានវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស និងបានបើក និងដំណើរការបានចំនួន១៣ នៅទូទាំងប្រទេសក្នុងឆ្នាំសិក្សា

(២០១៧-២០១៨) នេះមានសិស្សចំនួន១៤៧២ នាក់ក្នុងនោះស្រី ចំនួន៥២៧នាក់ កំពុងសិក្សាថ្នាក់បច្ចេកទេស (របាយការណ៍សន្និបាទអប់រំឆ្នាំ២០១៨ របស់នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ(VOD))។ ពិភពលោកមានការប្រែប្រួលឥតឈប់ឈរពីមួយថ្ងៃទៅមួយថ្ងៃ ដើម្បីបំពេញតាមតម្រូវការរបស់មនុស្ស និងការរីកចម្រើននៃបច្ចេកវិទ្យា។ តាមការព្យាករណ៍ ឧស្សាហកម្ម៤.០នឹងស្រូបយកការងារចំនួន៥លានប្រភេទនៅឆ្នាំ២០២០។ ទោះបីយ៉ាងណាក៏ដោយ នេះមិនមែនជាបញ្ហាចោទនោះទេ។ ផ្នែកសំណង់ ផលិតកម្ម សេវាកម្ម សុខភាពសាធារណៈ និងអប់រំនឹងនៅតែដើរតួនាទីសំខាន់ ក្នុងការផ្តល់កំលាំងការងារ។ ដើម្បីឱ្យសិស្សទទួលជោគជ័យក្នុងទីផ្សារការងារ ពួកគេត្រូវមានជំនាញបច្ចេកទេសច្បាស់លាស់។ ដើម្បីអាចបំពេញតម្រូវការនេះបាន ក្រសួងអប់រំ យុវជន និងកីឡា ដែលមាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ជាសេនាធិការ បានរៀបចំស្តង់ដា ក្នុងនោះមានដាក់ចេញនូវសូចនាករស្តង់ដាវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស សម្រាប់កំណត់លក្ខណៈវិនិច្ឆ័យ និងការវាយតម្លៃដំណើរការរៀន និងបង្រៀននៃវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសទូទាំងប្រទេសឱ្យមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការផ្តល់សេវាអប់រំបច្ចេកទេសប្រកបដោយ គុណភាព ស្របតាមតម្រូវការឧស្សាហកម្ម៤.០។

ការសិក្សាស្រាវជ្រាវនេះផ្តលសារៈសំខាន់ជាព័ត៌មានមួយចំនួនសម្រាប់អ្នកកសាង និងរៀបចំគោលនយោបាយផ្នែកអប់រំបច្ចេកទេស បណ្តាគណៈគ្រប់គ្រងវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ក្រុមហ៊ុន សហគ្រាស រោងចក្រ ដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិនានា សហគមន៍ ឱ្យស្គាល់ពីតួនាទី និងភារកិច្ច នៃការងារអប់រំបច្ចេកទេសកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងការកសាងធនធានមនុស្សពេញលេញផ្នែកបច្ចេកទេស និងវិជ្ជាជីវៈសម្រាប់ចូលរួមមួយចំណែកក្នុងការកសាងខឿនសេដ្ឋកិច្ចប្រទេសជាតិ។ ព្រមទាំងចូលរួមមួយចំណែកក្នុងការឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍប្រទេសរបស់រាជរដ្ឋាភិបាលដែលបានកំណត់ថា កម្ពុជានឹងក្លាយជាប្រទេសឧស្សាហកម្ម ឬហៅថាប្រទេសផលិតនៅឆ្នាំ២០២៥ ប្រទេសទទួលបានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងក្លាយជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០។

## ១.២- ចំណោទបញ្ហា

ដើម្បីសម្រេចធ្វើឱ្យសម្រេចបាននូវគោលដៅ ក្លាយជាប្រទេសដែលទទួលបានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈក្រសួងអប់រំ យុវជន និងកីឡា បាននឹងកំពុងអនុវត្តកម្មវិធីកំណែទម្រង់វិស័យអប់រំជាបន្តបន្ទាប់ ការកំណត់ និងអនុវត្តគោលនយោបាយអប់រំជាតិ និងគោលដៅអប់រំជាតិ យ៉ាងច្បាស់លាស់ តាមរយៈស្វែងរកដៃគូអភិវឌ្ឍ ការធ្វើកិច្ចសហប្រតិបត្តិការនានា ជាមួយប្រទេសជាដៃគូដែលល្បីៗខាងផ្នែកការសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស ដូចជាប្រទេសចិន ប្រទេសសិង្ហបុរី ប្រទេសជប៉ុន ប្រទេសកូរ៉េ និងប្រទេសមួយចំនួនទៀតដើម្បីស្វែងរកការផ្សារភ្ជាប់ទំនាក់ទំនង និងចុះអនុស្សរណៈនៃយោគយល់គ្នា ( MoU ) និងតាមរយៈដៃគូអភិវឌ្ឍនៃប្រទេសមួយចំនួនទៀត។ ដោយប្រទេសកម្ពុជាយើងទើបនឹងចាប់ផ្តើមសម្លឹងមើលឃើញថាការអភិវឌ្ឍប្រទេសត្រូវផ្តើមចេញ និងបោះជំហានពីការកសាងធនធានមនុស្សផ្នែកផលិត ឬហៅថាធនធានមនុស្សផ្នែកបច្ចេកទេស ហេតុនេះហើយទើបប្រទេស

យើងមានភាពទន់ខ្សោយខ្លាំងផ្នែកការងារអប់រំបច្ចេកទេស និងបណ្តុះបណ្តាលវិជ្ជាជីវៈនេះ។ បច្ចុប្បន្នេះ ផងដែរការអប់រំផ្នែកបច្ចេកទេស និងបណ្តុះបណ្តាលវិជ្ជាជីវៈ ហាក់មានការបែកខ្ញែកគ្នាជាពីរផ្នែក ដោយមួយផ្នែកស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមួយផ្នែកទៀតគឺការងារអប់រំផ្នែកបច្ចេកទេសកម្រិតមធ្យមសិក្សាទុតិយភូមិ ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំពុងដំណើរការ និងបណ្តាសាលាខ្លះកំពុងជួបបញ្ហាប្រឈមមួយចំនួនលើការងារគ្រប់គ្រង និងដឹកនាំទូទៅ ការងារគ្រប់គ្រងសម្ភារៈ ការងាររៀននិងបង្រៀន សមត្ថភាពគ្រូបង្រៀន ការប្រើប្រាស់សម្ភារៈជាដើម។ អាស្រ័យហេតុនេះការបង្ហាញអំពីការសិក្សាស្រាវជ្រាវប្រធានបទ “ ការគ្រប់គ្រង និងដឹកនាំការអប់រំបច្ចេកទេសកម្រិតមធ្យមសិក្សានៅប្រទេសកម្ពុជា ” ករណីសិក្សាខេត្តកំពង់ឆ្នាំង សម្រាប់ជាផ្នែកមួយនៃមគ្គុទ្ទេសក្នុងការដឹកនាំ និងគ្រប់គ្រងនិងមើលឱ្យឃើញពីបញ្ហាប្រឈម សម្រាប់ចូលរួមជាទស្សនាទាន ឬជាកញ្ចក់ឆ្លុះបញ្ចាំងឱ្យឃើញកាន់តែច្បាស់ពីដំណើរឆ្ពោះទៅរកការអភិវឌ្ឍផ្នែកអប់រំបច្ចេកទេស ពិសេសជាការបង្ហាញត្រង់ទៅមន្ត្រីនៃក្រសួងអប់រំ យុវជន និងកីឡា ដែលបច្ចុប្បន្ននេះគឺស្ថិតនៅក្រោមការដឹកនាំរបស់នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ (VOD) ប្រយោជន៍សម្រាប់អ្នកធ្វើគោលនយោបាយ លោក លោកស្រីដែលជាគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូតាមបណ្តាវិទ្យាល័យចំណេះនិងបច្ចេកទេស និងអ្នកដែលពាក់ព័ន្ធទាំងឡាយនៅក្នុងផ្នែកការកសាងធនធានផ្នែកបច្ចេកទេសនេះផងដែរ និងចំពោះក្រុមអ្នកជំនួញដែលវិនិយោគផ្នែកការងារផ្នែកបច្ចេកទេសនេះផងដែរ និងសម្រាប់អ្នកសិក្សាស្រាវជ្រាវបន្តយកទៅប្រតិបត្តិ ឬលកលៃធ្វើនវានុវត្តន៍ដើម្បីឱ្យកាន់តែមានប្រសិទ្ធភាពស្របតាមសម័យកាលនីមួយៗ។

## ១.៣- គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងរកឱ្យឃើញពីរបៀបនៃការដឹកនាំ និងគ្រប់គ្រង និងការអភិវឌ្ឍរបស់វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី ដែលធ្វើឱ្យវិទ្យាល័យនេះចេះតែមានភាពរីកចម្រើន មានឈ្មោះល្បីល្បាញក្នុងប្រទេស និងមានដៃគូប្រទេសមួយចំនួនដូចជាប្រទេស ឆែក ប្រទេសកូរ៉េខាងត្បូងមកជួយអភិវឌ្ឍ និងចូលរួមកសាងធនធានមនុស្ស និងធ្វើឱ្យសិស្សដែលបានបញ្ចប់ការសិក្សានៅវិទ្យាល័យនេះមានសមត្ថភាពរកការងារបានធ្វើ និងបន្តការសិក្សានៅក្នុង និងក្រៅប្រទេស។ ការសិក្សាស្រាវជ្រាវនេះទៀតសោតក៏ធ្វើការសិក្សារកពីចំណុចខ្វះខាត បញ្ហាប្រឈម និងដំណោះស្រាយដែលបានជួបប្រទះ និងដោះស្រាយកន្លងមកផងដែរ។

## ១.៤- សំណួរស្រាវជ្រាវ

ដើម្បីគាំទ្រ និងសម្រេចបាននូវវត្ថុបំណងខាងលើអ្នកសិក្សាមានសំណួរស្រាវជ្រាវសំខាន់ៗដូចខាងក្រោម៖

(១).តើគណៈគ្រប់គ្រងវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី បានធ្វើការគ្រប់គ្រង ដឹកនាំ និងអភិវឌ្ឍបែបណាដែលធ្វើឱ្យវិទ្យាល័យចំណេះទូទៅនេះមានការរីកចម្រើន?

(២). តើវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនីបានជួបប្រទះនឹងបញ្ហាប្រឈមអ្វីខ្លះ ហើយមានដំណោះស្រាយបែបណាខ្លះចំពោះបញ្ហានីមួយៗដែលបានកើតឡើង?

## ១.៥- ដែនកំណត់ និងវិសាលភាព

ការសិក្សាស្រាវជ្រាវដំណើរការបានល្អ គឺវាអាស្រ័យដោយការកំណត់ពីដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ ហើយវិសាលភាពនៃការសិក្សាស្រាវជ្រាវបានផ្តោតទៅលើតែផ្នែកអប់រំបច្ចេកទេសកម្រិតមធ្យមសិក្សា។ ការសិក្សាស្រាវជ្រាវនេះបានជ្រើសរើសយកវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសចំនួន ០១ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡាគឺវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី ខេត្តកំពង់ឆ្នាំង។

ជ្រើសរើសគ្រូបង្រៀនផ្នែកបច្ចេកទេសទាំងអស់ឆ្នាំទី១ ឆ្នាំទី២ និងឆ្នាំទី៣ (មុខជំនាញចំនួនបីគឺ អគ្គិសនី គ្បេត្រសាស្ត្រ និងបសុវប្បកម្ម)សរុប១៧នាក់ និងជ្រើសរើសគ្រូបង្រៀនមុខវិជ្ជាចំណេះទូទៅផ្នែកជំនាញបច្ចេកទេសចំនួន ១០នាក់។

## ១.៦- សារសំខាន់នៃការសិក្សាស្រាវជ្រាវ

បើទោះបីជាការសិក្សាស្រាវជ្រាវនេះ មិនមបានគ្រប់ដណ្តប់ឱ្យបានគ្រប់ជ្រុងជ្រោយលើខ្លឹមសារនៃប្រធានបទ ការគ្រប់គ្រង និងដឹកនាំ ការអប់រំផ្នែកបច្ចេកទេសនៅកម្ពុជា ក៏លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ នឹងមានចំណុចល្អមួយផ្នែកមួយ ឬច្រើន ក្នុងការផ្តល់ព័ត៌មានសម្រាប់អ្នករៀបចំគោលនយោបាយ អ្នកផ្តល់សេវា និងអ្នកប្រើប្រាស់សេវា ការងារកសាងធនធានពេញលេញផ្នែកបច្ចេកទេស តួយ៉ាងមាន លោក លោកស្រី ជាគណៈគ្រប់គ្រងសាលារៀន ទាំងរដ្ឋ និងឯកជន ម្ចាស់ក្រុមហ៊ុន សហគ្រាស រោងចក្រ កសិដ្ឋានធន់តូច មធ្យម ម្ចាស់អាជីវកម្ម។ល។ ដើម្បីស្វែងយល់ពីតម្រូវការ នៃការអភិវឌ្ឍវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស របៀបរបបនៃការគ្រប់គ្រង និងដឹកនាំតាមបណ្តាវិទ្យាល័យ និងស្វែងយល់ពីតួនាទី ភារកិច្ច ការវាយតម្លៃ និងស្វ័យវាយតម្លៃគុណភាព ប្រសិទ្ធភាព និងប្រសិទ្ធផលនៃដំណើរការដើម្បីកាសាងធនធានមនុស្សឆ្លើយតបទៅនឹងតម្រូវការការងារទីផ្សារប្រទេស និងក្នុងតំបន់ និងកាន់តែធ្វើឱ្យមានការកាន់តែផុសផុលឡើងលើវិស័យកសាងធនធានមនុស្សផ្នែកផលិតនេះ។

ម្យ៉ាងវិញទៀតលទ្ធផលដែលទទួលបានពីការសិក្សានេះ ក៏មានសារប្រយោជន៍សម្រាប់អ្នកសិក្សាជំនាន់ក្រោយ ដើម្បីយកទៅសិក្សាស្រាវជ្រាវបន្ត ស្វែងរកនូវចំណុចដែលខ្វះខាត ចំណុចដែលមិនទាន់រកឃើញកដើម្បីបំពេញបន្ថែមក្នុងគោលបំណងគាំទ្រ និងលើកកម្ពស់ការកសាងធនធានមនុស្សនេះ។ រួមចំណែករកឱ្យឃើញនូវចំណុចល្អ បញ្ហាប្រឈម តាមបណ្តាសាលានីមួយៗ សម្រាប់ផ្សព្វផ្សាយបន្ត និងធ្វើការកែតម្រូវ ក្នុងន័យស្វែងរកឧត្តមភាពនៃការគ្រប់គ្រង និងដឹកនាំ សម្រាប់ការងារកសាងធនធានមនុស្សពេញលេញផ្នែកបច្ចេកទេស ដែលជាតម្រូវការចម្បងរបស់កម្ពុជាបច្ចុប្បន្ន ដើម្បីឆ្លើយតបជាមួយគោលដៅនៃប្រទេសកម្ពុជាក្លាយជាប្រទេសផលិតនៅឆ្នាំ២០២៥។

## ១.៧- គម្រោងនៃការសិក្សាស្រាវជ្រាវ

| សកម្មភាព | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា |
|---|---|---|---|---|---|---|---|
| ប្រមូលធាតុចូល និងសរសេរសេចក្តីផ្តើម | | | | | | | |
| សរសេររំលឹកទ្រឹស្តី និងរៀបចំកម្រងសំណួរ | | | | | | | |
| វិធីសាស្ត្រស្រាវជ្រាវ | | | | | | | |
| ចុះស្រាវជ្រាវផ្ទាល់ | | | | | | | |
| បង្ហាញលទ្ធផលស្រាវជ្រាវ | | | | | | | |
| បកស្រាយរបកគំហើញ | | | | | | | |
| សន្និដ្ឋាន អនុសាសន៍ និងសំណូមពរ | | | | | | | |

## ១.៨- រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះបានចែកចេញជា៦ជំពូកដូចមានខាងក្រោម៖

**ជំពូកទី១៖ សេចក្តីផ្តើមៈ** ក្នុងជំពូកនេះបានបង្ហាញអំពីលំនាំនៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ។

**ជំពូកទី២៖ រំលឹកទ្រឹស្តីៈ** ក្នុងជំពូកនេះបានលើកឡើងអំពីបណ្តាទ្រឹស្តីណាដែលដែលមានសង្គតិភាពនឹងប្រធានបទ ឬការសិក្សាស្រាវជ្រាវ ជាពិសេសនូវរាល់ចំណុចដែលបានលើកឡើងនៅក្នុងចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ។

**ជំពូកទី៣៖ វិធីសាស្ត្រនៃការស្រាវជ្រាវៈ** ក្នុងជំពូកនេះត្រូវ បង្ហាញពីគម្រោងវិភាគ និងវិធីសាស្ត្រស្រាវជ្រាវដែលបញ្ជាក់ ពីអត្ថប្រយោជន៍នៃប្រធានបទ និងបញ្ហាទំនាក់ទំនងរវាងចំណុចនីមួយៗដែលបានចោទក្នុងចំណោទបញ្ហាទៅជាមួយនឹងប្រធានបទ។

**ជំពូកទី៤៖ លទ្ធផល និងការពិភាក្សាលើលទ្ធផលនៃការសិក្សាស្រាវជ្រាវៈ** ក្នុងជំពូកនេះបានលើកឡើងអំពី (ស្ថានភាពជាក់ស្តែងនៃទីតាំងសិក្សាស្រាវជ្រាវ) ត្រូវលើកយកពីលក្ខណៈ ស្ថានភាពជាក់ស្តែង ដែលអ្នកសិក្សាស្រាវជ្រាវ ហើយចំណុចដែលត្រូវលើកឡើង គឺត្រូវឱ្យចូលទៅក្នុងចំណុចទាំងអស់ដែលបានចោទសួរនៅក្នុងចំណោទបញ្ហា។ វិភាគទៅលើចំណុចទាំងអស់ដែលបានអនុវត្តជាក់ស្តែងតើវាដូចគ្នាទៅនឹងទ្រឹស្តីដែរ ឬទេ? គឺថានៅក្នុងបំណងវិភាគរកឱ្យឃើញចំណុចខ្វះខាត ដើម្បីធ្វើការកែលម្អ (វិភាគកម្រងសំណួរ)។

**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ៈ** គឺធ្វើការសន្និដ្ឋានទៅលើគ្រប់ចំណុចទាំងអស់ដែលបានវិភាគ និងផ្តល់ជាអនុសាសន៍ទៅលើចំណុចដែលត្រូវកែលម្អ ឬចំណុចដែលបានការខ្វះខាត។

# ជំពូកទី២

# រំលឹកទ្រឹស្តី

# ជំពូកទី២
# រំលឹកទ្រឹស្តី

## ២.១- អត្ថន័យនៃពាក្យគន្លឹះ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងរកឱ្យឃើញពីរបៀបនៃការគ្រប់គ្រង និងដឹកនាំ និងការអភិវឌ្ឍការអប់រំផ្នែកបនច្ចេកទេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី ដែលនាំឱ្យមានការរីកចម្រើនដូចបច្ចុប្បន្ន។ ម្យ៉ាងវិញទៀតការសិក្សាស្រាវជ្រាវនេះក៏ធ្វើការអង្កេតពីបញ្ហាប្រឈម និងដំណោះស្រាយនានា ដែលបានជួប្រទះនាពេលកន្លងមក។ ដើម្បីសិក្សាស្រាវជ្រាវអំពីបញ្ហាខាងលើនេះ ថាតើវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី បានយកទ្រឹស្តីមួយណាមកជាគម្រូក្នុងការអនុវត្តទើបទទួលបានជោគជ័យបែបនេះនាពេលបច្ចុប្បន្ន និងមានទ្រឹស្តីណាផ្សេងទៀតដែលមានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយប្រធានបទនេះ។ ដើម្បីឱ្យកាន់តែមានភាពយល់ច្បាស់ និងមានភាពចូលឱ្យកាន់តែជ្រៅជាមមួយប្រធានបទ ជាអាទិ៍ត្រូវគម្បីយល់នូវពាក្យគន្លឹះមួយចំនួនដូចខាងក្រោម៖

***ការគ្រប់គ្រង៖ ការគ្រប់គ្រង*** មានទំនាក់ទំនងនឹងពាក្យ ***ភាពជាអ្នកដឹកនាំ*** ហើយពាក្យ ***អ្នកគ្រប់គ្រង*** ក៏ពុំមែនខុសគ្នាស្រឡះពីពាក្យ ***អ្នកដឹកនាំ*** នោះទេ។ តាមពិតវាហាក់ដូចជាកាក់មួយដែលមានមុខពីរដែរ។ ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ មានការបំពេញឱ្យគ្នាទៅវិញទៅមកដែរ ក្នុងស្ថានភាពដែលមានការប្រែប្រួលច្រើន។ មេដឹកនាំ អាចជាអ្នកគ្រប់គ្រងផង ពោលគឺមានមុខនាទីក្នុងអង្គភាព ឬក៏គ្មានតំណែង ឬគ្មានអំណាចផ្លូវការទេ។ ចំណែកឯអ្នកគ្រប់គ្រងវិញ ខ្លះក៏អាចបញ្ជាអ្នកក្រោមបង្គាប់ឱ្យបំពេញភារកិច្ចដោយសារអាជ្ញាដែលខ្លួនមាន ព្រោះខ្លួនមានមុខនាទី ឬតំណែងក្នុងអង្គភាព ហើយខ្លះទៀតថែមទាំងមានភាពជាអ្នកដឹកនាំ ដែលអាចឱ្យគាត់ដឹកនាំសម្រេចគោលដៅខ្ពស់ និងមានប្រសិទ្ធភាពលើអ្នកគ្រប់គ្រងដែលគ្មានលក្ខណសម្បត្តិភាពជាអ្នកដឹកនាំ។

ទស្សនៈរបស់ទស្សនវិទូដែលបនបកស្រាយទាក់ទងទៅនឹងសារៈសំខាន់ និងប្រសិទ្ធភាពនៃការគ្រប់គ្រង និងដឹកនាំសាលារៀន។ ទស្សនវិទូជាច្រើនបានលាតត្រដាង និងអះអាងនូវទស្សនៈរបស់ខ្លួនទាក់ទងទៅនឹងប្រសិទ្ធភាពនៃការគ្រប់គ្រង និងដឹកនាំអង្គភាព ឬស្ថាប័ន ឬគ្រឹះស្ថានសិក្សា។

***ការគ្រប់គ្រង*** គឺជាពណ៌នាទៅលើការដោះស្រាយភាពស្មុគ្រស្មាញ( **Kotter, 1990**)។

***ការគ្រប់គ្រង*** ជាដំណើរការដែលធ្វើឱ្យបុគ្គលម្នាក់ ឬច្រើននាក់ ក្នុងការសម្របសម្រួលសកម្មភាពចំពោះមនុស្សដទៃ ដើម្បីសម្រេចឱ្យបានលទ្ធផល តែមិនអាចសម្រេចដោយសកម្មភាពរបស់បុគ្គលម្នាក់បានទេ។ ឬជាដំណើរការដែលសម្រេចគោលដៅជាក់លាក់របស់អង្គភាពមួយ និងអ្នកដឹកនាំ ឬនាំកម្លាំងមនុស្សដទៃដើម្បីសម្រេចសកម្មភាពដែលចាំបាច់និងគោលដៅទាំងឡាយ។

**(http://srpchandeth.wordpress.com)**

***ការគ្រប់គ្រងអប់រំ*** គឺជាផ្នែកមួយនៃការអនុវត្តទាក់ទងទៅនឹងដំណើរការជាប្រព័ន្ធទៅនឹងដំណើរការការងារអប់រំ។ មុខងារនៃការគ្រប់គ្រងអប់រំ ដំណើរការនៃការធ្វើផែនការ ការរៀបចំចក្ខុវិស័យ បេសកកម្ម និងការកែលម្អឱ្យស្របទៅតាមស្ថានភាពនៃការអភិវឌ្ឍ ការដឹកនាំ គ្រប់គ្រង ចាត់ចែង និងអនុវត្តសកម្មភាពក្នុងគោលបំណងឱ្យមានការប្រែប្រួលពីអវិជ្ជមាន ឱ្យទៅជាវិជ្ជមាន និងប្រកបដោយចីរភាព បំរើឱ្យការរស់នៅប្រកបដោយសុខដុមរមនារបស់គ្រួសារ សង្គម និងមនុស្សជាតិ។ ដើមប្បីឱ្យជោគជ័យអ្នកគ្រប់គ្រងអប់រំជាចាំបាច់ត្រូវមានសមត្ថភាពខ្ពស់ក្នុងការប្រើប្រាស់ និងគ្រប់គ្រងធនធានមនុស្ស និងសម្ភារៈប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធ **( Khedekar, 2014 )**។ សមាសភាពដែលដើរតួរសំខាន់ ក្នុងសកម្មភាពគ្រប់គ្រងគ្រង និងដឹកនាំ គឺអ្នករៀបចំគោលនយោបាយអប់រំ មន្ត្រីគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់ រាប់តាំងពីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ លោកកគ្រូ អ្នកគ្រូ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ សហគមន៍ អាណាព្យាបាល ដៃគូអភិវឌ្ឍជាតិ អន្តរជាតិ បណ្តាក្រុមហ៊ុន រោងចក្រសហគ្រាស ហើយត្រូវមានការទទួលខុសត្រូវរួមក្នុងការផ្តល់សេវាអប់រំទាំងផ្នែកចំណេះទូទៅ និងទាំងផ្នែកបច្ចេកទេស។

***ការដឹកនាំ*** គឺជាការសម្របសម្រួលផ្លាស់ប្តូរ ការពុះពារគ្រប់ឧបសគ្គ និងធ្វើឱ្យអង្គភាពមួយមានការអភិវឌ្ឍ។

***អ្នកដឹកនាំ*** ជាមនុស្សដែលអាចធ្វើឱ្យអ្នកដទៃសម្រេចគោលដៅ ដោយអ្នកទាំងនោះមិនដឹងថាមានវត្តមានរបស់អ្នកដឹកនាំផង ( ***ឡាវស៊ុ*** )។

***អ្នកដឹកនាំ*** ជាមនុស្សម្នាក់ដែលមានសមត្ថភាព មានឥទ្ធិពល ឬអាចជំរុញឱ្យអ្នកដទៃអនុវត្តតាមខ្លួន(**លីន បូចីវែល**)។

លោក **Boon** និងលោក **Kurtz (1992)** លោកទាំងពីរបានឱ្យនិយមន័យនៃពាក្យ ***ការគ្រប់គ្រង*** ថាជាការប្រើប្រាស់ធនធានមនុស្ស និងធនធានផ្សេងៗ ដើម្បីសម្រេចនូវទិសដៅ ឬផែនការដែលបានគ្រោងទុក។ ហើយវាអាស្រ័យទៅនឹងការសិក្សាពីគ្រប់ស្ថានភាព ការរៀបចំផែនការ ហើយដំណើរការនៃការគ្រប់គ្រងមានសារៈសំខាន់ណាស់ក្នុងការជំរុញឱ្យមានការរីចម្រើន។ ការងារគ្រប់គ្រងវាមានការទាក់ទងយ៉ាងស្អិតរមួតទៅនឹងការបង្កើតមជ្ឈដ្ឋានការងារ ដែលធ្វើឱ្យមនុស្ស ឬបុគ្គលម្នាក់អាចប្រើប្រាស់ធនធានផ្សេងៗយ៉ាងស័ក្តិសិទ្ធ ក្នុងគោលបំណងដើម្បីសម្រេចគោលដៅដែលបានគ្រោងទុក និងតាមកាលកំណត់។ វាក៏ទាមទារឱ្យមានការចាត់តាំង និងការសម្របសម្រួល តែការចាត់តាំងត្រូវធ្វើទៅតាមជំនាញ និងឧបនិស្ស័យមនុស្ស ទើបអាចទទួលបាននូវលទ្ធផលល្អប្រសើរ។

***អភិវឌ្ឍ*** ជាពាក្យបាលី ថ្នាក់ពាក្យជាកិរិយាស័ព្ទ មានន័យថា ចម្រើនក្រៃលែង លូតលស់ចម្រើន។ អភិវឌ្ឍន ឬអភិវឌ្ឍន៍ ន.សេចក្តីចម្រើនក្រៃលែង។ អភិវឌ្ឍនភាព ភាពនៃសេចក្តីចម្រើន។ អភិវឌ្ឍនាការ អាការនៃអភិវឌ្ឍន៍។ល។ (វចនានុក្រម របស់សម្តេចព្រះសង្ឃរាជ **ជួន ណាត**)។ ការអភិវឌ្ឍកើតមានបានលុះត្រាណាក្នុងស្ថាប័នមួយ ឬអង្គភាពមួយមានអ្នកដឹកនាំប្រកបដោយសមត្ថភាព ភាពជាអ្នកដឹកនាំមនសិការក្នុងការងារអភិវឌ្ឍ មានជំនាញក្នុងការដឹកនាំគ្រប់គ្រង មានផែនការ និងចក្ខុវិស័យវែងឆ្ងាយ

បេសកកម្ម ព្រមទាំងដឹកនាំអនុលោមតាមស្តង់ដានាយកសាលារៀន ដែលក្រសួងបានរៀបចំ ឬតាមក្របខណ្ឌនៃសមត្ថភាពគោលនាយកអាស៊ីអាគ្នេយ៍ជាដើម។

***នាយកសាលារៀន៖*** សំដៅទៅលើអ្នកដឹកនាំ ឬអ្នកគ្រប់គ្រងសាលារៀន ដែលអាចមានឈ្មោះតួនាទីផ្សេងគ្នា អាស្រ័យទៅតាមបរិបទការងារ និងគោលនយោបាយដឹកនាំរបស់ក្រសួង និងរដ្ឋាភិបាល។

***ការដឹកនាំសាលារៀន៖*** ជាដំណើរការនៃការព្យាយាមរក និងនែនាំទេពកោសល្យ និងថាមពលរបស់គ្រូបង្រៀន សិស្សានុសិស្ស និងមាតាបិតាសិស្ស សំដៅសម្រេចនូវវត្ថុបំណងការអប់រំរួមស្របតាមគោលនយោបាយអប់រំជាតិ និងគោលនយោបាយប្រទេស សំដៅអភិវឌ្ឍធនធានមនុស្ស និងប្រទេសជាតិ។

***ផែនការអភិវឌ្ឍវិជ្ជាជីវៈ៖*** ផែនការដែលក្រសួង ឬស្ថាប័ន រៀបចំឱ្យមានសមត្ថភាពចំណេះដឹង បំណិន ឥរិយាបថ និងគុណតម្លៃ ដែលនាយកសាលារៀនត្រូវការ រួមមាន៖ កម្មវិធីបំប៉នផ្សេងៗ និងសកម្មភាពសិក្សា ហើយនាយកសាលាអាចចូលរួមក្នុងការបំពេញបន្ថែមលើសមត្ថភាពដែលខ្វះខាត។

***គំនិតជាយុទ្ធសាស្ត្រ និងនវានុវត្តន៍៖*** សមត្ថភាពនៃការរៀបចំទិសដៅជាយុទ្ធសាស្ត្រសម្រាប់សាលារៀន ការសម្រេចចិត្តនាំឱ្យមានការផ្លាស់ប្តូរ និងនវានុវត្តន៍

***ភាពជាអ្នកដឹកនាំ និងគ្រប់គ្រង៖*** សមត្ថភាពនៃការគ្រប់គ្រងធនធាន និងប្រព័ន្ធសាលារៀន ការគ្រប់គ្រងការបំពេញការងាររបស់បុគ្គលិក ការគ្រប់គ្រងការបំពេញកម្មវិធីរបស់បុគ្គលិក ការគ្រប់គ្រងកម្មវិធី និងគម្រោងនានារបស់សាលារៀន ប្រកបដោយនិរន្តរភាព។

***ភាពជាអ្នកដឹកនាំការបង្រៀន និងរៀន៖*** សមត្ថភាពនៃការដឹកនាំក្នុងការអនុវត្ត និងកែលម្អនូវកម្មវិធីសិក្សា បង្កើតកម្មវិធីសិក្សាតាមបែបសិស្សមជ្ឈមណ្ឌល អធិការ និងវាយតម្លៃលើការបំពេញភារកិច្ចរបស់គ្រូបង្រៀន ក៏ដូចជាផ្តល់ជាលទ្ធផលអំពីផែនការសិក្សា។

***ឧត្តមភាពផ្ទាល់ខ្លួន៖*** សមត្ថភាពនៃការគ្រប់គ្រងលើសមត្ថភាពបុគ្គលទៅលើសកម្មភាពឱ្យអស់ពីសមត្ថភាព និងលទ្ធភាពដែលអាចធ្វើទៅបាន និងបន្តអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈរបស់គណៈគ្រប់គ្រង លោក លោកស្រី។

***ការចូលរួមពីភាគីពាក់ព័ន្ធ៖*** សមត្ថភាពក្នុងការលើកកម្ពស់ ការចែករំលែក ការទទួលខុសត្រូវសម្រាប់ការអភិវឌ្ឍសាលារៀន គ្រប់គ្រងភាពជាដៃគូ និងបណ្តាញការអប់រំ និងរក្សានិរន្តរភាពនៃទំនាក់ទំនងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ របស់គណៈគ្រប់គ្រងសាលារបស់លោក លោកស្រី។

**( SEAMEO INNOTECH, 2016 )**

***ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា៖***

គឺសំដៅលើការអប់រំជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ដូចជាជំនាញអគ្គិសនី គ្បេត្រសាស្ត្រ បសុវប្បកម្ម អេឡិចត្រូនិច និងមេកានិចជាដើម។ល។ ជាការអប់រំដែលធ្វើឱ្យអ្នកសិក្សាទទួលបាននូវចំណេះដឹងជំនាញ បំណិន និងឥរិយាបថល្អក្នុងសង្គម ឬក្លាយជាអ្នកបច្ចេកទេសកម្រិតមធ្យម និងក្លាយជាពលករជំនាញ កម្មករជំនាញ និងមានសេចក្តីថ្លៃថ្នូរ អាចប្រកបគាំទ្រ និងផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃបាន ព្រមទាំងរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ការងារអប់រំបច្ចេកទេសនៅកម្រិតមធ្យមសិក្សា

ទុតិយភូមិ ត្រូវបានអនុវត្តចាប់តាំងពីឆ្នាំសិក្សា២០០២-២០០៣ ដោយចាប់ផ្ដើមដំបូងនៅវិទ្យាល័យកំពង់ឈើទាល ខេត្តកំពង់ធំ។ បន្ទាប់មកនៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន រ៉ូតា ខេត្តកណ្ដាល ក្នុងឆ្នាំសិក្សា ២០១២-២០១៣។ វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ព្រះបាទសម្ដេច ព្រះបរមនាថ នរោត្តមសីហមុនី ខេត្តកំពង់ឆ្នាំង ក្នុងឆ្នាំសិក្សា ២០១៣-២០១៤ និងមានជាបន្តបន្ទាប់ដូចជា វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ព្រះនរោត្តមសីហមុនី និងវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសព្រះរាជសម្ភារ ខេត្តកំពត។ ក្នុនោះដែរក៏មានវិទ្យាល័យឯកជនមួយចំនួនបានដាក់ពាក្យសុំចូលនៅក្រោមការដឹកនាំ និងគ្រប់គ្រងបច្ចេកទេស របស់ក្រសួងអប់រំយុវជន និងកីឡា មានដូចជាវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសឯកជន ដុនបូស្កូ ប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសឯកជនសន្តប្រ្យង់ស៊្វ័រ ខេត្តតាកែវជាដើម។ល។ ការបង្កើតវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសនេះដោយអនយលោមតាមច្បាប់អប់រំនៃព្រះរាជាណាចក្រកម្ពុជា វត្ថុបំណងនៃការអប់រំគឺផ្ដោតលើ ការកសាង និងអភិវឌ្ឍធនធានមនុស្សពេញលេញដោយផ្ដល់នូវការរៀនសូត្រពេញមួយជីវិត ដើម្បីទទួលបាននូវចំណេះដឹងទូទៅ ចំណេះជំនាញ សមត្ថភាព បំណិន សេចក្ដីថ្លៃថ្នូរ សីលធម៌ និងអត្តចរិកល្អ ក្នុគោលបំណងជុំរុញអ្នកសិក្សាឱ្យស្គាល់ ស្រលាញ់ ថែរក្សា និងការពារអត្តសញ្ញាណជាតិ វប្បធម៌ ប្រពៃណី ទំនៀមទំលាប់ និភាសាជាតិ និងធ្វើការផ្សព្វផ្សាយទៅសាកលលោក។

## ២.២- ការគ្រប់គ្រង ដឹកនាំ និងការអភិវឌ្ឍ

គោលបំណងរបស់រាជរដ្ឋាភិបាល គឺផ្ទុំយ៉ាងណាដើម្បីប្រែក្លាយកម្ពុជា ឱ្យក្លាយទៅជាប្រទេសដែលទទួលបានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលទទួលប្រាក់ចំណូលខ្ពស់ ឬហៅថាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០។ ដូច្នេះរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលដៅយុទ្ធសាស្រ្តចំនួនបួន គឺ (១)- ធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំជាមធ្យម៧% (២)- បង្កើតការងារបន្ថែមទៀតសម្រាប់ប្រជាពលរដ្ឋ ពិសេសយុវជន (៣)- សម្រេចឱ្យបានក្នុងការកាត់បន្ថយភាពក្រីក្រជារៀងរាល់ឆ្នាំជាង១% (៤)- ការពង្រឹងសមត្ថភាពស្ថាប័ន និងអភិបាលកិច្ចទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ផែនការយុទ្ធសាស្រ្តវិស័យអប់រំឆ្នាំ២០១៤-២០១៨ បានដាក់ចេញនូវគោលក្របខណ្ឌគោលនយោបាយសំខាន់ចំនួនបីគឺ គោលនយោបាយទី១៖ ធានាការទទួលនូវការទទួលសេវាអប់រំ ប្រកបដោយសមធម៌នៅគ្រប់កម្រិតសិក្សា គោលនយោបាយទី២៖ បង្កើនគុណភាព និងអ្វីដែលពាក់ព័ន្ធនឹងការរៀន និងគោលនយោបាយទី៣៖ ធានាយ៉ាងមានប្រសិទ្ធភាពនូវភាពជាអ្នកដឹកនាំ និងគ្រប់គ្រងដល់គ្រប់បុគ្គលិកអប់រំនៅគ្រប់កម្រិត ។

**នៅក្នុងគោលនយោបាយទី៣ ពិតជាមានសារសំខាន់ជាពិសេស ការងារគ្រប់គ្រង និងដឹកនាំ តាមស្ថាប័ននីមួយៗ ដែលជាសេនាធិការឱ្យក្រសួង ក៏ដូចជារាចរដ្ឋាភិបាល ក្នុងការងារកសាងប្រទេសជាតិ។ យ៉ាងណាមិញការគ្រប់គ្រងប្រកបដោយ គុណភាព ប្រសិទ្ធភាព និងប្រសិទ្ធផល ព្រមទាំងមានវិជ្ជាជីវៈខ្ពស់ និងគុណតម្លៃល្អបំផុត ( ផ្ដោតសំខាន់ទៅលើលទ្ធផល )។** ការត្រួតពិនិត្យបានយ៉ាងត្រឹមត្រូវ ការរាយការណ៍បានទាន់ពេលវេលាអំពីលទ្ធផល ជាមួយនឹងមតិត្រឡប់ គឺជាម៉ែត្រសម្រាប់វាស់ស្ទង់ប្រកបដោយ

គណនេយ្យភាព និងជាយន្តការមួយសម្រាប់កែសម្រួលគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ។ ការគ្រប់គ្រងស្ថាប័នអប់រំសាធារណៈ ទាំងផ្នែកចំណេះទូទៅ និងផ្នែកបច្ចេកទេស អាចឆ្លើយតបបានយ៉ាងមានប្រសិទ្ធភាព ទៅនឹងតម្រូវការនានានៅកម្រិតសាលារៀន។ ( Hanushek & Woessmann, 2008 ) បានសង្កេត សិក្សាឃើញថា ការសិក្សាពីផលប៉ះពាល់នៃការអប់រំ ដោយមើលតែលើកំណើនសេដ្ឋកិច្ច មិនបានមើលលើចំណេះជំនាញខុសគ្នា ផ្តល់ដោយសាលាដែលមានគុណភាពផ្សេងៗគ្នា វានឹងបង្ហាញឱ្យឃើញនូវភាពលម្អៀងខ្ពស់ក្នុងការប៉ាន់ប្រមាណលើផលប៉ះពាល់នៃការសិក្សា និងលទ្ធផលនៃការសិក្សា។

គុណភាពអប់រំ គឺផ្តើមចេញពីគុណភាពរបស់នាយកសាលា និងគ្រូបង្រៀន។ ក្នុងអត្ថន័យនេះ កំណែទម្រង់វិស័យអប់រំបច្ចុប្បន្ន គឺផ្តោតទៅលើការពង្រឹងការគ្រប់គ្រង និងដឹកនាំរបស់នាយកសាលារៀន គុណភាពគ្រូបង្រៀន និងការកែលម្អការរៀន និងបង្រៀន ដោយធ្វើសហវិមជ្ឈការឱ្យទៅសាលារៀននូវការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រង និងដឹកនាំសាលារៀន ( School Base Managment ) និងការទទួលខុសត្រូវទៅលើលទ្ធផលនៃការសិក្សារបស់សិស្ស។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការខាងលើក្នុងការអនុវត្តកំណែទម្រង់វិស័យអប់រំ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំស្តង់ដាវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ស្តង់ដានាយកវិទ្យាល័យ និងចូលរួមក្នុងការសហការអនុវត្តតាមក្របខណ្ឌសម្ថភាពគោលនាយកអាស៊ីអាគ្នេយ៍។

### *២.២.១- ការគ្រប់គ្រង*

នៅក្នុងប្រព័ន្ធអប់រំ បើនិយាយពីអ្នកគ្រប់គ្រង ឬការគ្រប់គ្រង អ្នកគ្រប់គ្រងត្រូវតែមានសមត្ថភាព និងចំណេះដឹងពាក់ព័ន្ធទៅនឹង រចនាសម្ព័ន្ធក្រសួងអប់រំ យុវជន និងកីឡា ការសរសេរ និងការប្រើប្រាស់លិខិតបទដ្ឋានគតិយុត្ត ទ្រឹស្តីនៃការគ្រប់គ្រងអប់រំ មុខងារ តួនាទី និងជំនាញនៃការគ្រប់គ្រងអប់រំ ភាពអ្នកដឹកនាំ ការរៀបចំផែនការអភិវឌ្ឍសាលារៀន ការធ្វើឱ្យសម្រេចបាននូវលទ្ធផលកាន់តែល្អប្រសើរនូវគុណភាពអប់រំ ឬការសម្រេចបាននូវវត្ថុបំណងនៃការអប់រំ និងអភិបាលកិច្ចល្អនៅក្នុងសាលារៀនជាដើម។

ការងារគ្រប់គ្រងអង្គភាព ឬស្ថាប័នមួយចាមួយដំណើការប្រើប្រាស់សមត្ថភាពចំណេះដឹង បំណិនឥរិយាបថ និងគុណតម្លៃ ដើម្បីដឹកនាំ គ្របើគ្រង និងតាមដាននូវដំណើការសកម្មភាព វឌ្ឍនភាពការងារដែលខ្លួនបានធ្វើ និងដើម្បីធ្វើឱ្យប្រាកដថា បុគ្គលិក និងប្រភពធនធានរបស់ខ្លួន ឬស្ថាប័នផ្សេងៗទៀតត្រូវបានប្រើប្រាស់បានចំគោលដៅ ត្រឹមត្រូវ ប្រកបដោយប្រសិទ្ធភាព ចំណាយតិច និងទទួលបានផលច្រើន ឆ្ពោះទៅរកការសម្រេចបាននូវគោលដៅរបស់អង្គភាព( ក្រសួងអប់រំ យុវជន និងកីឡា ២០០៩)។

### *២.២.២- ការគ្រប់គ្រងអប់រំ*

**មន្ត្រីគ្រប់គ្រងអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា** រួមមានមន្ត្រីជាន់ខ្ពស់ (រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង ឬអគ្គាធិការ អគ្គាធិការង ប្រធាន អនុប្រធាននាយកដ្ឋាន ប្រធាន អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក្រុង និងប្រធាន អនុប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុក ខណ្ឌ។ គុណសម្បត្តិអប់រំ ការបណ្តុះបណ្តាលបច្ចេកទេស និង

វិជ្ជាជីវៈ និងបទពិសោធន៍អនុវត្តរបស់គេ គឺជាគន្លឹះប្រកបដោយប្រសិទ្ធភាពចំពោះការគ្រប់គ្រងប្រព័ន្ធអប់រំនៅកម្ពុជា។

**ព័ត៌មាននៃការការគ្រប់គ្រង៖** ក្រសួងអប់រំ យុវជន និងកីឡា បានអភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ( **EMIS** ) ដោយបញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ ហើយបានរៀបចំ ប្រមូល កែច្នៃ វិភាគ និងប្រើប្រាស់ស្ថិតិ អាំងឌីកាទ័រ និងត្រូវបានបោះពុម្ព និងផ្សព្វផ្សាយជាប្រចាំឆ្នាំ។

**ផែនការអភិវឌ្ឍធនធានមនុស្ស៖** គឺជាវិធីដោះស្រាយតាមស្តង់ដាមួយ ដើម្បីវិភាគវិស័យអប់រំដោយធ្វើការវាយតម្លៃភារកិច្ច គោលដៅ និងវត្ថុបំណងនៃវិស័យអប់រំ មុខងារនាយកដ្ឋាន សកម្មភាពនានានៃផ្នែក និងការព័ណ៌នាមុខតំណែង។ ( **MoEYS,** នាយកដ្ឋានផែនការ ការពន្យល់ពីការផ្តើមផែនការកម្មសម្រាប់មន្ត្រីគ្រប់គ្រងអប់រំ, ១៩៩៨, ទំព័រ៤៧ **UNDP, UNESCO** )

### *២.២.៣- ការដឹកនាំ*

***ការដឹកនាំ*** គឺជាជំនាញក្នុងការប្រើប្រាស់ និងដឹកនាំមនុស្ស ឱ្យបំពេញការងារប្រកបដោយសមានចិត្ត ការទទួលខុសត្រូវខ្ពស់ និងឈានទៅរកការសម្រេចបាននូវគោលដៅដែលបានដៅ ឬគ្រោងទុក ( **Hunter, 1985** )។ ***ការដឹកនាំ*** ជាអំណាចពីធម្មជាតិ ឬជាអំណាចដែលទទួលបានតាមច្បាប់ជាតិដែលអ្នកដឹកនាំ ឬអ្នកគ្រប់គ្រង ប្រគល់ឱ្យអ្នកក្រោមបង្គាប់ ឬអ្នកដទៃបំពេញតាមគោលដៅ ឬផែនការ និងជាការគាំទ្រនូវសក្តានុពលរបស់មនុស្ស។ ការងារជាក្រុម ឬការងារអ្វីណានីមួយ ប្រសិនបើគ្មានអ្នកដឹកនាំ និងការសម្របសម្រួលទេនោះ ការងារពិតមិនអាចសម្រេចបានទាន់ពេលវេលាឡើយ។ គ្មានអ្នកដឹកនាំ គឺគ្មានទិសដៅច្បាស់ និងគ្មានកន្លែងបញ្ចប់ គ្មានផែនការ និងពេលវេលាច្បាស់លាស់ ហើយសកម្មភាពផ្សេងៗមិនអាចបន្សីគ្នាបានទេ។ ចំណែកឯលោក **Harry Truman (1997)** បានឱ្យនិយមន័យ***ភាពជាអ្នកដឹកនាំ*** គឺជាបុគ្គល ឬមនុស្សដែលមានសមត្ថភាពនាំមនុស្ស ឬក្រុមមនុស្សមួយក្រុម ឬច្រើនក្រុមឱ្យធ្វើអ្វីដែលពួកគេមិនចង់ធ្វើ ហើយថែមទាំងសប្បាយចិត្តក្នុងការធ្វើការ ឬបំពេញការងារនោះថែមទៀតផង។ លោក **Adolf Hitler (1925)** ការដឹកនាំគឺជាការបង្រួបបង្រួមស្មារតីមនុស្សម្នាក់ ឬច្រើននាក់ឱ្យរួបរួមគ្នាជាធ្លុងមួយ ដើម្បីបង្កើតកម្លាំងតបតនឹងសត្រូវ។

នៅក្នុងសាលារៀនមួយចាំបាច់ត្រូវមានអ្នកគ្រប់គ្រង ដឹកនាំ ជាសេនាធិការឱ្យក្រសួង ជាអ្នកអនុវត្តផ្ទាល់សំដៅសម្រេចបាននូវវត្ថុបំណងនៃការអប់រំ។ នាយកសាលារៀន ជាបុគ្គលគំរូ និងត្រូវឱ្យអ្នកក្រោមឱវាទរបស់ខ្លួនបានទទួលឥទ្ធិពល និងការអភិវឌ្ឍខ្លួនពីភាពជាអ្នកដឹកនាំរបស់ខ្លួន។

**លក្ខណសម្បត្តិភាពជាអ្នកដឹកនាំ៖** ក្នុងសង្គមនីមួយៗ មានការកំណត់លក្ខណសម្បត្តិរបស់អ្នកដឹកនាំរបស់ខ្លួនមិនខុសគ្នាប៉ុន្មាននោះទេ គឺអាស្រ័យទៅតាមបរិបទនីមួយៗនៃការអភិវឌ្ឍសង្គម វប្បធម៌ និងវិទ្យាសាស្ត្រ។

លក្ខណសម្បត្តិសម្រាប់ភាពជាអ្នកដឹកនាំជាអត្តចរិតដែលពិសេសប្លែកផ្សេងពីអ្នកដទៃ និងភាពថ្លៃថ្នូរដែលលើកតម្កើងអ្នកឱ្យមានលក្ខណៈគ្រប់គ្រាន់សម្រាប់ធ្វើការជាអ្នកដឹកនាំម្នាក់។ លក្ខណសម្បត្តិ

ទាំងនេះជាចរិតលក្ខណៈដែលអ្នកសំដៅយកយ៉ាងជាក់លាក់នៅក្នុងការអនុវត្តភាពជាអ្នកដឹកនាំ និងការទទួលខុសត្រូវក្នុងភាពជាអ្នកដឹកនាំ គ្រប់គ្រង។ សារៈសំខាន់នៃលក្ខណៈសម្បត្តិទាំងនេះ មិនអាចត្រូវបានពន្លើសបន្ថែមបានទេ កាលបើខកខានមិនបានបង្ហាញឱ្យច្បាស់នូវលក្ខណសម្បត្តិទាំងនេះ ចំពោះក្រុមការងារ នោះវាបណ្តាលឱ្យបាត់បង់នូវជំនឿជាក់ពីសមាជិកក្រុម ឬអ្នកក្រោមបង្គាប់បញ្ជា។ បុគ្គលជាអ្នកដឹកនាំដែលជោគជ័យត្រូវមានលក្ខណៈសម្បត្តិ១០យ៉ាង ដូចខាងក្រោម៖

(១)- គ្រប់គ្រងអារម្មណ៍

(២)- ការសម្របសម្រួលតាមស្ថានភាព

(៣)- គំនិតផ្តួចផ្តើម

(៤)- ភាពក្លាហាន

(៥)- ការប្តេជ្ញា ការតាំងចិត្ត និងដំណោះស្រាយ

(៦)- ចរិតមានលីលធម៌

(៧)- សុភវិនិច្ឆ័យ

(៨)- ភាពមានអំណត់អត់ធន

(៩)- ភាពអាចទុកចិត្តបាន

(១០)- មហិច្ឆតា

**( ស្នាដៃសហនិពន្ធរបស់ ណ័រម៉េន ឡ.ហ្វ្រីហ្គន សរ. ហេនរីយេ )**

### ***លក្ខណសម្បត្តិរបស់នាយក ឬនាយិកាវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស***

វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ត្រូវមានគណៈគ្រប់គ្រង ដើម្បីបំពេញការងារទៅតាមភារកិច្ច និងមុខតំណែងរៀងៗខ្លួន ដើម្បីឆ្ពោះទៅរកការសម្រេចឱ្យបាននូវវត្ថុបំណងអប់រំ។ គណៈគ្រប់គ្រងត្រូវមានលក្ខណសម្បត្តិ បុគ្គលិកលក្ខណៈ បទពិសោធន៍ និងគុណវុឌ្ឍិសមស្របនឹងការងារដែលខ្លួនទទួលខុសត្រូវ។ នាយក ឬនាយិកា ដែលដឹកនាំ និងគ្រប់គ្រងវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសកម្ពុជាត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

- មានកម្រិតគុណវុឌ្ឍិចាប់ពីកម្រិតបរិញ្ញាបត្រឡើងទៅ
- ជាគ្រូបង្រៀនកម្រិតឧត្តម
- មានបំណិនភាសាបរទេសកាន់តែប្រសើរ
- មានបំណិនខាងកុំព្យូទ័រការងាររដ្ឋបាល
- មានឆន្ទៈ មនសិការ ការទទួលខុសត្រូវខ្ពស់ក្នុងការងារ និងមនសិការក្នុងការងារដឹកនាំ និងគ្រប់គ្រង និងអភិវឌ្ឍសាលារៀន
- មានកាយសម្បទា ឥរិយាបថ និងសីលធម៌សមស្រប
- មានបទពិសោធពាក់ព័ន្ធនឹងការងារគ្រប់គ្រង និងដឹកនាំ

- មានសមត្ថភាពទំនាក់ទំនង ធ្វើការងារក្រុម ដោះស្រាយបញ្ហា មានគំនិតផ្តួចផ្តើម នងច្នៃប្រឌិត និងចក្ខុវិស័យវែងឆ្ងាយ។
  **( ស្តង់ដាវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស, ក្រសួងអប់រំ យុវជន និងកីឡា, នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ, ២០១៨ )**

### *២.២.៤- ភាពដូចគ្នា និងភាពខុសគ្នា រវាងអ្នកគ្រប់គ្រង និងអ្នកដឹកនាំ*

*ភាពដូចគ្នា និងភាពខុសគ្នា* ពាក្យ “ *ការគ្រប់គ្រង* ” និង “ *ភាពជាអ្នកដឹកនាំ* ”

អ្នកសិក្សាស្រាវជ្រាវជាច្រើនបានខិតខំរំលេច ពីភាពខុសគ្នាជាមូលដ្ឋានរវាងភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង។ **(Kotter, 1990)** ជាមនុស្សម្នាក់ដែលព័ណ៌នាការគ្រប់គ្រងទៅលើការដោះស្រាយភាពស្មុគ្រស្មាញ រីឯភាពជាអ្នកដឹកនាំវិញជាអ្នកដែលផ្តោតយកចិត្តទុកដាក់ទៅលើការផ្លាស់ប្តូរ។ អ្នកស្រាវជ្រាវដដែលកត់សម្គាល់ពីភាពចាំបាច់ក្នុងការបញ្ចូលគ្នា និងអាទិភាពនៃភាពជាអ្នកដឹកនាំនៅក្នុងបរិបទនៃទសវត្សន៍ថ្មីនេះដែលមានសភាពប្រែប្រួលច្រើនជាមួយនឹងការទទួលបាននូវភាពជោគជ័យ។

ចំណែកលោក **(Fairholm, 1991)** បានគូសបញ្ជាក់ពីភាពខុសគ្នារវាងភាពជាអ្នកដឹកនាំ នៅត្រង់គោលបំណង មូលដ្ឋានយល់ដឹង និងកម្រិតជំនាញ។ លោកបង្ហាញថាភាពខុសគ្នានៃអ្នកដឹកនាំ ផ្តោតទៅលើលក្ខណៈបុគ្គលនៅក្នុងបណ្តាសមាជិកក្រុមជាងអ្នកគ្រប់គ្រង។ អ្នកដឹកនាំផ្តោតទៅលើទិដ្ឋភាពសកលនៅក្នុងការគិត។ ជាបន្ថែមគឺចង់ឱ្យអ្នកដឹកនាំផ្តោតទៅលើតម្លៃ ការរំពឹងទុក និងបរិបទ។ ផ្ទុយទៅវិញ អ្នកគ្រប់គ្រងផ្តោតច្រើនលើការត្រួតត្រា និងលទ្ធផល។ អ្នកដឹកនាំជះឥទ្ធិពលលើអ្នកដើរតាម និងក្រុមសំខាន់ដទៃទៀតតាមរបៀបមួយដែលអនុញ្ញាតឱ្យអ្នកក្រោមឱវាទមានការបំពេញកិច្ចការបែបសេរីជាង និងពុំមែនតាមយន្ដការអាជ្ញានោះទេ។ អ្នកគ្រប់គ្រងវិញដាក់បញ្ជាច្បាស់លាស់ ដាក់ការងារឱ្យអ្នកដើរតាមធ្វើ និងមានការលំបាកក្នុងការធ្វើឱ្យមានការសហការគ្នា។ ឯអ្នកដឹកនាំផ្តល់តម្លៃលើកិច្ចសហការ ហើយមិនមែនត្រឹមតែការសម្របសម្រួលគ្នាប៉ុណ្ណោះទេ។ **(Ibid, p.39)**

### មុខនាទីគ្រប់គ្រងបំពេញដោយអ្នកដឹកនាំ

ដើម្បីដឹកនាំ ងួកដើរតាមឈានទៅរកសម្រេចគោលដៅរបស់អង្គភាពប្រកបដោយប្រសិទ្ធភាព អ្នកដឹកនាំចាំបាច់ត្រូវបំពេញមុខនាទីចាំបាច់មួយចំនួន។ លោក **Henry Mintzberg** បានចែកមុខនាទីនេះជាបីក្រុមគឺ **មុខនាទីអន្តរបុគ្គល មុខនាទីព័ត៌មាន និងមុខនាទីសម្រេចចិត្ត**។ មុខនាទីទាំងបីនេះមានទំនាក់ទំនងគ្នា។

**មុខនាទីអន្តរបុគ្គលរបស់អ្នកដឹកនាំមាន៖**

(១)- **មុខនាទីជាប្រមុខ៖** អ្នកដឹកនាំ បំពេញមុខនាទីជាប្រមុខនៅពេលគេធ្វើជាតំណាងឱ្យអង្គភាព ផ្នែក ឬនាយកដ្ឋានដែលខ្លួនទទួលខុសត្រូវ។ អ្នកដឹកនាំថ្នាក់ខ្ពស់ត្រូវបានគេម៉លឃើញថាបានបំពេញមុខនាទីនេះជាញឹកញាប់។ សកម្មភាពដែលពាក់ព័ន្ធទៅនឹងការបំពេញមុខនាទីប្រមុខមានដូចជាធ្វើជាប្រធានអង្គប្រជុំ ឬព្រឹត្តិការណ៍ផ្សេងៗដូចជាពីធីសម្ពោធ ពិធីប្រគល់រង្វាន់ និងចូលរួមប្រជុំជាមួយអង្គភាពដទៃជាដើម។ល។

**(២)- មុខនាទីដឹកនាំ៖** ទាក់ទងទៅនឹងការផ្តល់ការណែនាំ ប្រឹក្សាយោបល់ ការពិភាក្សា ការបណ្តុះបណ្តាល និងការធ្វើការវាយតម្លៃលទ្ធផលជាដើម។

**(៣)- មុខនាទីសម្ព័ន្ធការ៖** ការបំពេញមុខនាទីនេះកើតនៅពេលអ្នកដឹកនាំមានទំនាក់ទំនងជាមួយអ្នកដទៃ ដៃគូជាតិ អន្តរជាតិ ពិសេសនៅក្រៅអង្គភាព ផ្នែក ឬក្រុមរបស់ខ្លួនធ្វើការទាក់ទងដើម្បីបង្កើនទំនាក់ទំនង ទទួលបានព័ត៌មាន ឬការគាំទ្រជាដើម។ សកម្មភាពជាក់ស្តែងអាចចូលក្នុងគណៈកម្មាធិការ ជាមួយអ្នកផ្សេងៗទៀតមកពីអង្គភាពផ្សេង ចូលរួមអង្គប្រជុំនានា ឬការកោះប្រជុំអ្នកក្រោមឱវាទជាដើម។

***មុខនាទីព័ត៌មានរបស់អ្នកដឹកនាំមាន៖***

**(១)- មុខនាទីត្រួតពិនិត្យ** (Monitor Role) ៖

អ្នកដឹកនាំត្រូវធ្វើការត្រួតពិនិត្យ ដើម្បីឱ្យប្រាកដថា កិច្ចការរបស់អង្គភាពត្រូវបានបំពេញ និងសម្រេចបានកម្រិតណា។ វាពឹងផ្អែកជាមូលដ្ឋានលើការស្រាវជ្រាវព័ត៌មាន ធ្វើការវិភាគដើម្បីយល់ និងរកឃើញការខ្វះខាត។ ការប្រមូលព័ត៌មានធ្វើតាមរូបភាពសង្កេត អានរបាយការណ៍ ធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងបុគ្គលិក ប្រជុំ និងពិនិត្យមើលការតវ៉ា ឬត្អូញត្អែរពីមជ្ឈដ្ឋានដទៃជាដើម។ ម្យ៉ាងទៀតការស្រាវជ្រាវព័ត៌មានពុំធ្វើត្រឹមតែដើម្បីវិនិច្ឆ័យពីការងារខ្វះខាតរបស់អង្គភាពខ្លួនប៉ុណ្ណោះទេ គេត្រូវការព័ត៌មានផ្សេងៗ ដែលអាចឱ្យដឹងពីកាលានុវត្ត និងបញ្ហាកើតឡើងដោយបរិស្ថានខាងក្រៅទៀតផង។

**(២)- មុខនាទីផ្សព្វផ្សាយ** (Disseminator Role)៖

អ្នកដឹកនាំបំពេញមុខនាទីអ្នកចែកចាយ និងផ្សព្វផ្សាយព័ត៌មាននៅពេលដែលគេបញ្ជូនសារទៅអ្នកក្រោមបង្គាប់។ អ្នកដឹកនាំអាចមានព័ត៌មានដែលអ្នកដើរតាមត្រូវការ ដូចជាព័ត៌មានត្រឡប់ ចក្ខុវិស័យគោលនយោបាយថ្មី និងព័ត៌មានផ្សេងៗទៀត។ ការចែកចាយអាចធ្វើដោយផ្ទាល់ដូចជាការប្រជុំប្រាស្រ័យជាមួយបុគ្គល ការបិទផ្សាយព័ត៌មានតាមក្តារខៀនព័ត៌មាន និងតាមមធ្យោបាយសារអេឡិចត្រូនិចជាដើម។

**(៣)- មុខនាទីជាអ្នកនាំពាក្យ** (Spokeperson Role) ៖

អ្នកដឹកនាំបំពេញការងារនេះនៅពេលដែលគេបញ្ជូនព័ត៌មានទៅអ្នកដទៃ ដែលនៅក្រៅក្រុម ឬអង្គភាពខ្លួន។ អ្នកគ្រប់គ្រងត្រូវរាយការណ៍ទៅមេកើយ ដែលមានលំដាប់ខ្ពស់ជាងដូចជាប្រធានអង្គភាព ឬម្ចាស់អង្គភាព ក្រុមប្រឹក្សាភិបាល ឬទៅកាន់មនុស្សនៅក្រៅអង្គភាពខ្លួនដូចជាផ្នែកដទៃ អតិថិជន អ្នកផ្គត់ផ្គង់ និងសាធារណជនជាដើម។ លើប្រការនេះអ្នកដឹកនាំបំពេញមុខនាទីជាអ្នកតំណាងផ្នែកទំនាក់ទំនងសាធារណៈឱ្យអង្គភាព រស្ថាប័នរបស់ខ្លួនក្រោមរូបភាពជា ការជួបប្រាស្រ័យជាបុគ្គល ប្រជុំ និងធ្វើសន្និសិទ្ធសារព័ត៌មានជាដើម។

***មុខនាទីសម្រេចចិត្តរបស់អ្នកដឹកនាំមាន*** *(Decision Role)៖*

មុខនាទីនេះរាប់បញ្ចូលមុខនាទីជាសហគ្រិន ដោះស្រាយបញ្ហា និងជាអ្នកចរចារ

**(១)- មុខនាទីសហគ្រិន** (Entrepreneur Role) ៖

ក្នុងផ្នែកធុរកិច្ច អ្នកដឹកនាំបំពេញមុខនាទីសហគ្រិន នៅពេលដែលគេធ្វើឱ្យផលិតផលមានលក្ខណៈថ្មី ឬកែលម្អដំណើរការផលិត ប្រើបច្ចេកវិទ្យាថ្មី កែប្រែសកម្មភាពឱ្យកាន់តែប្រសើរឡើងរបស់អង្គភាព ហើយឱ្យមានការផ្សារភ្ជាប់ទៅនឹងការផ្លាស់ប្តូរ និងគំនិតច្នៃប្រឌិត។

(២)- **មុខនាទីដោះស្រាយបញ្ហា** (Disturbance- Handler Role) ៖

ក្នុងកាលៈទេសៈដែលមានបញ្ហាជម្លោះ អ្នកដឹកនាំបំពេញមុខនាទីជាអ្នកដោះស្រាយបញ្ហា។ ខុសគ្នាពីសកម្មភាពសហគ្រិន ដែលធ្វើតាមផែនការគិតទុកជាមុន ការដោះស្រាយបញ្ហាមានលក្ខណៈជាប្រតិកម្ម ទៅនឹងព្រឹត្តិការណ៍ ឬបញ្ហាដែលកើតឡើងដោយគ្មានការគ្រោងទុក ដូចជាកង្វះវត្ថុធាតុដើម សម្ភារបរិក្ខារ គ្រោះថ្នាក់ផ្សេងៗ បាតុកម្ម កូដកម្មពីសំណាក់បុគ្គលិក និងការបំពេញការងារជាបន្ទាន់ណាមួយ។ល។

(៣)- **មុខនាទីជាអ្នកចែកចាយធនធាន** (Resource – Allocator Role) ៖

អ្នកដឹកនាំបំពេញមុខនាទីជាអ្នកចែកចាយធនធាន នៅពេលដែលគេត្រូវ ដោះស្រាយ និងចែកចាយធនធាន សម្ភារបរិក្ខារ ការទទួលខុសត្រូវ និងថវិកាជាដើម។ ត្រូវគិតវិភាគមើលលើការដែលត្រូវតំលើងឋានៈ ឬប្រាក់កម្រៃ ឱ្យបុគ្គលិកណាម្នាក់ជាដើម។

(៤)- **មុខនាទីជាអ្នកចរចារ** (Negotiator Role) ៖

អ្នកដឹកនាំក្នុងនាមផ្នែក អង្គភាព ឬស្ថាប័នរបស់ខ្លួនធ្វើការចរចារជាមួយបុគ្គល ឬអង្គភាពដទៃក្នុងសមត្ថកិច្ចរបស់ខ្លួនដូចជាការបង់កម្រៃ និងអត្ថប្រយោជន៍ក្នុងការជួលទីកន្លែង ធ្វើការចរចារ និងចុះកិច្ចសន្យាការទិញសម្ភារបរិក្ខារផ្សេងៗ ការចរចារដើម្បីផលចំណេញដល់បុគ្គលិក ឬអង្គភាពរបស់ខ្លួន។

បើទោះជាគោលការណ៍ អ្នកដឹកនាំត្រូវបំពេញមុខងារទាំង១០មែន ប៉ុន្តែការប្រើប្រាស់ជាក់ស្តែង វាអាស្រ័យទៅនឹងលំដាប់កម្រិតនៃអ្នកដឹកនាំ លក្ខណៈអង្គភាព បច្ចេកវិទ្យា និងប្រភេទនៃបញ្ហាកើតឡើង។

### *២.២.៥- ការអភិវឌ្ឍ*

***កំរិតនៃការអប់រំនៅកម្ពុជា ( Cambodia's Education development Level )***

ការរៀបចំគោលដៅ អាទិភាព គោលនយោបាយ និងវត្ថុបំណងវិស័យអប់រំ សម្រាប់វិស័យអប់រំជាតិ អាស្រ័យទៅលើ**កម្រិតនៃការអភិវឌ្ឍការអប់រំ**របស់ប្រទេស ព្រមទាំងកត្តាពាក់ព័ន្ធដទៃជាច្រើនទៀតដូចជា ផែនការបង្កើនសេដ្ឋកិច្ច ការអនុវត្តភាពសមស្របនៃទិសដៅ អទិភាពជម្រើសចំពោះថវិកាជាតិ ភាពបន្ទាន់ និងតម្រូវការអប់រំ។

នៅក្នុងរបប**កម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)** អ្នកគ្រប់គ្រង និងបុគ្គលិកសិក្សាកម្ពុជាស្ទើទាំងអស់ត្រូវបានកាប់សំលាប់ មានតែមួយចំនួនតូចប៉ុណ្ណោះបានរស់រានមានជីវិត ដោយខ្លះបានរត់ទៅជ្រកកោននៅបរទេស និងខ្លះទៀតបានលាក់បាំងការពិត ការចេះដឹងមិនឱ្យរដ្ឋអំណាចដឹង។

នៅក្រោមការគ្រប់គ្រងរបស់រដ្ឋកម្ពុជា ( **១៩៧៩-១៩៩២** ) គឺជាដំណាក់កាលនៃការកសាងឡើងវិញ និងការស្តារកម្រិតនៃប្រព័ន្ធអប់រំ។ ដោយអនុលោមទៅតាមភាពចាំបាច់ តម្រូវការអ្នកអប់រំ ក៏ដូចជាការផ្គត់ផ្គង់សម្ភារបរិក្ខារគាំទ្រវិស័យអប់រំដែរ។ គ្រូបង្រៀនមួយចំនួនមិនសូវមានគុណភាពដោយសារការអំពាវនាវឱ្យចូលបំរើការងារ។ សាលារៀនភាគច្រើនត្រូវរៀបចំការកសាងឡើងវិញ ការ

ស្វែងរកដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ។ ភាសាបរទេសដែលយកមកប្រើមាន ភាសារុស្ស៊ី និងភាសាវៀតណាម ជំនួសភាសាបារាំងដែលធ្លាប់បានប្រើនៅក្នុងទសវត្សឆ្នាំ៥០ ឆ្នាំ៦០ និងដើមឆ្នាំ៧០។

អន្តរាគមន៍របស់ អ៊ុនតាក់ **(UNTAC)** និងការបោះឆ្នោតនៅឆ្នាំ១៩៩៣ គឺជាការចាប់ផ្តើមថ្មីមួយនៃរាជរដ្ឋាភិបាល ព្រមជាមួយសេដ្ឋកិច្ចទីផ្សារសេរី និការសន្យាដើម្បីស្តារ និងអភិវឌ្ឍវិស័យអប់រំ។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើជាផ្លូវការមានចែងអំពីភារកិច្ច និងទិសដៅអប់រំជាតិ។ ប្រព័ន្ធអប់រំ ត្រូវបានកែលម្អ ការកសាងសាលារៀនខ្លះនៅតាមទីក្រុង និងតំបន់ជនបទត្រូវបានឧបត្ថមដោយភ្នាក់ងារអន្តរជាតិ និងអ្នកផ្តល់ជំនួយបរទេសនានា។

**ចាប់ពីឆ្នាំ១៩៩៣មក** ការចូលសិក្សារបស់កុមារកម្ពុជា នៅបឋមសិក្សា និងមធ្យមសិក្សា មានការកើនឡើងគួរឱ្យកត់សំគាល់។ ខណៈពេលនោះប្រទេសអភិវឌ្ឍនានាមានអត្រាអក្ខរកម្ម និងអត្រាសិក្សាស្ទើរតែស្មើនឹង១០០% នៅកម្ពុជាត្រូវបានប៉ាន់ស្មានមានត្រឹម៦៥% និងអត្រាសិក្សាឆ្នាំ១៩៩៨មាន ៧៧.៨% សម្រាប់មធ្យមសិក្សាបឋមភូមិ ១៦.៣% និងចំពោះមធ្យមសិក្សាទុតិយភូមិ ៦.៨%។ ( **MoEYS, នាយកដ្ឋានផែនការ ការពន្យល់ពីការផ្តើមផែនការកម្មសម្រាប់មន្ត្រីគ្រប់គ្រងអប់រំ ១៩៩៨ ទំព័រ ៤៧ UNDP, UNESCO** )

## ***ការអភិវឌ្ឍស្ថាប័ន និងធនធានមនុស្ស***

មូលនិធិភាពជាដៃគូអភិវឌ្ឍសមត្ថភាព **(CDPF)** (២០១១-២០១៤) គឺដើម្បីរួមចំណែកក្នុងការងារអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ របស់រាជរដ្ឋាភិបាល(២០០៩-២០១៣) និងការអនុវត្តព្រមទាំងការត្រួតពិនិត្យ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ (២០០៩-២០១៣) របស់ក្រសួងអប់រំ យុវជន និងកីឡា ប្រមទាំងសមិទ្ធិផលនៃការអប់រំសម្រាប់យើងទាំងអស់គ្នា **(EFA)** និងគោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជាតាមរយៈការអនុវត្តផែនការអភិវឌ្ឍសមត្ថភាព (២០១១-២០១៣) និងផែនការមេសម្រាប់អភិវឌ្ឍសមត្ថភាព(២០១១-២០១៥)។ គោលបំណងនៃ **CDPF** គឺដើម្បីគាំទ្រការអនុវត្តគោលដៅអភិវឌ្ឍសមត្ថភាពនៃផែនការវិស័យ ព្រមទាំងផែនការប្រតិបត្តិប្រចាំឆ្នាំ **(AOP)** ដែលបានដំណើរការតាមរយៈផែនការអភិវឌ្ឍសមត្ថភាព (២០១១-២០១៣) និងផែនការមេសម្រាប់ការអភិវឌ្ឍសមត្ថភាព (២០១៣-២០១៥)។

អនុគោលបំណងទាំងបីរបស់ **CDPF** គឺ៖

(១)- ពង្រឹងសមត្ថភាពក្រសួង អប់រំ យុវជន និងកីឡា ក្នុងការធ្វើផែនការគ្រប់គ្រងអប់រំ និងការត្រួតពិនិត្យសម្រាប់ការផ្តល់សេវាអប់រំ គុណផល គុណវិស័យអប់រំ និងលទ្ធផលឱ្យកាន់តែមានភាពប្រសើរឡើង។

(២)- ពង្រឹងសមត្ថភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ធ្វើយ៉ាងណាដើម្បីធានានិរន្តរភាពនៃភាពប្រទាក់ក្រឡា និងទំនាក់ទំនងរវាងម៉ាក្រូ និងដំណើការនៃកំណែតម្រង់កម្រិតគុណវិស័យដើម្បីបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាអប់រំ អភិបាលកិច្ច ពិសេសការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ និងសេវាស៊ីវិល កំណែទម្រង់រដ្ឋបាល។

(៣)- ពង្រឹងសមត្ថភាពក្នុងការធ្វើឱ្យប្រសើរឡើង នូវសមត្ថភាពក្រសួងអប់រំ យុវជន និងកីឡា ក្នុងការស្រូបយកប្រសិទ្ធភាពប្រព័ន្ធធ្វើឱ្យប្រសើរឡើង ការផ្តល់សេវាអប់រំ និងប្រព័ន្ធគណនេយ្យភាព។

(កំណែទម្រង់វិស័យអប់រំនៅកម្ពុជា មាគ៌ាឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាព ហង់ ជួន ណារ៉ុន, 2016)

***ក្របខណ្ឌសមត្ថភាពគោលនយោបាយអាស៊ីអាគ្នេយ៍៖*** (SEAMEO INNOTECH, 2016)

***សមត្ថភាពគោលទី១៖ គំនិតប្រកបដោយយុទ្ធសាស្ត្រ និងនវានុវត្តន៍***

- ❖ ដឹកនាំរៀបចំ ធ្វើតារាងទិសដៅយុទ្ធសាស្ត្រ របស់សាលារៀន
- ❖ ធ្វើការជាមួយសាលារៀន និងសហគមន៍ ពាក់ព័ន្ធក្នុងការអភិវឌ្ឍផែនការយុទ្ធសាស្ត្រសាលារៀន
- ❖ ដឹកនាំក្នុងការអភិវឌ្ឍផែនការយុទ្ធសាស្ត្រសាលារៀន
- ❖ បង្ហាញទស្សនវិស័យសាលារៀន និងធ្វើជាគម្រូនៃតម្លៃការងារ និងការអនុវត្តប្រចាំ
- ❖ បានប្រើប្រាស់ភស្តុតាងច្រើនផ្សេងៗគ្នា ដើម្បីគាំទ្រ
- ❖ ត្រួតពិនិត្យ វាយតម្លៃ និងកែលម្អផែនការយុទ្ធសាស្ត្រ
- ❖ អនុវត្តការពិនិត្យឡើងវិញជាប្រចាំនៃការអនុវត្តន៍គម្រោង ឬកម្មវិធី និងប្រើប្រាស់លទ្ធផលក្នុងការណែនាំពីបញ្ហា និងការព្រួយបារម្ភពីការអនុវត្តន៍ផែនការ
- ❖ ដឹកនាំដំណើរការផ្លាស់ប្តូរសំដៅទៅលើការអនុវត្ត និងអភិវឌ្ឍគោលវិធី ប្រព័ន្ធរចនាសម្ព័ន្ធថ្មី
- ❖ ធ្វើឱ្យមាននិរន្តរភាពគំនិតច្នៃប្រឌិត និងការបង្កើតថ្មី នៅក្នុងកម្មវិធីសាលា ដើម្បីសម្រេចនូវលទ្ធផលសិក្សាខ្ពស់ជាងមុន
- ❖ ការសម្រេចចិត្តដោយផ្អែកដំណឹង
- ❖ ដឹកនាំផ្លាស់ប្តូរ និងធ្វើការបង្កើតថ្មី

***សមត្ថភាពគោលទី១៖ ភាពជាអ្នកដឹកនាំ និងគ្រប់គ្រង***

- ❖ គ្រប់គ្រងធនធាន និងប្រព័ន្ធនៃសាលារៀន
- ❖ គ្រប់គ្រង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុ
- ❖ គ្រប់គ្រងលើបរិស្ថានសិក្សា
- ❖ គ្រប់គ្រងលើនីតិវិធី និងប្រព័ន្ធផ្សេងៗ
- ❖ គ្រប់គ្រងការបំពេញការងាររបស់បុគ្គលិក
- ❖ គ្រប់គ្រងលើតម្រូវការបុគ្គលិកសាលារៀន
- ❖ ផ្តល់ការគាំទ្រដល់ការអភិវឌ្ឍវិជ្ជាជីវៈរបស់បុគ្គលិក
- ❖ ទទួលស្គាល់ការបំពេញការងាររបស់បុគ្គលិក និងលើកទឹកចិត្ត
- ❖ បង្ហាញពីជំនាញគ្រប់គ្រងកម្មវិធី និងគម្រោងអភិវឌ្ឍសាលារៀន
- ❖ លើកកម្ពស់កម្មវិធី និងគម្រោងដែលផ្តោតលើសាលារៀនសម្រាប់ការគាំទ្រការអភិវឌ្ឍដោយនិរន្តរភាព
- ❖ បង្ហាញពីជំនាញគ្រប់គ្រងកម្មវិធី និងគម្រោងអភិវឌ្ឍសាលារៀន

- បានលើកកម្ពស់កម្មវិធី និងគម្រោងដែលផ្តោតលើសាលារៀន សម្រាប់គាំទ្រការអភិវឌ្ឍប្រកបដោយនិរន្តរភាព

***សមត្ថភាពគោលទី២៖ ភាពជាអ្នកដឹកនាំការបង្រៀន និងរៀន***

- គ្រប់គ្រងការអនុវត្តកម្មវិធីសិក្សា
- លើកកម្ពស់សកម្មភាពសិក្សាសិស្សមជ្ឈមណ្ឌល
- បានលើកកម្ពស់បរិស្ថានសាលារៀន ដែលអាចរួមបញ្ចូលសុវត្ថភាព និងសុខភាព
- លើកកម្ពស់វប្បធម៌សន្តិភាព និងការគោរពលក្ខណៈផ្សេងៗគ្នា
- បានបណ្តុះការអប់រំប្រធានក្រុមបច្ចេកទេស
- លើកកម្ពស់ស្មារតីធ្វើការងារជាក្រុមក្នុងការដឹកនាំជាសិក្សាធិការ
- គ្រប់គ្រងលើការវាយតម្លៃដើម្បីកែលម្អការរៀន និងបង្រៀន
- លើកកម្ពស់ការប្រើប្រាស់សម្ភារឧបទ្ទេស ឧបករណ៍បិសោធ ក្នុងពេលបង្រៀន និងរៀន
- គ្រប់គ្រងលើការងារវាយតម្លៃ ដើម្បីកែលម្អការបបង្រៀន និងរៀន

***សមត្ថភាពគោលទី៤៖ ឧត្តមភាពបុគ្គលរបស់គណៈគ្រប់គ្រង***

- ដឹកនាំ និងគ្រប់គ្រងដោយធ្វើជាគំរូល្អក្នុងសារៀន
- បង្ហាញពីគណនេយ្យភាព និងតម្លាភាព
- អនុវត្តរបៀបរស់នៅប្រកបដោយសុខភាពល្អ និងតុល្យភាព
- មានមោទនភាពលើវិជ្ជាជីវៈ
- បង្ហាញលទ្ធផលនៃការគ្រប់គ្រង
- គ្រប់គ្រងលើការងារជាអាទិភាព
- ពន្យល់ពីការសម្រេចចិត្តក្នុងការដោះស្រាយបញ្ហាប្រឈមនានា
- មានទំនួលខុសត្រូវលើការសិក្សាពេញមួយជីវិត
- គាំទ្រនូវតម្លៃ និងទស្សនវិស័យអាស៊ាន និងដៃគូពាក់ព័ន្ធ
- គាំទ្រគោលនយោបាយអប់រំជាតិគឺការកសាងធនធានពេញ

***សមត្ថភាពគោលទី៥៖ ការចូលរួមពីភាគីពាក់ព័ន្ធ***

- បង្កើតទំនុកចិត្ត និងដឹកនាំក្រុម សហគមសម្រាប់កែលម្អសាលារៀន និងដៃគូពាក់ពាន់
- ពង្រឹងការចូលរួមពីសហគមក្នុងការលើកកម្ពស់ដំណើការរបស់សាលារៀន
- ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពខ្ពស់ ជាមួយភាគីពាក់ព័ន្ធផ្សេងៗ
- សម្របសម្រួលភាពជាដៃគូ និងសកម្មភាពសាលារៀន និងសហគមន៍
- ជម្រុញការបង្កើតមតិ ដោយការស្របគ្នា ឬមតិរួម
- គ្រប់គ្រងលើការខ្វែងគំនិតគ្នា និងអនុវត្តជំនាញចរចារ និងដោះស្រាយបញ្ហា
- ទំនាក់ទំនងពីសកម្មភាពរបស់សាលារៀន ដល់ភាគីពាក់ព័ន្ធ

## ២.៣- ទស្សនាទាន នៃការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ

### ២.៣.១- សាវតានៃការអប់រំបច្ចេកទេស និងវិជ្ជាជីវៈកម្រិតមធ្យមសិក្សា

ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ជាបញ្ហាអាទិភាពមួយ ដែលរាជរដ្ឋាភិបាលបាននឹងកំពុងយកចិត្តទុកដាក់ ដើម្បីបណ្តុះបណ្តាលយុវជនឱ្យមានជំនាញបច្ចេកទេសចាំបាច់អាចប្រកបរបរចិញ្ចឹមជីវិតបានក្រោយពីបញ្ចប់កម្រិតសិក្សានីមួយៗ និងរួមចំណែកប្រែក្លាយប្រទេស ពីប្រទេសដែលទទួលប្រាក់ចំណូលមធ្យមកម្រិតទាបទៅជាប្រទេសដែលទទួលបានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាល តាមរយៈក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញគោលដៅពង្រីក និងពង្រឹងវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ដែលជាសាលាផ្តល់ជំនាញបច្ចេកទេសដល់យុវជន។

ការអប់រំបច្ចេកទេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិចាប់បដិសន្ធិឡើងនៅឆ្នាំ២០០៣ ដែលជាការចាប់ផ្តើមដំបូងគេនៃការបង្កើតវិទ្យាល័យកំពង់ឈើទាលស្ថិតនៅក្នុងស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ។ វិទ្យាល័យកំពង់ឈើទាលបានផ្តល់សេវាអប់រំបច្ចេកទេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិលើ៤មុខជំនាញគឺ កេ្សត្រសាស្ត្រ បសុវប្បកម្ម អគ្គិសនី និងអេឡិចត្រូនិចដល់សិស្សចំនួន១៦០នាក់ក្នុងឆ្នាំ២០០៣។ ក្នុងឆ្នាំ២០១៨នេះ វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសសរុបមានចំនួន១៣ ទាំងរដ្ឋ ឯកជន និងអង្គការក្រៅរដ្ឋាភិបាល ចូលរួមផ្តល់សេវាអប់រំបច្ចេកទេសទាំងផ្នែកចំណេះទូទៅ និងផ្នែកបច្ចេកទេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ។

ជារៀងរាល់ឆ្នាំ សិស្សប្រមាណជាង៣០០នាក់បានបញ្ចប់ការសិក្សាពីវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសដោយជោគជ័យ ដែលក្នុងនោះចំនួន៧០%មានការងារធ្វើ ២០%រៀនបន្តទៅកម្រិតឧត្តមសិក្សា ៥%ប្រកបរបរចិញ្ចឹមជីវិតដោយខ្លួនឯង និង៥%មិនទាន់កំណត់គោលដៅច្បាស់លាស់។ នេះសរបញ្ជាក់ឱ្យឃើញថាពលរដ្ឋជំនាញ និងកម្លាំងការងារផលិតកម្មចាប់ផ្តើមរីកដុះដាល ស្របតាមការវិវឌ្ឍនៃកំណើនសេដ្ឋកិច្ច។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏ការផ្គត់ផ្គង់ និងតម្រូវការការងារនៅមិនទាន់ឆ្លើយតបគ្នានៅឡើយទេក្នុងទីផ្សារការងារកម្ពុជា។ ជំនាញបច្ចេកទេសជាតម្រូវការចាំបាច់របស់និយោជក ហើយគុណភាពនៃជំនាញបច្ចេកទេសក៏ត្រូវតែលើកកម្ពស់ តាមរយៈការវាស់វែងជាសូចនាករដែលមានកំណត់ក្នុងស្តង់ដាវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស។

ដោយមើលឃើញពីភាពរីកដុះដាលនៃចំនួនវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសទូទាំងប្រទេស ក្រសួងអប់រំ យុវជន និងកីឡា បានកសាងស្តង់ដាវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ដើម្បីវាស់វែងកម្រិតគុណភាពនៃការផ្តល់សេវាអប់រំបច្ចេកទេស ដែលជាផែនការអាទិភាពមួយក្នុងផែនការគោលសម្រាប់ការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ ២០១៥-២០១៩។ ស្តង់ដាវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស នឹងដើរតួនាទីសំខាន់ ជាកញ្ចក់ឆ្លុះបញ្ចាំងពីកម្រិតនៃការអនុវត្តនៅតាមសាលារៀន ដើម្បីវាយតម្លៃ និងស្វ័យវាយតម្លៃ ផ្អែកលើតម្រូវការជាក់ស្តែងរបស់វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសនីមួយៗ។

**តួនាទី និងគុណសម្បត្តិនាយកក្នុងយុគ្គសម័យឌីជីថល**

នាយកសាលាជាក្បាលម៉ាស៊ីនមួយ សម្រាប់បញ្ជាឱ្យនាវាដឹកនាំគ្រូ និងសិស្សានុសិស្សឆ្ពោះទៅរកការសម្រេចគោលបំណងអប់រំ ឱ្យទាំងប្រកបដោយចីរភាព និងស្របតាមនិន្នាការនៃការរីកចម្រើននៃបច្ចេកវិទ្យា សម័យកាលឌីជីថល ឬសម័យបដិវត្តន៍ឧស្សាហកម្ម **4.0**។ បើតាម (Sheninger (2004), The Pillears of Digital Leadership, Sukanya Chaemchoy (2008)) នាយកសាលារៀនសម័យកាលឌីជីថល ឬសម័យបដិវត្តន៍ឧស្សាហកម្ម **4.0** ត្រូវមានតួនាទី និងគុណសម្បត្តិដូចខាងក្រោម៖

(១)- បំណិនគមនាគមន៍ (Communications Skills)

(២)- ទំនាក់ទំនងសាធារណៈ និងជាមួយសហគមន៍ (Public Relation Skills)

(៣)- បំណិនបង្កើតម៉ាក (Branding Skills)

(៤)- បង្កលក្ខណៈឱ្យសិស្សរៀន (Students engagement Or Learning)

(៥)- បង្កលក្ខណៈឱ្យគ្រូអភិវឌ្ឍជំនាញវិជ្ជាជីវៈ (Professional Growth or Developement)

(៦)- ចេះច្នៃប្រឌិតបរិស្ថានសិក្សាដែលទាក់ទាញដល់ការរៀន និបង្រៀនដោយប្រើវិធីនវានុវត្តន៍ (Re-envisioning Learning spaces and envirronments)

(៧)- ចេះចាប់យក និងផ្តល់ឱកាស (Opportunity)

(ឯកសារ Presentation របស់ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា គុណភាពគ្រូ ជាគុណភាពមូលធនមនុស្សសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ២០១៨)

### *២.៣.២- ស្ថានភាពទូទៅនៃវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី ខេត្តកំពង់ឆ្នាំង*

វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី ស្ថិតនៅក្នុងភូមិសាលាលេខប្រាំ ឃុំអូរឬស្សី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ វិទ្យាល័យនេះមានបុគ្គលិកសរុបចំនួន១០១នាក់ ស្រី៣០នាក់ គ្រូផ្នែកបច្ចេកទេមានចំនួន១៧នាក់។ មានបង្រៀនអគ្គិសនី ក្បេរ្រត្រសាស្រ្ត និងបសុវប្បកម្ម។

**ទិន្នន័យសិស្សក្នុងឆ្នាំសិក្សា២០១៧-២០១៨**

| ជំនាញ | អគ្គិសនី | | | | ក្បេរ្រត្រសាស្រ្ត | | | | បសុវប្បកម្ម | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | សិស្ស | ស្រី | បប | ស្រី | សិស្ស | ស្រី | បប | ស្រី | សិស្ស | ស្រី | បប | ស្រី |
| ឆ្នាំទី១ | 46 | 05 | 02 | 00 | 23 | 16 | 03 | 02 | 05 | 01 | 05 | 01 |
| ឆ្នាំទី២ | 42 | 01 | 02 | 00 | 18 | 15 | 03 | 02 | 12 | 06 | 00 | 00 |
| ឆ្នាំទី៣ | 33 | 11 | 01 | 01 | 44 | 29 | 01 | 00 | 00 | 00 | 05 | 01 |
| **សរុប** | **121** | 17 | 05 | 01 | **85** | 60 | 07 | 04 | **17** | 07 | 05 | 01 |

### ស្ថិតិសិស្សថ្នាក់បច្ចេកទេស ឆ្នាំសិក្សា២០១៦-២០១៧

| ជំនាញ | ចំនួនថ្នាក់ | ឆ្នាំទី១ | | ឆ្នាំទី២ | | ឆ្នាំទី៣ | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| អគ្គិសនី | ០៣ | ៥១ | ០៣ | ៤០ | ១៣ | ២៧ | ១០ |
| គ្រឿងត្រជាក់ | ០៣ | ២៨ | ២៣ | ៤៩ | ៣៣ | ១២ | ០៩ |
| បសុវប្បកម្ម | ០១ | ១៤ | ០៦ | ០០ | ០០ | ០០ | ០០ |
| សរុប | ០៧ | ៩៣ | ៣២ | ៨៩ | ៤៦ | ៣៩ | ១៩ |

### ស្ថិតិសិស្សថ្នាក់បច្ចេកទេស ឆ្នាំសិក្សា២០១៧-២០១៨

| ជំនាញ | ចំនួនថ្នាក់ | ឆ្នាំទី១ | | ឆ្នាំទី២ | | ឆ្នាំទី៣ | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| អគ្គិសនី | | | | | | | |
| គ្រឿងត្រជាក់ | | | | | | | |
| បសុវប្បកម្ម | | | | | | | |
| សរុប | | | | | | | |

#### ២.៣.៣- សារៈសំខាន់នៃការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ

ក្នុងបរិបទសាកលភាវូបនីយកម្ម ការរីកចម្រើនលូតលាស់ឥតឈប់ឈរនៃសម័យបច្ចេកវិទ្យា ជាក់ស្តែងពិភពលោកថ្មីបច្ចុប្បន្នបានផ្ទុំដំណើរមកដល់សម័យកាលបដិវត្តន៍ឧស្សាហកម្ម **4.0 (** ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាចុងក្រោយ គឺប្រព័ន្ធ **Sensor**។ គឺជាសម័យកាលដែលមានការប្រកួតប្រជែងបច្ចេកវិទ្យា។ ក្នុងកាលៈទេសៈ នេះដើម្បីការស្វែងរកនូវឧត្តមភាព គឺទាមទារឱ្យប្រទេសនោះសំបូរទៅដោយធនធានផលិតធនធានមនុស្សផ្នែកបច្ចេកទេស និងសមត្ថភាពគ្រប់គ្រង និងដឹកនាំ ឱ្យបានកម្រិតអតិបរមា។ សមាហរណកម្មនៅក្នុងបណ្តាប្រែសអាស៊ានតម្រូវឱ្យប្រទេសកម្ពុជាចូលរួមក្នុងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង លើវិស័យអាទិភាពដើម្បីរួមចំណែកក្នុងការសម្រេចនូវចក្ខុវិស័យរបស់អាស៊ាន។ ដើម្បីរួមចំណែកក្នុងកិច្ចការអភិវឌ្ឍសង្គមសេដ្ឋកិច្ច រាជរដ្ឋាភិបាលបានប្រមើលមើលឃើញថា ការកសាងកម្លាំងពលកម្មឱ្យមានសមត្ថភាពជំនាញពេញលេញ និងអាចមានលទ្ធភាពសិក្សាស្វែងយល់ និងប្រើប្រាស់បច្ចេកវិទ្យាកម្រិតខ្ពស់ គឺជាកាតព្វកិច្ចដ៏សំខាន់របស់កម្ពុជា ក្នុងការឈានទៅសម្រេចគោលដៅកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព។ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយ និងផែនការសកម្មភាពមួយចំនួនស្តីពីការកសាង និងអភិវឌ្ឍធនធានមនុស្សបច្ចេកទេស ក្នុងការដឹកនាំប្រទេសឆ្ពោះទៅរកការអភិវឌ្ឍជាបន្តបន្ទាប់ និងបានប្រែក្លាយពីប្រទេសដែលមានស្ថានភាពអន់ថយផ្នែកសេដ្ឋកិច្ច និង

មានអត្រាភាពក្រីក្រខ្ពស់ មកជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។ កនុងរយៈពេលជាងមួយទសវត្សកន្លងមកនេះ កម្ពុជាបានសម្រេចកំណើនសេដ្ឋកិច្ចខ្ពស់ប្រចាំឆ្នាំប្រមាណ៧%។

ការអប់រំបច្ចេកទេស និងបណ្តុះបណ្តាលវិជ្ជាជីវៈ **(Technical Vocational Education and Training)** ជាទិដ្ឋភាពនៃដំណោះរការអប់រំ បណ្តុះបណ្តាលបន្ថែមទៅលោការអប់រំផ្នែកបច្ចេកវិទ្យា និងវិទ្យាសាស្ត្រមួយចំនួនទាក់ទងទៅនិងការទាញយកចំណេះដឹងជំនាញ និងការអនុវត្តជាក់ស្តែងក្នុងជីវភាពប្រចាំថ្ងៃ ការគ្រប់គ្រង និងដឹកនាំ ការប្រើប្រាស់នូវបច្ចេកវិទ្យាប្រកបដោយភាពច្បាស់លាស់ ពិសេសការគ្រប់អភិវឌ្ឍសេដ្ឋកិច្ចគ្រួសារ និងប្រទេសជាតិ។ **TVET** ការងារមិនត្រឹមតែបានផ្តល់នូវជំនាញបច្ចេកទេសមួយមុខដល់មនុស្សតែប៉ុណ្ណោះទេ ថែមទាំងបានផ្តល់ដល់មនុស្សការដឹកនាំជីវិតឱ្យរស់នៅប្រកបដោយសុខដុមរមនា ដែលមនុស្សលោកមិនអាចខ្វះបាននាពេលបច្ចុប្បន្ន និងនាពេលអនាគត។ (ការអប់រំរបស់អង្គការ **UNESCO**) ។ យុទ្ធសាស្ត្ររបស់អង្គការយូនេស្កូ បង្កើតក្នុងគោលបំណងដើម្បីពង្រឹងសមត្ថភាពជំនាញបច្ចេកទេស ការគ្រប់គ្រង និងដឹកនាំ ប្រទេសដែលជាសមាជិនៅក្នុងជំនាញ **TVET** និងផ្តោតទៅលើវិធី ឬរបៀបក្នុងការផ្លាស់ប្តូរ និងពង្រីកការងារ **TVET** ដើម្បីធានាថា មនុស្សពេញវ័យទាំងអស់អាចកសាង និងអភិវឌ្ឍសមត្ថភាពជំនាញដែលមានភាពចាំបាច់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃបានប្រកបដោយជោគជ័យ។ អង្គការយូនេស្កូ បានរៀបចំសកម្មភាពពិភាក្សាជាលក្ខណៈអន្តរជាតិ ស្តីពីការបង្កើតជំនាញ និងសេចក្តីសន្និដ្ឋានមាននៅក្នុងឯកសារ "ទីក្រុងសៀងហៃជាផ្លូងមួយ"។ អង្គការ **UNESCO** បានបង្កើតមជ្ឈមណ្ឌលអន្តរជាតិ **UNEVOC** លើការងារអប់រំបច្ចេកទេស និងវិជ្ជាជីវៈ**(UNESCO–UNEVOC International Center For Technical and Vocational Education and Training)** ។ មជ្ឈមណ្ឌលនេះបានជួយរដ្ឋដែលជាសមាជិករបស់អង្គការយូនេស្កូ ដើម្បីពង្រឹង និងការធ្វើឱ្យកាន់តែប្រសើរឡើងនៃប្រព័ន្ធ **TVET** និងការជ្រើសរើសជំនាញសម្រាប់ទីផ្សារការងារ ដែលជាកត្តាដ៏សំខាន់សម្រាប់សេដ្ឋកិច្ច និងសង្គម។ ការសិក្សាបានបង្ហាញថា **TVET** ជាតម្រូវការចាំបាច់របស់មនុស្សក្នុងការគាំទ្រជីវភាពប្រចាំថ្ងៃ និងសេចក្តីត្រូវការនៃទីផ្សារការងារដែលប្រកបដោយគុណភាពខ្ពស់។ អង្គការយូនេស្កូមានស្ថាប័ន **UNEVOC** ប្រមាណ២៥០កន្លែង និងស្ថាប័នដែលមានជំនាញឯកទេសក្នុង **TVET** ក្នុងបណ្តាប្រទេសចំនួន១៥៧ នៅទូទាំងពិភពលោក។ យុទ្ធសាស្ត្ររបស់អង្គការយូនេស្កូ **UNESCO TVET(2010- 2015)** គាំទ្រប្រទេសជាសមាជិកតាមរយៈកត្តាសំខាន់ៗដែលជាធាតុស្នូលចំនួនបីធំៗគឺ៖ (១)- ការផ្តល់ដំបូន្មានអំពីគោលនយោបាយ និងការអភិវឌ្ឍសមត្ថភាព។ (២)- ផ្តល់ជាគំនិត ផែនការនៃការអភិវឌ្ឍជំនាញណិងការធ្វើឱ្យប្រសើរោឡើងនូវការត្រួតពិនិត្យ។ និងទី(៣)- ដើរតួជា **Clearing House** និងជាការជូនដំណឹងជាសកលអំពីការជជែកគ្នាលើការងារ **TVET**។

### *២.៣.៤- ចក្ខុវិស័យនៃគ្រប់គ្រង និងដឹកនាំការអភិវឌ្ឍលើការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ*

**ផ្នែកទី១៖ ការគ្រប់គ្រង និងដឹកនាំ**ការអភិវឌ្ឍការអប់រំបច្ចេកទេស និងវិជ្ជាជីវៈរបស់ប្រទេសជប៉ុន

ផ្នែកទី២៖ ការគ្រប់គ្រង និងដឹកនាំការអភិវឌ្ឍការអប់រំបច្ចេកទេស និងវិជ្ជាជីវៈរបស់វិទ្យាល័យ **ចំណេះទូទៅ និងបច្ចេកទេស ព្រះបាទសម្ដេច ព្រះបរមនាថ នរោត្តមសីហមុនី** ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ព្រះបាទសម្ដេច ព្រះបរមនាថ នរោតមសីហមុនី បានចាប់ដំណើរការសាងសង់នៅដើមឆ្នាំ២០១០ និងបានបញ្ចប់ការសាងសង់នៅចុងឆ្នាំ២០១២ ក្រោមព្រះរាជទានរបស់ព្រះករុណា ព្រះបាទសម្ដេច ព្រះបរមនាថ នរោត្តមសីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងបានដាក់ឱ្យដំណើរការរៀន និងបង្រៀននៅក្នុងឆ្នាំសិក្សា២០១២-២០១៣។

នៅក្នុងឆ្នាំសិក្សា២០១៧-២០១៨ វិទ្យាល័យបានដំណើរការរៀន និងបង្រៀនលើបីមុខជំនាញ គឺជំនាញអគ្គិសនី គ្រឿងត្រជាក់ និងជំនាញបសុវប្បកម្ម។

**ការងារគ្រប់គ្រង និងដឹកនាំ៖** វិទ្យាល័យនេះបានរៀបចំជា ចក្ខុវិស័យ បេសកកម្ម ផែនការប្រតិបត្តិប្រចាំឆ្នាំ ផែនការអភិវឌ្ឍសាលារៀន បំណែងចែកភារកិច្ចគណៈគ្រប់គ្រង និងបុគ្គលិក ក្ដារខៀនព័ត៌មាន និងបានប្រើប្រាស់ជាប្រចាំ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន

***ការរៀបចំផែនការអភិវឌ្ឍសាលារៀន (SDP)៖***

(១)- **មានរៀបចំចក្ខុវិស័យ និងបេសសកម្ម៖** មាន និងបានបិទផ្សាយ ការពិនិត្យ និងបានធ្វើបច្ចុប្បន្នភាពឡើងវិញ

(២)- **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន៖** មានសៀវភៅផែនការយុទ្ធសាស្ត្រ និងបានផ្សព្វផ្សាយ

(៣)- **ផែនការប្រតិបត្តិប្រចាំឆ្នាំ៖** បានរៀបចំ ផ្សព្វផ្សាយ និងអនុវត្តន៍

(៤)- **រចនាសម្ព័ន្ធតួនាទី និងភារកិច្ចវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស៖** មានរចនាសម្ព័ន្ធ គណៈគ្រប់គ្រង

***ការគ្រប់គ្រងថវិកា៖***

(១)- **ផែនការយុទ្ធសាស្ត្រថវិកា៖** មានសៀវភៅផែនការថវិកា និងអនុវត្តតាមផែនការដែលបានគ្រោងទុក

(២)- **កិច្ចបញ្ជិការគណនេយ្យ៖** មានប័ណ្ណចំណូលចំណាយ និងបញ្ជីតាមដានថវិកាត្រឹមត្រូវ

(៣)- **តារាងតម្លាភាពថវិកា៖** បានរៀបចំ និងបិទផ្សាយ

(៤)- **រចនាសម្ព័ន្ធគ្រប់គ្រងថវិកា៖** បានរចនាសម្ព័ន្ធ និងបានផ្សព្វផ្សាយដល់បុគ្គលិក និងសាធារណៈ

(៥)- **ការប្រើប្រាស់ថវិកា៖** មានរបាយការណ៍សក្ខភាព និងវិក័យបត្រចំណាយត្រឹមត្រូវ

(៦)- **បញ្ជីតាមដានការប្រើប្រាស់ថវិកា៖** បានរៀបចំ និងប្រើប្រាស់ត្រឹមត្រូវ

***ការគ្រប់គ្រង និងរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារបរិក្ខារបច្ចេកទេស៖***

**(១)- បានដឹកនាំ និងរៀបចំឱ្យមានផ្ទៃដីធំទូលាយ បរិស្ថានល្អ និងមានរបងការពារ**

**(២)- មានក្លោងទ្វារ និងស្លាកឈ្មោះវិទ្យាល័យ និងបានថែទាំបានល្អ**

(៣)- **សួនផ្កា ដើមឈើ និងសួនជីវៈចម្រុះ៖** មានសួនផ្កា ដើមឈើ និងសួនជីវៈចម្រុះល្អ និងបានថែទាំជាប្រចាំ

(៤)- **ទង់ជាតិ៖** បានរៀបចំ និងចងបានត្រឹមត្រូវ និងការតុបតែងលម្អ

(៥)- **កន្លែងសម្រាប់សិស្សអង្គុយ និងលំហែកាយ៖** មានកន្លែងសម្រាប់សិស្សអង្គុយសម្រាកលំហែកាយ និងអានសៀវភៅ និងមានការថែទាំជាប្រចាំ

(៦)- **បាវចនាជាតិ៖** មានដាក់តាំងព្រះឆាយាល័ក្ខណ៍ ព្រះបរមរនកោដ្ឋ ព្រះឆាយាល័ក្ខណ៍ព្រះមហាក្សត្រី និងព្រះឆាយាល័ក្ខណ៍ ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី តាមសេចក្តីណែនាំបានត្រឹមត្រូវ

(៧)- **អគារសិក្សា៖** មានរៀបចំថ្នាក់រៀនតាមនិយាមសិស្សថ្នាក់

(៨)- **អគារទីចាត់ការ បន្ទប់ធ្វើការរបស់គណៈគ្រប់គ្រង គ្រូបង្រៀន និងបុគ្គលិករដ្ឋបាល៖**

មានការរៀបចំទីចាត់ការ ការរៀបន្ទប់របស់គណៈគ្រប់គ្រង គ្រូបង្រៀន និងបុគ្គលិករដ្ឋបាលបានត្រឹមត្រូវ

(៩)- **អគារពហុបំណង៖** បានដឹកនាំរៀបចំឲ្យមានអគារសាលប្រជុំ ការតុបតែងពាក្យស្លោក និងរៀបចំឱ្យមានសម្ភារបរិក្ខាគាំទ្រផ្សេងៗ

(១០)- **បណ្ណាល័យ៖** បានរៀបចំបណ្ណាល័យ មានបណ្ណាក្សគ្រប់គ្រង និងដឹកនាំ និងគាំទ្រសកម្មភាពប្រើប្រាស់បណ្ណាល័យ ការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់បណ្ណាល័យ ការរៀបចំការគ្រប់គ្រង និងការទទួលខុសត្រូវ ដឹកនាំការកសាងឯកសារគាំទ្រមុខជំនាញ(តែមិនទានគ្រប់គ្រន់) មានការថែទាំ និងគ្រប់គ្រ់ស្ថិតិ អ្នកអាន អ្នកខ្ចីសៀវភៅបានត្រឹមត្រូវតាមការណែនាំរបស់ក្រសួង។

(១១)- **ផ្ទះសំណាក់គ្រូបង្រៀន៖** បានរៀបចំ និងយកអគារសិក្សាចាស់ដែលសល់ពីការសិក្សាបែងចែកឱ្យគ្រូមកពីទីឆ្ងាយបានស្នាក់នៅ និងការថែទាំ

(១២)- **កន្លែងស្នាក់នៅសិស្ស៖** បានច្នៃរៀបចំឱ្យមានទីកន្លែងនៃការស្នាក់នៅបណ្តោះអាសន្នដោយយកអគារសិក្សាចាស់ដែលនៅសល់សម្រាប់ស្នាក់នៅក្នុងការសិក្សានិងមានការគ្រប់គ្រង ពីគ្រូ

(១៣)- **ការរៀបចំប្រព័ន្ធអគ្គិសនីសម្រាប់បន្ទប់ប្រតិបត្តិ៖** បានដឹកនាំរៀបចំបណ្តាញអគ្គិសនីមានលក្ខណៈបច្ចេកទេស អនាម័យ និងសុវត្ថិភាព។

(១៤)- **កសិដ្ឋានសម្រាប់សិស្សប្រតិបត្តិជំនាញ៖** បានដឹកនាំរៀបចំដីសម្រាប់ដាំដុះ ប្រព័ន្ធទឹក វត្ថុធាតុដើម សម្ភារៈគ្រឿងយន្តកសិកម្ម( គាំទ្រដោយគម្រោងទីភ្នាក់ងារអភិវឌ្ឍឆេក)។

***ការគ្រប់គ្រងសាលារៀន (School Management)***

នាយករង នាយិការង មានគ្រប់គ្រាន់ និងត្រឹមត្រូវតាមនិយាមនៃការបហារើប្រាស់បុគ្គលិករបស់ក្រសួងអប់រំ យុវជន និងកីឡា និងមានការបែងចែកការទទួលខុសត្រូវ និងការបំពេញភារកិច្ចទៅតាមផ្នែកនីមួយៗច្បាស់លាស់៖

(១)- **ការគ្រប់គ្រងតាមបែប (School Based Management)៖** ការចូលរួមរបស់មាតាបិតា

សហគមន៍ ការអញ្ជើញមាតាបិតាមកស្ដាប់ពីការណែនាំ និងការសិក្សារបស់កូននៅដើមឆ្នាំសិក្សា និងមុនពេលប្រលងឆមាសជាដើម។ ការអនុញ្ញាតឱ្យមាតាបិតាសិស្សបានដឹងពីលទ្ធផលសិក្សារបស់កូន។ សកម្មភាពសង្គមមួយចំនួនដូចជាពិធីសាសនា ការរៀបចំការតាំងពិព័រណ៍ស្នាដៃសិស្សជាដើម។ល។

(២)- **សកម្មភាពអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ៖** បានគ្រប់គ្រង និងផ្ដល់ឱកាសសម្រាប់នាយយកនាយករង គ្រូបង្រៀន និងសិស្សានុសិស្សឱ្យទៅពង្រឹងសមត្ថភាព តាមរយៈការបណ្ដុះបណ្ដាល សិក្ខាសាលា កម្មសិក្សា ទស្សនកិច្ចសិក្សាក្នុង និងក្រៅប្រទេស។

(៣)- **ក្រុមប្រឹក្សាអធិការកិច្ចគ្រូបង្រៀន៖** នាយកសាលា នាយករង និងប្រធានក្រុមបច្ចេកទេសតាមជំនាញបានរៀបចំផែនការអធិការកិច្ច (តែមិនបានអនុវត្តឱ្យបានទៀងទាត់ និងត្រឹមត្រូវតាមផែនការគ្រោងទុក)

(៤)- **ក្រុមប្រឹក្សាវិន័យសាលា៖** បានរៀបចំ និងគណៈកម្មការប្រឹក្សាវិន័យ និងបញ្ជីឈ្មោះសមាជិកតាមរយៈលិខិតបង្គាប់ការ

(៥)- **មានគណៈកម្មកាទ្រទ្រង់សាលា៖**

(៦)- **មានកិច្ចសហការរវាងសាលា និងវិស័យឯកជន ដៃគូជាតិ និងគូអន្តរជាតិ៖** មានការទំនាក់ទំនងតាមបណ្ដាក្រុមហ៊ុនឯកជន រោងចក្រ កសិដ្ឋាន សម្រាប់សិស្សចុះកម្មសិក្សា ទស្សនកិច្ចសិក្សា និងការចុះអនុស្សរណៈយោគយល់គ្នាជាមួយបរទេសឆេក ប្រទេសកូរ៉េ សាលាUST ជាដើម។

(៧)- **លទ្ធផលការសិក្សារបស់សិស្ស៖** អត្រាសិស្សប្រលងឆមាសជាប់ អត្រាសិស្សប្រលងប្រចាំខែជាប់ អត្រាសិស្សប្រលងបញ្ចប់ឆ្នាំសិក្សាជាប់ អត្រាសិស្សប្រលងសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ជាប់ ស្នាដៃសិស្សផលិតបានសម្រាប់តាំងពិព័រណ៍

(៨)- **លទ្ធផលសិក្សារបស់សិស្សក្រោយបញ្ចប់ការសិក្សាដោយជោគជ័យ៖** អត្រាសិស្សបន្តការសិក្សា អត្រាសិស្សរកការងារធ្វើ អត្រាសិស្សប្រកបរអាជីវកម្មខ្លួនឯង

(៩)- **កម្មសិក្សាសិស្ស៖** បានដឹកនាំ និងបែងចែកសិស្សចុះកម្មសិក្សាទៅតាមបណ្ដាក្រុមហ៊ុនសហគ្រាស រោងចក្រដែលបានទំនាក់ទំនងដោយក្រសួង នាយកសាលា និងតាមរយៈគ្រូបង្រៀន

ដោយរៀបចំឱ្យមានលិខិតអនុញ្ញាតពីមាតាបិតាសិស្ស លិខិតចុះកម្មសិក្សាចេញដោយសាលា របាយការណ៍សកម្មភាពសិក្សារបស់សិស្ស លិខិតយល់ព្រមទទួលយកការចុះកម្មសិក្សាពីសហគ្រាស រោងចក្រ ឬក្រុមហ៊ុន កសិដ្ឋាន និងលិខិត ឬវិញ្ញាបនបត្របញ្ជាក់ការសិក្សាដោយជោគជ័យ។

(១០)- **ទស្សនកិច្ចសិក្សា៖** រៀបចំកម្មវិធីទស្សនកិច្ចសិក្សាសម្រាប់សិស្សជារៀងរាល់ឆ្នាំតាមបណ្តាសាលាបច្ចេកទេស ឬក្រុមហ៊ុននៅក្នុងប្រទេស។

***គ្រូបង្រៀនផ្នែកបច្ចេកទេស៖***

គ្រូបង្រៀនរៀបចំសៀវភៅរដ្ឋបាលគ្រូ និងប្រើប្រាសើជាប្រចាំនៅពេលបង្រៀន

(១)- **ក្រុមបច្ចេកទេស៖** មានក្រុមបច្ចេកទេសតាមក្រុមមុខវិជ្ជាចំណេះទូទៅ និងបច្ចេកទេស មានប្រធានក្រុម០១រូប និងអនុប្រធានក្រុម០១រូប មានបញ្ជីឈ្មោះសមាជិកក្រុម មានផែនការការងារក្រុម ការប្រជុំប្រចាំខែ និងរបាយការណ៍។

(២)- **សកម្មភាពអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន៖** ការប្រគួតប្រជែងគ្រូបង្រៀនដែលមានស្នាដៃ ការបញ្ជូនគ្រូទៅចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា ការប្រជុំនានា ទស្សនកិច្ចសិក្សា ចូលរួមក្រុងគម្រោង ការដឹកនាំការចុះកម្មសិក្សាសិស្ស ការដឹកនាំក្រុមរៀបចំស្នាដៃសិស្សសម្រាប់តាំងពិព័រណ៍ប្រចាំឆ្នាំ។

(៣)- **ការវាយតម្លៃកម្រិតអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន៖** ការតាមដាយពីសភាពការណ៍ ការនិតយាយតគ្នាពីសិស្ស និងវាយតម្លៃគ្រូតាមរយៈការចុះអធិការកិច្ចលើការបង្រៀន។

(៤)- **ការងារបន្ទុកថ្នាក់៖** បានរៀបចំគ្រូបន្ទុកថ្នាក់តាមជំនាញ និងថ្នាក់ស្របនីមួយៗ និងមានលិខិតបង្គាប់ការ និងបានពិនិត្យតាមដានការអនុវត្តការងារ ដែលគ្រូបន្ទុកម្នាក់ៗត្រូវធ្វើដូចការរៀបចំកិច្ចការរដ្ឋបាលថ្នាក់ផ្សេងៗ ការកោះហៅមាតាបិតាសិស្សក្នុងករណីសិស្សមានបញ្ហា(មានបញ្ជី និងលិខិតស្នាមត្រឹមត្រូវ)។

***សុខមាលភាព អនាម័យ និងសុវត្ថិភាព៖***

( ១)- **ប្រព័ន្ធថែទាំ និងការពារសុខមាលភាព៖** អនុវត្តមិនទាន់បានល្អ

(២)- **ប្រព័ន្ធការពារសុវត្ថិភាព៖** មិនទាន់មានឧបករណ៍ និងសម្ភារៈគ្រប់គ្រាន់នៅផ្នែកនេះ

(៣)- **បុគ្គលិកសន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យ៖** មានបុគ្គលិកសន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យ (ជាបុគ្គលិកជាប់កិច្ចសន្យា និងជួលបន្ថែម) និងបានបែងចែកាកាទទួលខុសត្រូវ។

***កម្មវិធីសិក្សាអប់រំបច្ចេកទេស៖***

(១)- **កម្មវិធីសិក្សាអប់រំបច្ចេកទេស៖** មានដឹកនាំរៀបចំកម្មវិធីសិក្សា និងអនុវត្តតាមសេចក្តីណែនាំរបសើនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈនៃក្រសួងអប់រំ យុវជន និងកីឡាបានត្រឹមត្រូវ ការអនុវត្តលើទ្រឹស្តី៤០% និងការងនុវត្ត៦០%។ ដឹកនាំសិស្សរៀបចំគម្រោងសិក្សាលើជំនាញបច្ចេកទេស (សម្រាប់សិស្សឆ្នាំទី៣) ការចុកម្មសិក្សា និងទស្សនកិច្ចសិក្សា។

(២)- **សៀវភៅសិក្សាគោល៖** បានដឹកនាំប្រើប្រាស់ សៀវភៅគោលរបស់ក្រសួងដែលមាន។ សម្រាប់ជំនាញ រផ្នាំដែលគ្មាននាយកដឹកនាំគ្រូស្រាវជ្រាវកសាងបន្ថែមសម្រាប់ការបង្រៀន។ គ្រូមានបញ្ហាប្រឈមលើសៀវភៅសិក្សាគោល (ខ្វះសៀវភៅសិក្សាគោល និងឯកសារស្រាវជ្រាវជំនាញ)។ ចំណែកឯសៀវភៅសោក្សាគោលចំណេះទូទៅមានគ្រប់គ្រាន់ និងបានប្រើប្រាស់ត្រឹមត្រូវ។

***ការគ្រប់គ្រងសិស្ស៖***

- រៀបចំបញ្ជីឈ្មោះតាមថ្នាក់ និងតាមជំនាញបានច្បាស់លាស់
- បញ្ជីវត្តមានសិស្សតាមថ្នាក់
- រៀបចំ និងពិនិត្យតាមដានការសិក្សារបស់សិស្សតាមរយៈគ្រូបង្រៀន និងគ្រូបន្ទុកថ្នាក់
- តាមដានការបោះបង់ការសិក្សារបស់សិស្ស
- ស្ថិតិសិស្សចុះកម្មសិក្សាប្រចាំឆ្នាំ
- ស្ថិតិសិស្សចុះទស្សនកិច្ចសិក្សាប្រចាំឆ្នាំ
- ស្ថិតិសិស្សបន្តការសិក្សា និងមានការងារធ្វើ
- រៀបចំស្ថិតិសិស្សបានបញ្ចប់ការសិក្សាតាមឆ្នាំនីមួយៗ
- រៀបចំក្រុមប្រឹក្សាកុមារ និងយុវជន
- ក្រុមយុវជនស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា
- ក្រុមយុវជនស្ម័គ្រចិត្តកាយរឹទ្ធិកម្ពុជា
- ការចូលរួមសកម្មភាពរបស់សិស្ស

***ការងារគ្រប់គ្រងបច្ចេកទេស៖***

- រៀបចំក្រុមបច្ចេកទេសតាមមុខវិជ្ជា និងជំនាញនីមួយៗ
- ដឹកនាំការបច្ចេកទេសតាមក្រុម និងជំនាញ និងរបាយការណ៍លទ្ធផល
- ដឹកនាំការងារប្រជុំបច្ចេកទេសតាមមុខជំនាញ
- បែងចែកតារាង និងសេវានៃការចុះអង្កេតការបង្រៀន និងរៀន
- រៀបចំគម្រោង និងផែនការចុះកម្មសិក្សា និងទស្សនកិច្ចសិក្សាសិស្ស

***ការងារគ្រប់គ្រងបុគ្គលិក៖***

- តារាងបញ្ជីឈ្មោះគ្រូបង្រៀន ឬតារាងសន្និធិគ្រូបង្រៀន និងបានធ្វើបច្ចុប្បន្នភាព
- បញ្ជីវត្តមានគ្រូប្រចាំថ្ងៃ តាមសេវាប្រចាំថ្ងៃ
- ការលើកទឹកចិត្តគ្រូបង្រៀនតាមតយៈការបែងចែកសេវាបង្រៀន ការផ្តល់ឱកាសបន្តការសិក្សា ទស្សនកិច្ចសិក្សាក្នុង និងក្រៅប្រទេស។ល។

## ២.៣.៥- ទិសដៅនៃការអភិវឌ្ឍការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ

## ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣

### ១. ការវិភាគស្ថានភាពទូទៅ

ការអប់រំបច្ចេកទេសនៅមធ្យមសិក្សាបានអនុវត្តនៅក្នុងប្រព័ន្ធអប់រំចាប់ពីឆ្នាំ ២០០២ នៅវិទ្យាល័យកំពង់ឈើទាលស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ។ មកដល់ឆ្នាំសិក្សា២០១៧-២០១៨ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសចំនួន ១១ ទាំងរដ្ឋ និងឯកជន ដែលមានសិស្សចូលរៀនសរុបចំនួន ១៤៧២នាក់ និងគ្រូសរុបចំនួន ៩៣នាក់ ផ្តល់សេវាអប់រំបច្ចេកទេសលើមុខជំនាញអគ្គិសនី អេឡិចត្រូនិច មេកានិច គ្រឿងត្រសាស្ត្រ និងបសុវប្បកម្ម។ ទន្ទឹមនឹងនេះ ក្រសួងអប់រំ យុវជន និងកីឡាក៏បានបង្កើតមជ្ឈមណ្ឌលអប់រំបច្ចេកទេសមិត្តភាពកម្ពុជា-ជប៉ុន ដែលបណ្តុះបណ្តាលលើជំនាញវគ្គខ្លីៗដូចជាជំនាញកសិកម្ម និងកុំព្យូទ័រ (រយៈពេល០៣ខែ) និងជំនាញភាសាជប៉ុន រយៈពេល ០២ឆ្នាំ។

### ២. គោលដៅគោលនយោបាយ

- បណ្តុះបណ្តាលសិស្សឱ្យមានជំនាញពិតប្រាកដ និងសមស្របតាមតម្រូវការទីផ្សារការងារ ងាយស្រួលក្នុងការរកការងារធ្វើ អាចប្រកបរបរចិញ្ចឹមជីវិតបាន ឬអាចបន្តការសិក្សាទៅថ្នាក់ឧត្តមសិក្សានៅតាម គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ
- ពង្រឹងប្រព័ន្ធគ្រប់គ្រង និងមុខងារវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសដោយធានាផ្តល់សេវាអប់រំបច្ចេកទេសប្រកបដោយគុណភាពខ្ពស់

### ៣. សកម្មភាពគោលនយោបាយ

- រៀបចំលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់ដំណើរការប្រឡងបញ្ចប់ផ្នែកអប់រំបច្ចេកទេស
- អភិវឌ្ឍឧបករណ៍សម្រាប់ចុះពិនិត្យតាមដាន និងចុះពង្រឹកការអប់រំបច្ចេកទេស
- រៀបចំសេចក្តីណែនាំសុវត្ថិភាពបន្ទប់ពិសោធន៍
- រៀបចំឯកសារណែនាំស្តីពីការគ្រប់គ្រង និងសុវត្ថិភាពបន្ទប់ពិសោធន៍
- រៀបចំឯកសារណែនាំស្តីពីការចុះកម្មសិក្សា
- ផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តស្តង់ដាវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស
- កសាងផែនការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគណៈគ្រប់គ្រង និងគ្រូបង្រៀនផ្នែកអប់រំបច្ចេកទេស
- ផ្តល់វគ្គបំប៉ន ស្តីពីដំណើរការអនុវត្តស្តង់ដាវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ចំពោះគណៈគ្រប់គ្រងសាលា និងគ្រូបង្រៀនផ្នែកអប់រំបច្ចេកទេស
- បណ្តុះបណ្តាលគណៈគ្រប់គ្រង និងបេឡាសាលាពីបែបបទនៃការគ្រោង និងប្រើប្រាស់ថវិកាសម្រាប់វិទ្យាល័យ ចំណេះទូទៅ និងបច្ចេកទេស
- រៀបចំសេចក្តីណែនាំ ស្តីពីកិច្ចសហប្រតិបត្តិការរវាងសាលារៀន និងវិស័យឯកជន
- ពិនិត្យឡើងវិញផែនការគោលផ្នែកអប់រំបច្ចេកទេស។

## ៤. បញ្ហាប្រឈមជាអាទិភាព

- សម្ភារគាំទ្រការប្រតិបត្តិមួយចំនួនពុំទាន់សមស្របតាមកម្មវិធីសិក្សា
- ចំនួនគ្រូបច្ចេកទេសតាមមុខជំនាញនីមួយៗមិនទាន់មានគ្រប់តាមតម្រូវការ
- ការសហការរវាងសាលា និងវិស័យឯកជនមិនទាន់បានប្រសើរ
- សមត្ថភាពគ្រូជំនាញនីមួយៗមិនទាន់មានបទពិសោធន៍លើការងារប្រតិបត្តិ
- ប្រព័ន្ធគ្រប់គ្រងទិន្នន័យ (Database) មិនទាន់មានសម្រាប់គ្រប់គ្រងទិន្នន័យសិស្ស និងការងារប្រឡង
- សៀវភៅសិក្សាគោលមិនទាន់បំពេញតាមតម្រូវការមុខជំនាញ និងគ្រប់កម្រិតឆ្នាំ។

## ៥. អាទិភាព និងយុទ្ធសាស្ត្រ

***អាទិភាពទី១ ៖ លើកកម្ពស់ការគ្រប់គ្រងតាមសាលារៀនប្រកបដោយប្រសិទ្ធភាព***

***យុទ្ធសាស្ត្រទី១ ៖ កែលម្អការបំពេញការងារ និងការទទួលខុសត្រូវរបស់សាលារៀន***

- រៀបចំសេចក្តីណែនាំ ស្តីពីការពង្រឹងច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- ចងក្រងឯកសារស្តីពីកម្រងការងាររបស់នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ
- បំប៉នគណៈគ្រប់គ្រងសាលានិងគ្រូផ្នែកអប់រំបច្ចេកទេសស្តីពីឯកសារកម្រងការងាររបស់នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ

***យុទ្ធសាស្ត្ររងទី១.១ ៖ ពង្រឹងសមត្ថភាពគ្រប់គ្រងអប់រំ (គណៈគ្រប់គ្រងសាលា និងគ្រូ)***

- បង្កើតកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធដើម្បីអភិវឌ្ឍគ្រូអប់រំបច្ចេកទេស និងគណៈគ្រប់គ្រង
- បំប៉នឯកសារណែនាំ ស្តីពីការផលិតសម្ភារឧបទ្ទេសបង្រៀន និងរៀន
- បំប៉នឯកសារ ស្តីពីការសិក្សាស្រាវជ្រាវសកម្ម (Action Research)

***យុទ្ធសាស្ត្ររងទី១.២ ៖ ពង្រឹងយន្តការពិនិត្យតាមដានការបង្រៀន និងរៀន***

- កែលម្អឧបករណ៍ចុះពិនិត្យតាមដានការបង្រៀន និងរៀន និងការប្រឡងឆមាស
- រៀបចំឧបករណ៍វាយតម្លៃវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសឆ្នើម
- ពិនិត្យតាមដាន ការអនុវត្តស្តង់ដារវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស
- ពិនិត្យតាមដានដំណើរការរៀន បង្រៀន និងការប្រឡងគ្រប់ប្រភេទ

***យុទ្ធសាស្ត្ររងទី១.៣ ៖ ពិនិត្យឡើងវិញលើរចនាសម្ព័ន្ធគ្រប់គ្រង លិខិតបទដ្ឋានគតិយុត្តនានា***

- កែលម្អលិខិតបទដ្ឋានគតិយុត្តនានា ស្តីពីការប្រឡងផ្នែកអប់រំបច្ចេកទេស
- រៀបចំសេចក្តីណែនាំ ស្តីពីលក្ខន្តិកៈវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសឆ្នើម
- រៀបចំគណៈកម្មការវាយតម្លៃវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសឆ្នើម
- រៀបចំសេចក្តីណែនាំ ស្តីពីវិធីសាស្ត្រនៃការបង្រៀន (សិស្សមជ្ឈមណ្ឌល វិធីរិះរក ការស្រាវជ្រាវមេរៀន និងវិធីសាស្ត្រផ្អែកលើគម្រោង)

- រៀបចំសេចក្តីណែនាំ ស្តីពីការប្រើប្រាស់សៀវភៅណែនាំការបង្រៀនតាមមុខជំនាញ
- រៀបចំសេចក្តីណែនាំ ស្តីពីការអនុវត្តស្តង់ដារវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស
- រៀបចំប្រកាស ស្តីពីការអនុវត្តស្តង់ដារវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស
- រៀបចំសេចក្តីណែនាំ ស្តីពីការគ្រប់គ្រងបន្ទប់ពិសោធន៍
- រៀបចំសេចក្តីណែនាំ ស្តីពីការការពារ និងសុវត្ថិភាពបន្ទប់ពិសោធន៍
- រៀបចំសេចក្តីណែនាំ ស្តីពីការរៀបចំផែនការអភិវឌ្ឍសាលា និងគ្រប់គ្រងថវិកាប្រកបដោយតម្លាភាព និងគណនេយ្យភាព
- រៀបចំសេចក្តីណែនាំ ស្តីពីនិយាមការប្រើប្រាស់គ្រូបង្រៀនផ្នែកអប់រំបច្ចេកទេស
- រៀបចំសេចក្តីណែនាំ ស្តីពីការពង្រាយគ្រូផ្នែកអប់រំបច្ចេកទេស
- រៀបចំសេចក្តីជូនដំណឹង ស្តីពីការបង្កើតកម្មវិធីស្ពានចម្លង
- រៀបចំឯកសារទស្សនទានកម្មវិធីស្ពានចម្លង
- រៀបចំសេចក្តីណែនាំ ស្តីពីការអនុវត្តកម្មវិធីស្ពានចម្លង
- រៀបចំសេចក្តីណែនាំ ស្តីពីការប្រមូលទិន្នន័យសិស្សក្រោយបញ្ចប់ការប្រឡងសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣

***យុទ្ធសាស្ត្ររងទី១.៤ ៖ ពង្រឹងកម្មវិធីប្រឡងប្រណាំង លើកទឹកចិត្តដល់អ្នកដែលមានស្នាដៃល្អ***

- បង្កើតកម្មវិធីប្រកួតប្រជែងលើវិធីសាស្ត្របង្រៀន
- បង្កើតកម្មវិធីប្រកួតប្រជែងស្នាដៃស្រាវជ្រាវបង្កើតថ្មីរបស់គ្រូ
- បង្កើតកម្មវិធីប្រកួតប្រជែងស្នាដៃរបស់សិស្ស
- ចូលរួមកម្មវិធីតាំងពិព័រណ៍ស្នាដៃសិស្ស
- បង្កើតកម្មវិធីប្រកួតប្រជែងវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសឆ្នើម

***យុទ្ធសាស្ត្ររងទី១.៥ ៖ ពិនិត្យឡើងវិញកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងឯកសារពាក់ព័ន្ធ***

- ផលិតសៀវភៅសិក្សាគោលផ្នែកអប់រំបច្ចេកទេស
- រៀបចំ និងកែលម្អកម្មវិធីសិក្សា ផ្នែកអប់រំបច្ចេកទេស
- រៀបចំសៀវភៅណែនាំពីវិធីសាស្ត្របង្រៀនរបស់គ្រូផ្នែកអប់រំបច្ចេកទេស
- ផលិតឯកសារណែនាំ ស្តីពីវិធីសាស្ត្រផលិតសម្ភារឧបទ្ទេសបង្រៀន និងរៀន
- ផលិតឯកសារ ស្តីពីការសិក្សាស្រាវជ្រាវសកម្ម (Action Research)
- បង្កើតស្តង់ដាតាមមុខជំនាញនីមួយៗ
- ផលិតឯកសារណែនាំ ស្តីពីការចុះកម្មសិក្សា
- ផលិតឯកសារណែនាំ ស្តីពីការគ្រប់គ្រងបន្ទប់ពិសោធន៍
- រៀបចំឯកសារណែនាំ ស្តីពីការការពារ និងសុវត្ថិភាពបន្ទប់ពិសោធន៍
- ផលិតឯកសារ ស្តីពីការរៀបចំផែនការអភិវឌ្ឍសាលា និងគ្រប់គ្រងថវិកាប្រកបដោយតម្លាភាព និងគណនេយ្យភាព

- សិក្សាស្តីពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា
- សិក្សាពីផលប៉ះពាល់នៃការអនុវត្តកម្មវិធីសិក្សាចំពោះអតីតសិស្សផលិតឯកសារ សម្រាប់វគ្គបណ្តុះបណ្តាលគ្រូបច្ចេកទេសលើមុខវិជ្ជា PLC ការត្រឡឹង និងការផ្សារ

***យុទ្ធសាស្ត្រទី២ ៖ អនុវត្តស្តង់ដាវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសឱ្យមានប្រសិទ្ធភាព***

***យុទ្ធសាស្ត្ររងទី២.១៖ ផ្សព្វផ្សាយការយល់ដឹង ស្តីពីស្តង់ដាវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស***

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការអនុវត្តស្តង់ដាវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស
- បោះពុម្ពសៀវភៅស្តង់ដាវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស
- ផ្សព្វផ្សាយសៀវភៅស្តង់ដាវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសតាមគេហទំព័រក្រសួងអប់រំ យុវជន និងកីឡា
- បកប្រែស្តង់ដាវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសទៅជាភាសាអង់គ្លេស

***យុទ្ធសាស្ត្រទី៣ ៖ ពង្រឹងភាពជាអ្នកដឹកនាំ សំដៅឱ្យមានស្វ័យភាព និងគណនេយ្យភាពនៅតាមវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស***

***យុទ្ធសាស្ត្ររងទី៣.១ ៖ ធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពលើការងារគ្រប់គ្រង និងភាពជាអ្នកដឹកនាំផ្អែកលើការគ្រប់គ្រងតាមសាលារៀន SBM***

- សិក្សាតម្រូវការសមត្ថភាព (Needs Assessment) របស់គណៈគ្រប់គ្រងសាលា
- សិក្សាពីតម្រូវការជំនាញនៅក្នុងសហគមន៍
- សិក្សាពីតម្រូវការទីផ្សារការងារ

***យុទ្ធសាស្ត្ររងទី៣.២ ៖ពង្រឹងយន្តការអភិវឌ្ឍសាលារៀន និងគ្រប់គ្រងថវិកាប្រកបដោយតម្លាភាព និងគណនេយ្យភាព***

- បើកវគ្គបំប៉នស្តីពីការរៀបចំផែនការអភិវឌ្ឍសាលា និងគ្រប់គ្រងថវិកាប្រកបដោយតម្លាភាព និងគណនេយ្យភាព
- សេចក្តីណែនាំស្តីពីយន្តការនៃការអភិវឌ្ឍសាលារៀននិងគ្រប់គ្រងថវិកាប្រកបដោយតម្លាភាព

***យុទ្ធសាស្ត្ររងទី៣.៣ ៖ កៀរគរថវិកាពីសហគមន៍ សប្បុរសជន និងដៃគូអភិវឌ្ឍនានា***

- បង្កើតវេទិកាភាពជាដៃគូរវាងសាលា សហគមន៍ និងដៃគូអភិវឌ្ឍន៍
- ផ្តល់ការលើកទឹកចិត្ត (លិខិតថ្លែងអំណរគុណ ប័ណ្ណសរសើរ និងគ្រឿងឥស្សរិយយស)
- បង្កើតគម្រោងស្រាវជ្រាវរួមគ្នាជាមួយដៃគូអភិវឌ្ឍ និងវិស័យឯកជន

***យុទ្ធសាស្ត្រទី៤ ៖ ផ្តល់ធាតុចូលដែលមានគុណភាព និងគាំទ្របច្ចេកទេសដល់វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសស្របតាមស្តង់ដា***

***យុទ្ធសាស្ត្ររងទី៤.១ ៖ ពង្រីកអគារសិក្សា និងហេដ្ឋារចនាសម្ព័ន្ធ***

- បន្តសាងសង់អគារសិក្សា រោងជាង បន្ទប់ពិសោធន៍ អន្តេវាសិកដ្ឋានគ្រូ សិស្ស កសិដ្ឋាន បន្ទប់ប្រឹក្សាសាលា និងបណ្ណាល័យស្របតាមស្តង់ដាវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស
- កែលម្អអគារសិក្សា រោងជាង បន្ទប់ពិសោធន៍ អន្តេវាសិកដ្ឋានគ្រូ សិស្ស កសិដ្ឋាន បន្ទប់ប្រឹក្សាសាលា និងបណ្ណាល័យ ដែលមានស្រាប់ឱ្យស្របតាមស្តង់ដាវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស
- បន្តបំពាក់បណ្តាញទឹក ភ្លើង ដើម្បីគាំទ្រសកម្មភាពបង្រៀន និងរៀន

***យុទ្ធសាស្ត្ររងទី៤.២ ៖ លើកកម្ពស់ការបំពាក់សម្ភារបរិក្ខារ សម្រាប់អនុវត្ត***

- បំពាក់សម្ភារប្រតិបត្តិបន្ថែមស្របតាមកម្មវិធីសិក្សា
- បំពាក់សម្ភារប្រតិបត្តិសម្រាប់វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសដែលបានពង្រីកថ្មី
- បំពាក់ប្រព័ន្ធស្រោចស្រពនៅតាមកសិដ្ឋាន

***យុទ្ធសាស្ត្ររងទី៤.៣ ៖ អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនផ្នែកអប់រំបច្ចេកទេស***

- បំប៉នសមត្ថភាពគ្រូបង្រៀន លើការប្រើប្រាស់ និងគ្រប់គ្រងសម្ភារបរិក្ខារផ្នែកអប់រំបច្ចេកទេស
- បំប៉នលើវិធីសាស្ត្របង្រៀន និងគរុកោសល្យដល់គ្រូផ្នែកអប់រំបច្ចេកទេស
- លើកទឹកចិត្តគ្រូបង្រៀនផ្នែកអប់រំបច្ចេកទេស ធ្វើទស្សនកិច្ចសិក្សាក្នុង និងក្រៅប្រទេស
- លើកទឹកចិត្តគ្រូបង្រៀនផ្នែកអប់រំបច្ចេកទេស ចូលរួមសិក្ខាសាលាក្នុង និងក្រៅប្រទេស
- លើកទឹកចិត្តគ្រូបង្រៀនផ្នែកអប់រំបច្ចេកទេស បន្តការសិក្សាឡើងកម្រិតក្នុង និងក្រៅប្រទេស
- លើកទឹកចិត្តគ្រូបង្រៀនផ្នែកអប់រំបច្ចេកទេសទទួលការបណ្តុះបណ្តាលផ្នែកអប់រំបច្ចេកទេសរយៈពេលខ្លី និងមធ្យមក្នុង និងក្រៅប្រទេស
- សិក្សាពីតម្រូវការមុខជំនាញវិជ្ជាជីវៈរបស់គ្រូដែលត្រូវទទួលការបណ្តុះបណ្តាល ដើម្បីអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន

***អាទិភាពទី២ ៖ លើកកម្ពស់ការចូលរៀនប្រកបដោយសមធម៌ និងបរិយាបន្ន***

***យុទ្ធសាស្ត្រទី១ ៖ជំរុញការចុះឈ្មោះចូលរៀននៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស***

- រៀបចំសេចក្តីជូនដំណឹងស្តី ពីការជ្រើសរើសសិស្សចូលរៀនផ្នែកអប់រំបច្ចេកទេស
- ផ្សព្វផ្សាយសេចក្តីជូនដំណឹង ស្តីពីការជ្រើសរើសសិស្សចូលរៀនផ្នែកអប់រំបច្ចេកទេស
- រៀបចំសេចក្តីណែនាំស្តីពីការជ្រើសរើសសិស្សចូលរៀននៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ
- ចូលរួមសហការវេទិកាការអប់រំតម្រង់ទិសវិជ្ជាជីវៈ
- បង្កើតមុខជំនាញសិក្សាសម្បូរបែបស្របតាមតម្រូវការទីផ្សារការងារ
- ចូលរួម និងសម្របសម្រួលការតាំងបង្ហាញសមិទ្ធផលស្នាដៃសិស្ស

***យុទ្ធសាស្ត្រទី២ ៖ កាត់បន្ថយការបោះបង់ការសិក្សានៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស***

*ផ្តល់សេវាប្រឹក្សា នៅតាមវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស*

- បង្កើនប្រាក់អាហារូបករណ៍សិស្សផ្នែកអប់រំបច្ចេកទេស
- សិក្សា និងកម្មសិក្សារបស់សិស្សផ្តល់អាទិភាពក្នុងការស្នាក់នៅអន្តេវាសិកដ្ឋានចំពោះសិស្សមានទីលំនៅដ្ឋានឆ្ងាយ ឬសិស្សងាយរងគ្រោះ
- សម្របសម្រួលក្នុងការស្វែងរកអាហារូបករណ៍សម្រាប់សិស្សរៀនបន្តទាំងក្នុង និងក្រៅប្រទេស
- សម្របសម្រួលក្នុងការធ្វើទស្សនកិច្ច

***យុទ្ធសាស្ត្រទី៣៖ ពង្រឹងការអនុវត្តកម្មវិធីស្ពានចម្លងនៅតាមវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស***

- ចងក្រងតេស្តស្តង់ដា សម្រាប់អ្នកបាត់បង់ឱកាសចូលសិក្សា
- បង្កើតគណៈកម្មការជ្រើសរើស និងវាយតម្លៃ
- ផ្តល់តេស្ត ឬការប្រឡងចូលរៀននៅតាមវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស

## ៦. សូចនាករវំពឹងទុក

- ❖ សិស្សចុះឈ្មោះចូលរៀនផ្នែកអប់រំបច្ចេកទេសនឹងកើនឡើងដល់ ៣០០០នាក់ក្នុងឆ្នាំសិក្សា (២០២២-២០២៣)
- ❖ ចំនួនវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសនឹងកើនឡើងដល់២០នៅឆ្នាំ២០២២-២០២៣
- ❖ ៩០%នៃសិស្សផ្នែកអប់រំបច្ចេកទេសនឹងអាចរកការងារធ្វើ ឬបង្កើតការងារដោយខ្លួនឯងបានត្រឹមឆ្នាំ(២០២២-២០២៣)
- ❖ ប្រហែល៨០%នៃវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសទូទាំងប្រទេសនឹងមានអន្តេវសិកដ្ឋានសិស្ស និងគ្រូ នៅឆ្នាំសិក្សា២០២២-២០២៣។

## ៧. កម្មវិធី និងសកម្មភាព

- ❖ ដើម្បីជំរុញការចុះឈ្មោះចូលរៀនរបស់សិស្សនៅតាមវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស កម្មវិធី និងសកម្មភាពគោលមានដូចខាងក្រោម៖
- ❖ បន្តផ្តល់ថវិកាគាំទ្រប្រចាំឆ្នាំដល់វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស រួមមានថវិកាដំណើរការសាលា (៥០លានរៀនសម្រាប់មួយសាលា) ថវិកាគិតតាមចំនួនសិស្សម្នាក់ (៦០០,០០០រៀនសម្រាប់សិស្សម្នាក់) កម្មសិក្សា (៤០,០០០រៀលសម្រាប់សិស្សម្នាក់) និងទស្សនកិច្ចសិក្សា (២០,០០០រៀលសម្រាប់សិស្សម្នាក់)
- ❖ បន្តបំពាក់សម្ភារប្រតិបត្តិនៅតាមវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសទូទាំងប្រទេស ដើម្បីបម្រើការងាររៀន និងបង្រៀន ដោយទ្រឹស្តីផ្សារភ្ជាប់នឹងការអនុវត្ត
- ❖ បង្កលក្ខណៈងាយស្រួល និងសម្របសម្រួលដល់ភាពជាដៃគូរវាងវិស័យឯកជន និងសាធារណៈ ដើម្បីបញ្ជូនសិស្សចុះកម្មសិក្សា ទស្សនកិច្ចសិក្សា និងងាយស្រួលក្នុងការស្វែងរកការងារធ្វើក្រោយពីប្រឡងជាប់

- ❖ បន្តបណ្តុះបណ្តាល និងលើទឹកចិត្តគ្រូផ្នែកអប់រំបច្ចេកទេសឱ្យអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជំនាញ ដើម្បីផ្ទេរចំណេះដឹងដល់សិស្សប្រកបដោយគុណភាព និងការទាក់ទាញ
- ❖ សម្របសម្រួលក្នុងការស្វែងរកអាហារូបករណ៍ទាំងក្នុង និងក្រៅប្រទេស សម្រាប់សិស្សបានបន្តការសិក្សា
- ❖ រៀបចំការប្រឡងប្រចាំខែ ប្រឡងឆមាស ប្រឡងបញ្ចប់ឆ្នាំ និងប្រឡងសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣
- ❖ ចុះពិនិត្យតាមដានការបង្រៀន និងរៀន ការប្រើប្រាស់សម្ភារប្រតិបត្តិ ប្រឡងឆមាស ប្រឡងបញ្ចប់ និងការអនុវត្តស្តង់ដារវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស
- ❖ ចុះសិក្សាស្រាវជ្រាវតម្រូវការមុខជំនាញថ្មីស្របតាមទីផ្សារការងារ
- ❖ ចុះសិក្សាស្រាវជ្រាវ និងពង្រីកវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស
- ❖ ចុះសិក្សាស្រាវជ្រាវប្លង់គម្រូរោងជាងប្រតិបត្តិតាមមុខវិជ្ជានីមួយៗ
- ❖ ចុះសិក្សាស្រាវជ្រាវគម្រូកសិដ្ឋាន
- ❖ សាងសង់រោងជាងប្រតិបត្តិតាមមុខជំនាញនីមួយៗ
- ❖ សាងសង់កសិដ្ឋានតាមតម្រូវការជំនាញនៅតាមវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស
- ❖ បណ្តុះបណ្តាលគ្រូបច្ចេកទេសលើមុខវិជ្ជា PLC ការក្រឡឹង និងការផ្សារ
- ❖ វគ្គបំប៉នគណៈគ្រប់គ្រង និងគ្រូបច្ចេកទេស ស្តីពីឯកសារសុវត្ថិភាពបន្ទប់ពិសោធន៍
- ❖ វគ្គបំប៉នគណៈគ្រប់គ្រង និងគ្រូបច្ចេកទេស ស្តីពីការគ្រប់គ្រងបន្ទប់ពិសោធន៍
- ❖ សិក្ខាសាលាអភិវឌ្ឍសៀវភៅសិក្សាគោលផ្នែកអប់រំបច្ចេកទេស
- ❖ សិក្ខាសាលាអភិវឌ្ឍកម្មវិធីសិក្សាផ្នែកអប់រំបច្ចេកទេស

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

វិធីសាស្ត្រស្រាវជ្រាវ អ្នកសង្គមវិទ្យាបានឱ្យនិយមន័យថា គឺជាផែនការជាប្រព័ន្ធមួយសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ និងបានគូសបញ្ជាក់ពីភាពខុសគ្នានៃវិធីសាស្ត្រស្រាវជ្រាវបែបបរិមាណវិស័យ និងបែបគុណវិស័យ។ វិធីសាស្ត្របែបគុណវិស័យ គឺមានគោលបំណងសម្រាប់ចាត់ថ្នាក់ លក្ខណៈពិសេសសម្រាប់បង្កើតគម្រូស្ថិតិដើម្បីសាកល្បងសម្មតិកម្ម និងពន្យល់ពីការអង្កេត និងសិក្សាស្រាវជ្រាវ។ បែបគុណវិស័យជាការព័ណ៌នាពេញលេញនៃការសង្កេតរួមទាំងបរិបទ ស្ថានភាពជារួម នៃព្រឹត្តការណ៍ និងកាលៈទេសៈ។

## ៣.១- គម្រោងវិភាគ

ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវខាងលើ និងសម្រេចតាមគោលបំណងនៃការសិក្សាស្រាវជ្រាវ ការសិក្សាស្រាវជ្រាវនេះបានប្រើវិធីសាស្ត្រចម្រុះ គឺវិធីសាស្ត្របែបបរិមាណវិស័យ និងបែបគុណវិស័យ។ បែបបរិមាណវិស័យ បានប្រើប្រាស់កម្រងសំណួរទម្រង់បិទ បែបជ្រើសរើសតាមលំដាប់លំដោយ។ ចំណែកបែបគុណវិស័យ គឺបានប្រើប្រាស់សំណួរបន្ថែមខាងក្រោម កម្រងសំណួរបែបគុណវិស័យ ដែលសួរពីកម្រិតនៃការយល់ឃើញទៅលើស្ថានភាព ទិដ្ឋភាពនៃការដឹកនាំ គ្រប់គ្រង ដែលមានលក្ខណៈជាទម្រង់បើក និងមានភាពបត់បែន។ មូលហេតុនៃការជ្រើសរើស និងប្រើប្រាស់បែបបរិមាណវិស័យនេះ ដើម្បីរកឱ្យឃើញនូវលទ្ធផលជាក់លាក់ អាចគិតជាភាគរយនៃក្រុមនីមួយៗ ប្រៀបធៀបនឹងចំនួនគំណតើជាក់លាក់មួយ **(Gray, 2009)**។ វិធីសាស្ត្រនេះត្រូវមានសូចនាករជាក់លាក់ និងស្តង់ដាដោយគោរពនូវដំណើរការជាក់លាក់ក្នុងការប្រមូលទិន្នន័យ **(Bamberger, 2012)**។ បើយោងតាម **(Merriam, 1998 )** ការសិក្សាស្រាវជ្រាវបែបបរិមាណវិស័យ អ្នកសិក្សាតែងចាប់អារម្មណ៍ និងមានការយល់ដឹង និងចេះវិភាគទិន្នន័យ។ ការសិក្សាស្រាវជ្រាវបែបគុណវិស័យធ្វើឡើងក្នុងគោលបំណងឱ្យយល់ដឹងពីស្ថានភាពមួយដោយផ្តោតការយកចិត្តទុកដាក់លើទិដ្ឋភាពរួមទាំងមូល ព្រមទាំងមានលក្ខណៈស៊ីជម្រៅ លើការយល់ដឹងជាងការវិភាគលើចំនួន និងស្ថិតិនៃទិន្នន័យទាំងនោះ **(Bamberger, 2012 & Ary et Berg,2009 )**។

នៅក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាបានកំណត់ជ្រើសរើសយកវិទ្យាល័យតែមួយគឺវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី ដែលស្ថិតនៅក្នុងភូមិសាលាលេខ៥ ឃុំអូរឫស្សី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ អ្នកសិក្សាបានរៀបចំកម្រងសំណួរសម្រាប់សំភាសន៍គ្រូ នាយក នាយករង ដោយរៀបចំកម្រងសំណួរតាមឯកសារតាមឯកសារនិង

សូចនាករនៃក្របខណ្ឌសមត្ថភាពនាយកអាស៊ីអាគ្នេយ៍ និងសិស្សកម្រងសំណួរកម្រិតនៃភាពពេញចិត្តទៅលើទិដ្ឋភាពរួមនៃការគ្រប់គ្រង និងដឹកនាំ និងការរៀន និងបង្រៀន។ សំភាសន៍នាយក នាយករង ឬនាយិការង គ្រូបង្រៀនមុខវិជ្ជាឯកទេសផ្នែកបច្ចេកទេស និងគ្រូបង្រៀនមុខវិជ្ជាចំណេះទូទៅ ផ្នែកបច្ចេកទេស និងសិស្សផ្នែកអគ្គិសនី ផ្នែកក្បេត្រសាស្រ្ត និងផ្នែកបសុវប្បកម្ម ឆ្នាំទី១ ឆ្នាំទី២ និងឆ្នាំទី៣។

## ៣.២- ការជ្រើសរើសសំណាក

ដើម្បីឆ្លើតតបទៅនឹងទំហំនៃការសិក្សា អ្នកសិក្សាបានកំណត់ជ្រើសរើស ជ្រើសរើសករណីសិក្សានៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី។ ចំពោះការជ្រើសរើសសំណាក អ្នកសិក្សាជ្រើសរើស គណៈគ្រប់គ្រងចំនួន០៤ នាក់ ស្រី០១នាក់ លោកគ្រូ អ្នកគ្រូបង្រៀនជំនាញឯកទេសសរុប១៧នាក់ ស្រី០៧នាក់ លោកគ្រូអ្នកគ្រូបង្រៀនមុខវិទ្យាចំណេះទូទៅចំនួន១០នាក់ ក្នុងនោះស្រី និងសិស្សានុសិស្សផ្នែកបច្ចេកទេស ឆ្នាំទី១ ឆ្នាំទី២ និងឆ្នាំទី៣ សរុបចំនួន ៨៤នាក់។

*តារាងចំនួនសំណាក*

| អ្នកតបសំភាសន៍ | សរុប | ប្រុស | ស្រី | ភាគរយប្រុស | ភាគរយស្រី | %សរុប |
|---|---|---|---|---|---|---|
| គណៈគ្រប់គ្រង | ០៤ | ០៣ | ០១ | ៧៥% | ២៥% | ១០០% |
| គ្រូបង្រៀនឯកទេស | ២៧ | ១៨ | ០៩ | ៦៦.៦៧% | ៣៣.៣៣% | ១០០% |
| សិស្ស | ៨៤ | ៣៣ | ៥១ | ៣៩.២៩% | ៦០.៧១% | ១០០% |
| សរុបភាគសំណាក | ១១៥ | ៥៤ | ៦១ | ៤៦.៩៥% | ៥៣.០៤% | ១០០% |

*មូលហេតុនៃការជ្រើសរើសសំណាក និងទីតាំងនៃការសិក្សាស្រាវជ្រាវ*

ការជ្រើសរើសទីតាំង៖

- ដោយវិទ្យាល័យនេះ ជាវិទ្យាល័យដែលជាព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
- សិក្សារកចំណុចខ្លាំង ចំណុចខ្សោយ បញ្ហាប្រឈម និងដំណោះស្រាយ

ការជ្រើសសំណាកសំណាក៖

- ចង់ដឹងពីកម្រិតនៃការវាយតម្លៃ និងការយល់ឃើញនៃការគ្រប់គ្រង និងដឹកនាំរបស់នាយកតាមរយៈនាយកខ្លួនឯង នាយករង គ្រូបង្រៀន និងសិស្ស។

## ៣.៣- វិធីសាស្រ្តប្រមូលទិន្នន័យ

តាមរយៈលិខិតឧទ្ទេសនាមរបស់ក្រសួងអប់រំ យុវជន និងកីឡា លិខិតសុំការអនុញ្ញាតចុះប្រមូលព័ត៌មានពីវិទ្យាស្ថានជាតិអប់រំ និងដោយមានលិខិតៈនុញ្ញាតពីប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ឆ្នាំង អ្នកសិក្សាបានចុះទៅសិក្សា និងប្រមូលព័ត៌មាននៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ ដោយខ្ញុំបាទជា

អតីតគ្រូបង្រៀននៅវិទ្យាល័យនេះដែរ ម្ល៉ោះហើយខណៈពេលដែលខ្ញុំបានចុះទៅនោះ គឺមានការទទួលស្វាគមន៍យ៉ាងកក់ក្ដៅ ពីសំណាក់ គណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស។ ខ្ញុំបានជួបសិស្សតាមថ្នាក់នីមួយៗ ខណៈពេលម៉ោងចេញលេង ម៉ោងទំនេរ និងជួបពួកគាត់នៅកន្លែងប្រតិបត្តិ និងកសិដ្ឋានជាដើម។ តាមថ្នាក់នីមួយៗ ខ្ញុំបានប្រាប់ទៅសិស្សយ៉ាងច្បាស់ពីគោលបំណងនៃការប្រមូលទិន្នន័យ និងបានសុំជ្រើសរើសការស្ម័គ្រចិត្តពីពួកគាត់ មិនមានការបង្ខិតបង្ខំ។ បន្ទាប់មកខ្ញុំបានចែកជូនកម្រងសំណួរទៅពួកគាត់ និងទុកពេលឱ្យពួកគាត់បំពេញយ៉ាងគ្រប់គ្រាន់ និងពិនិត្យបានត្រឹមត្រូវនូវគ្រប់សំណួរ និងការសាកសួរបន្ថែមខណៈដែលមិនទាន់យល់លើសំណួរណាមួយ។

### ៣.៣.១- ទិន្នន័យបន្ទាប់បន្សំ

ទិន្នន័យបន្ទាប់បន្សំបានប្រមូលតាមរយៈឯកសារបោះពុម្ពនានាដូចជា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រវិស័យអប់រំ (២០១៤-២០១៨) ផែនការយុទ្ធសាស្ត្រការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ(២០១៤-២០១៨) ច្បាប់ស្តីពីការអប់រំ ២០០៨ ឯកសារស្តង់ដាវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ឯកសារក្របខណ្ឌសមត្ថភាពគោលនាយកសាលាអាស៊ីអាគ្នេយ៍ (Seameo Innotech, 2016), របាយការណ៍ដំណាច់ឆ្នាំការងារអប់រំបច្ចេកទេសវិទ្យាល័យដែលបានសិក្សា។ តារាងលទ្ធផលនៃការប្រលងបញ្ចប់ថ្នាក់ឆ្នាំទី១ ឆ្នាំទី២ និងការប្រលងសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ សម័យប្រលងថ្ងៃ០៩ សីហា ឆ្នាំ២០១៨ មណ្ឌលវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី សម្រាប់ឆ្នាំសិក្សា (២០១៧-២០១៨)

### ៣.៣.២- ទិន្នន័យចម្បង

ដើម្បីទទួលបានព័ត៌មានមួយជាក់លាក់ អ្នកសិក្សាជាចាំបាច់បានរៀបចំជាកម្រងសំណួរ ដើម្បីចែកជូនដល់គណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូបង្រៀមមុខវិជ្ជាជំនាញ លោកគ្រូអ្នកគ្រូបង្រៀនមុខវិជ្ជាចំណេះទូទៅ និងសិស្សានុសិស្សផ្នែកបច្ចេកទេសដែលកំពុងសិក្សាថ្នាក់ឆ្នាំទី១ ឆ្នាំទី២ និងឆ្នាំទី៣ នៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសក្នុងឆ្នាំសិក្សា(២០១៧-២០១៨)។

## ៣.៤- ឧបករណ៍ប្រមូលទិន្នន័យ

នៅក្នុងការសំភាសន៍ និងបំពេញកម្រងសំណួរ ដែលមានកំណត់ពីវត្ថុបំណងយ៉ាងច្បាស់លាស់តាមរយៈកម្រងសំណួរចំនួន០៣ប្រភេទ គឺប្រភេទទី១ កម្រងសំណួរសម្រាប់សំភាសន៍ជាមួយគណៈគ្រប់គ្រង(នាយក និងនាយករង ឬនាយិការង) ប្រភេទទី២ កម្រងសំណួរសម្រាបសំភាសន៍ជាមួយគ្រូបង្រៀន និងប្រភេទទី៣ កម្រងសំណួរសម្រាប់សំភាសន៍ជាមួយសិស្ស។ នៅក្នុងកម្រងសំណួរនីមួយៗបានបែងចែកេជាផ្នែកនីមួយៗយ៉ាងត្រឹមត្រូវ។ ហើយកម្រិតនៃការវាយតម្លៃគឺកំណត់តាម (Likert Type Scal,2006) ដូចជា៖

***Likelihood***

(1) = Exstremely Unlikely = មិនពេញចិតទាល់តែសោះ

(2) = Unlikely = មិនពេញចិត្ត

(3) = Neutral = ធម្មតា ឬកណ្តាល

(4) = Likely = ពេញចិត្ត

(5) = Extjremely Likely = ពេញចិត្តខ្លាំងណាស់

***Level of agreement***

(1) = Strongly disagree = មិនឯកភាពទាល់តែសោះ

(2) = Disagree = មិនឯកភាព

(3) = Neither agree or disagree = ឯកភាពខ្លះ មិនឯកភាពខ្លះ

(4) = Agree = ឯកភាព

(5) = Strongly agree = ឯកភាពខ្លាំងណាស់

***ការបែងចែកជាចន្លោះភាគរយនៃកម្រិតនៃការអនុវត្ត***

(1) = កម្រិតអនុវត្តបានចន្លោះពី 0% - 20%

(2) = កម្រិតអនុវត្តបានចន្លោះពី 21% - 40%

(3) = កម្រិតអនុវត្តបានចន្លោះពី 41% - 60%

(4) = កម្រិតអនុវត្តបានចន្លោះពី 61% - 80%

(5) = កម្រិតអនុវត្តបានចន្លោះពី 81% - 100%

## ៣.៥- ឧបករណ៍ស្ថិតិ

ដើម្បីសម្របសម្រួលដល់ដំណើរការនៃការសិក្សាស្រាវជ្រាវ ឱ្យមានដំណើរការល្អ ក្នុងការបង្ហាញ និងការវិភាគ ការរំពឹងទុក និងធ្វើឱ្យការសន្និដ្ឋានមានអំណះអំណាងត្រឹមត្រូវ និងច្បាស់លាស់ អ្នកសិក្សាបានប្រើរូបមន្តស្ថិតិមួយចំនួន តាម **Descriptive Statistics of Frequencies** ការគណនាតម្លៃមធ្យម គំលាតស្តង់ដាជាដើម។

## ៣.៦- ដំណើរការក្នុងការប្រមូលទិន្នន័យ

ការសិក្សានេះបានធ្វើឡើងបន្ទាប់ពីឧបករណ៍ស្រាវជ្រាវនានាត្រូវបានកសាងរួចរាល់ ដោយពេលទទួលបានការយល់អនុម័ត និងយល់ព្រមពីសាស្ត្រាចារ្យដឹកនាំ សាស្ត្រាចារ្យដឹកនាំរង និងការពិគ្រោះយោបល់ពីបណ្តាអ្នកសិក្សាមុនៗ ដោយអនុលោមតាមសូចនាករនៃក្របខណ្ឌស្តង់ដាសមត្ថភាពគោលនាយកសាលាអាស៊ីអាគ្នេយ៍ និងមានលិខិតឧទ្ទេសនាមរបស់ក្រសួងអប់រំ យុវជន និងកីឡា លិខិតអនុញ្ញាតរបស់វិទ្យាស្ថានជាតិអប់រំ និងលិខិតស្នើសុំចុះប្រមូលទិន្នន័យរបស់អ្នកសិក្សាបានស្នើទៅមន្ទីរអប់រំ យុវជន និងកីឡាសាមី ព្រំទាំងមានការយល់ព្រមពីគណៈគ្រប់គ្រងដែលត្រូវចុះប្រមូលទិន្នន័យ។

ត្រូវបង្ហាញពីគោលបំណង និងព័ត៌មានលម្អិតនៃការសិក្សាស្រាវជ្រាវដល់នាយកសាលាដ៏ម្បីឱ្យមានការសម្របសម្រួល និងការរៀបចំផែនការក្នុងការប្រមូលទិន្នន័យ។ បន្ទាប់មកគឺការចុះប្រមូលទិន្នន័យតាមគោលដៅដែលបានកំណត់។

## ៣.៧- វិធីសាស្ត្រវិភាគទិន្នន័យ

ទិន្នន័យបែបបរិមាណវិស័យ ប្រើ **Descriptive Statistics of Frequencies** នៅក្នុងកម្រងសំណួរផ្នែកខាងក្រោមមានបន្ថែមនូវសំណួរបែបគុណវិស័យ ដើម្បីគាំទ្រឱ្យទិន្នន័យបែបបរិមាណវិស័យ។ រាល់ចម្លើយនៃសំណាកត្រូវបានកត់ត្រា និងរៀបចំនៅក្នុងកម្មវិធី **SPSS** ជាការងាយស្រួលក្នុងការរាប់ចំនួន វិភាគជាក្រុម និងផ្នែកនៃសមត្ថភាពគោលចំនួន៥ក្រុមផ្សេងគ្នានៃ ស្តង់ដាក្របខណ្ឌសមត្ថភាពគោលនាយកអាស៊ីអាគ្នេយ៍ និងវិភាគលើតម្លៃមធ្យម **(Mean)** និងតម្លៃគម្លាតស្តង់ដា **(SD)** ។ ជាបន្ទាប់ការរៀបចំតារាងក្រុងកម្មវិធី **Microsoft Excel 2013** ដើម្បីរៀបចំជាក្រាបផ្សេងៗ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការអាន ជាសោភ័ណសម្រាប់ការចាប់អារម្មណ៍ ពិសេសគឺងាយយល់ពីលទ្ធផលនៃការសិក្សាស្រាវជ្រាវ។ ក្នុងការវិភាគទិន្នន័យនេះអ្នកសិក្សា៖

- ❖ ប្រើតាមកម្មវិធី **SPSS**
  - សម្រាប់រកមធ្យម ( **MEAN** ) និងគំលាតស្តង់ដា ( **SD** )
  - សម្រាប់រកភាគរយ (%) និងប្រេកង់ (Freq.)
- ❖ និងប្រើកម្មវិធី **Ms. Excel**
  - សម្រាប់សង់ក្រាហ្វិក
  - សម្រាប់សង់តារាង
  - សម្រាប់ផ្ទុំទិន្នន័យបញ្ចូលគ្នាក្នុងការវិភាគទិន្នន័យនេះប្រើតាមកម្មវិធី **SPSS**

**(DESCRIPTIVE STATISTIC ANALYSIS)**
**OXFORT and BURRY- Stock (1995)**

| | | | |
|---|---|---|---|
| តម្លៃ **Mean** | ស្មើ ឬធំជាតិ | **3.5** | លទ្ធផល ខ្ពស់ |
| តម្លៃ **Mean** | ចាប់ពី | **2.5 to 3.49** | លទ្ធផល មធ្យម |
| តម្លៃ **Mean** | តូចជាង | **2.5** | លទ្ធផល ទាប |

# ជំពូកទី៤
# លទ្ធផល
# និងការពិភាក្សា

# ជំពូកទី៤
# លទ្ធផល និងការពិភាក្សាបកស្រាយ

ក្នុងការវិភាគនេះ យើងបានបែងចែកទិន្នន័យទៅតាមប្រភេទ និងក្រុមនីមួយៗ ហៀយដែលជ្រើសយកតែទិន្នន័យដែលចាំបាច់ប៉ុណ្ណោះយកមកវិភាគ។ ចំពោះកម្រងសំណួរដែលបានរៀបចំ អ្នកសិក្សាបានចែកជូនទៅអ្នកឆ្លើយតបចំនួន ១៣១ច្បាប់ ហើយប្រមូលបានមកវិញតែចំនួន ១១៥ច្បាប់មកវិភាគ។ ចំពោះកម្រងសំណួរដែលជាកត្តាមានឥទ្ធិពលលើប្រធានបទ អ្នកសិក្សាបានរៀបចំជាប្រាំកម្រិត គឺ កម្រិតទី១ អនុវត្តបានពី ០-២០% នៃសូចនាករដែលបានកំណត់ កម្រិតទី២ អនុវត្តបានពី ២១-៤០% នៃសូចនាករដែលបានកំណត់ កម្រិតទី៣ អនុវត្តបានពី ៤១-៦០% នៃសូចនាករដែលបានកំណត់ កម្រិតទី៤ អនុវត្តបានពី ៦១-៨០% នៃសូចនាករដែលបានកំណត់ និងកម្រិតទី៥ អនុវត្តបានពី ៨១-១០០% នៃសូចនាករដែលបានកំណត់ **(Likert type Scal)** ។ រីឯការវាយតម្លៃទៅលើភាពពេញចិត្តរបស់សិស្ស អ្នកសិក្សាបានចែកជាប្រាំកម្រិតដែរគឺ កម្រិតទី១ មិនពេញចិត្តសោះ កម្រិតទី២ មិនពេញចិត្ត កម្រិតទី៣ ពេញចិត្តតិចតួច កម្រិតទី៤ពេញចិត្ត និងកម្រិតទី៥ ពេញចិត្តខ្លាំងណាស់។

ក្រោយពីផលិតកម្រងសំណួរទាំងបីប្រភេទរួច អ្នកសិក្សាស្រាវជ្រាវបានជួបជាមួយក្រុមគោលដៅ ដើម្បីប្រមូលទិន្នន័យ ហើយអ្នកសិក្សាស្រាវជ្រាវ បានយកទិន្នន័យទាំងនោះមកវិភាគ និងសំយោគចេញជាលទ្ធផលដូចខាងក្រោម៖

## ៤.១- វិភាគព័ត៌មានទូទៅ

### *៤.១.១- ភេទ និងមុខរបរ*

**តារាងទី១៖ បំណែងចែកប្រភេទមុខរបរ និងភេទរបស់អ្នកបំពេញកម្រងសំណួរ**

| មុខរបរ | សរុប | ប្រុស | ស្រី | ភាគរយប្រុស | ភាគរយស្រី | %សរុប |
|---|---|---|---|---|---|---|
| គណៈគ្រប់គ្រង | ០៤ | ០៣ | ០១ | ៧៥% | ២៥% | ១០០% |
| គ្រូបង្រៀន | ២៧ | ១៨ | ០៩ | ៦៦.៦៧% | ៣៣.៣៣% | ១០០% |
| សិស្ស | ៨៤ | ៣៣ | ៥១ | ៣៩.២៩% | ៦០.៧១% | ១០០% |
| សរុបភាគសំណាក | ១១៥ | ៥៤ | ៦១ | ៤៦.៩៥% | ៥៣.០៤% | ១០០% |

**បំណកស្រាយ៖**

តាមតារាងទី១ បានបង្ហាញថា អ្នកដែលបានបំពេញកម្រងសំណួរស្រាវជ្រាវ និងសំភាសន៍ទាំងអស់១១៥នាក់ ក្នុងនោះសិស្ស ៨៤នាក់ ស្រីចំនួន គ្រូបង្រៀនមុខវិជ្ជាបច្ចេកទេសចំនួន១៧នាក់ ស្រី គ្រូបង្រៀនមុខវិទ្យាទូទៅ១០នាក់ ស្រី និងគណៈគ្រប់គ្រង ០៤នាក់ ស្រី

### ៤.១.២- ស្ថានភាពគ្រួសារ

**តារាងទី២៖ បង្ហាញពីស្ថានភាពគ្រួសារ ( មិនវិភាគលើសិស្ស)**

| ស្ថានភាពគ្រួសារ | គណៈគ្រប់គ្រង | គ្រូបង្រៀន | % គណៈគ្រប់គ្រង | %គ្រូបង្រៀន |
|---|---|---|---|---|
| **នៅលីវ** | ០០ | ០៨ | ០០.០០% | ២៩.៦៣% |
| **រៀបការ** | ០៤ | ១៩ | ១០០% | ៧០.៣៧% |
| **មេម៉ាយ ឬពោះម៉ាយ** | ០០ | ០០ | ០០.០០% | ០០.០០% |
| **សរុបភាគសំណាក** | ០៤ | ២៧ | ១០០% | ១០០% |

***បំណកស្រាយ៖***

តារាងទី២ បង្ហាញថាក្នុងចំណោមអ្នកតបសំភាសន៍ ចំនួន ៣១នាក់ ក្នុងនៅអ្នកនៅលីវ ចំនួន ០៨នាក់ គិតជាភាគរយ ២៩.៦៣% ។ អ្នករៀបការរួច ២៣នាក់ គិតជាភាគរយ ៧០.៣៧%។

### ៤.១.៣- ប្រាក់ចំណូល

**តារាងទី៣៖ បង្ហាញពីប្រាក់ចំណូល ( មិនវិភាគលើសិស្ស )**

| ប្រាក់ចំណូលប្រចាំខែ | គណៈគ្រប់គ្រង | គ្រូបង្រៀន | %គណៈ គ្រប់គ្រង | %គ្រូបង្រៀន |
|---|---|---|---|---|
| ក្រោម៣០០ដុល្លារ | ០១ | ០៦ | ៣៣.៣៣% | ២២.២៣% |
| ពី៣០០ ទៅ៤០០ដុល្លារ | ០១ | ១៩ | ៣៣.៣៣% | ៧០.៣៧% |
| ពី៤០០ ទៅ៥០០ដុល្លារ | ០១ | ០២ | ៣៣.៣៣% | ០៧.៤០% |
| ពី៥០០ ទៅ៦០០ដុល្លារ | ០០ | ០០ | 00.00% | ០០.០០% |
| ច្រើនជាង៦០០ដុល្លារ | ០០ | ០០ | 00.00% | ០០.០០% |
| **សរុបភាគសំណាក** | ០៣ | ២៧ | ១០០% | ១០០% |

***បំណកស្រាយ៖***

តារាងទី៣ បង្ហាញថាក្នុងចំណោមអ្នកតបសំភាសន៍ជាគ្រូបង្រៀន ចំនួន ២៧នាក់ ក្នុងនោះអ្នកដែលទទួលបានប្រាក់ខែក្រោម៣០០$ មានចំនួន ០៦នាក់ គិតជាភាគរយ ២២.២៣% ។ អ្នកដែលទទួលបានប្រាក់ខែចាប់ពី៣០០$ទៅ៤០០$ មានចំនួន ១៩នាក់ គិតជាភាគរយ ៧០.៣៧%។ អ្នកដែលទទួលបានប្រាក់ខែចាប់ពី៤០០$ទៅ៥០០$ មានចំនួន ០២នាក់ គិតជាភាគរយ ៧.៤០%។

ក្នុងចំណោមអ្នកតបសំភាសន៍ជាគណៈគ្រប់គ្រង ចំនួន០៣នាក់ ក្នុងនោះអ្នកដែលទទួលបានប្រាក់ខែក្រោម៣០០$ មានចំនួន ០១នាក់ គិតជាភាគរយ ៣៣.៣៣%។ អ្នកដែលទទួលបានប្រាក់ខែចាប់ពី៣០០$ ទៅ៤០០$ មានចំនួន ០១នាក់ គិតជាភាគរយ ៣៣.៣៣%។ អ្នកដែលទទួលបានប្រាក់ខែចាប់ពី៤០០$ ទៅ៥០០$ មានចំនួន ០១នាក់ គិតជាភាគរយ ៣៣.៣៣%។

### ៤.១.៤- ការអប់រំ

**តារាងទី៤៖ បង្ហាញពីការអប់រំ ( មិនវិភាគលើសិស្ស )**

| កម្រិតវប្បធម៌ | គណៈគ្រប់គ្រង | គ្រូបង្រៀន | %គណៈគ្រប់គ្រង | %គ្រូបង្រៀន |
|---|---|---|---|---|
| មធ្យមសិក្សាទុតិយភូមិ | ០១ | ០០ | ២៥.០០% | ០០.០០% |
| បរិញ្ញាបត្ររង | ០០ | ០៤ | ០០.០០% | ១៤.៨១% |
| បរិញ្ញាបត្រ | ០២ | ២០ | ៥០.០០% | ៧៤.០៨% |
| បរិញ្ញាបត្រជាន់ខ្ពស់ | ០១ | ០៣ | ២៥.០០% | ១១.១១% |
| **សរុបភាគសំណាក** | ០៤ | ២៧ | ១០០% | ១០០% |

***បំណកស្រាយ៖***

តារាងទី៤ បង្ហាញថាក្នុងចំណោមអ្នកតបសំភាសន៍ជាគ្រូបង្រៀន ចំនួន ២៧នាក់ ក្នុងនោះអ្នកដែលមានសញ្ញាបត្រត្រឹមកម្រិតបរិញ្ញាបត្ររង មានចំនួន ០៤នាក់ គិតជាភាគរយ ១៤.៨១% ។ អ្នកដែលមានសញ្ញាបត្រត្រឹមកម្រិតបរិញ្ញាបត្រ មានចំនួន ២០នាក់ គិតជាភាគរយ ៧៤.០៨% ។ អ្នកដែលមានសញ្ញាបត្រត្រឹមកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ មានចំនួន ០៣នាក់ គិតជាភាគរយ ១១.១១% ។

ក្នុងចំណោមអ្នកតបសំភាសន៍ជាគណៈគ្រប់គ្រង មានចំនួន ០៤នាក់ ក្នុងនោះអ្នកដែលមានសញ្ញាបត្រត្រឹមកម្រិតមធ្យមសិក្សាទុតិយភូមិ មានចំនួន ០១នាក់ គិតជាភាគរយ ២៥.០០% ។ អ្នកដែលមានសញ្ញាបត្រត្រឹមកម្រិតបរិញ្ញាបត្រ មានចំនួន ០២នាក់ គិតជាភាគរយ ៥០.០០% ។ អ្នកដែលមានសញ្ញាបត្រត្រឹមកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ មានចំនួន ០១នាក់ គិតជាភាគរយ ២៥.០០% ។

**តារាងទី៥៖ បង្ហាញពីរយៈពេលបម្រើការងារ ( មិនវិភាគលើសិស្ស )**

| រយៈពេលបម្រើការងារ | គណៈគ្រប់គ្រង | គ្រូបង្រៀន | %គណៈគ្រប់គ្រង | %គ្រូបង្រៀន | %សរុប |
|---|---|---|---|---|---|
| តិចជាង៣ឆ្នាំ | ០១ | ០៨ | ២៥% | ២៩.៦៣% | |
| ពី៣ឆ្នាំ- ៥ឆ្នាំ | ០១ | ១១ | ២៥% | ៤០.៧៤% | |
| ពី៥ឆ្នាំ- ១០ឆ្នាំ | ០១ | ០៥ | ២៥% | ១៨.៥២% | |
| ពី១០ឆ្នាំ- ១៥ឆ្នាំ | ០១ | ០១ | ២៥% | ០៣.៧០% | |
| ច្រើនជាង១៥ឆ្នាំ | ០០ | ០២ | ០០% | ០៧.៤១% | |
| **សរុបភាគសំណាក** | ០៤ | ២៧ | ១០០% | ១០០% | |

តារាងទី៥ បង្ហាញថាក្នុងចំណោមអ្នកតបសំភាសន៍ជាគ្រូបង្រៀន ចំនួន ២៧នាក់ ក្នុងនោះអ្នកដែលមាន រយៈពេលបម្រើការងារតិចជាង៣ឆ្នាំ មានចំនួន ០៨នាក់ គិតជាភាគរយ ២៩.៦៣% ។ អ្នក

ដែលមានរយៈពេលបម្រើការងារចន្លោះពី៣ឆ្នាំ ទៅ៥ឆ្នាំ មានចំនួន ១១នាក់ គិតជាភាគរយ ៤០.៧៤% ។ អ្នកដែលមានរយៈពេលបម្រើការងារចន្លោះពី៥ឆ្នាំ ទៅ១០ឆ្នាំមានចំនួន ០៥នាក់ គិតជាភាគរយ ១៨.៥២% ។ អ្នកដែលមានរយៈពេលបម្រើការងារចន្លោះពី១០ឆ្នាំ ទៅ១៥ឆ្នាំមានចំនួន ០១នាក់ គិតជាភាគរយ ០៣.៧០% ។

ក្នុងចំណោមអ្នកតបសំភាសន៍ជាគណៈគ្រប់គ្រង មានចំនួន ០៤នាក់ ក្នុងនោះអ្នកដែលមានសញ្ញាបត្រត្រឹមកម្រិតមធ្យមសិក្សាទុតិយភូមិ មានចំនួន ០១នាក់ គិតជាភាគរយ ២៥.00% ។ អ្នកដែលមានសញ្ញាបត្រត្រឹមកម្រិតបរិញ្ញាបត្រ មានចំនួន ០២នាក់ គិតជាភាគរយ ៥0.00% ។ អ្នកដែលមានសញ្ញាបត្រត្រឹមកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ មានចំនួន ០១នាក់ គិតជាភាគរយ ២៥.00% ។

## ៤.២- វិភាគលើការគ្រប់គ្រង និងដឹកនាំរបស់នាយកសាលា តាមក្របខណ្ឌសមត្ថភាពគោលនាយកសាលាអាស៊ីអាគ្នេយ៍

### *៤.២.១- គំនិតជាយុទ្ធសាស្ត្រ និងនវានុវត្តន៍*

បើផ្អែកតាមសៀវភៅមគ្គុទ្ទេសនាយកសាលារៀននៅអាស៊ីអាគ្នេយ៍ **SEMEO INNOTECH, 2016** បានបញ្ជាក់ថានាយកសាលារៀនត្រូវតែប្រកបដោយសមត្ថភាពគោលចំនួន៥ ដោយក្នុងនោះរួមមាន គំនិតជាយុទ្ធសាស្ត្រ និងនវានុវត្តផងដែរ។ គណៈគ្រប់គ្រងសាលាគឺជាអ្នកកាច់ចង្កូត ដឹកនាំការអនុវត្ត ការងារដើម្បីឱ្យសម្រាចបានតាមចក្ខុវិស័យ និងបេសកកម្មរបស់សាលា ដែលទាមទារឱ្យគណៈគ្រប់គ្រង គ្រប់រូបត្រូវមានទស្សនវិស័យប្រមើលមើលវែងឆ្ងាយ និងគោលការអនុវត្តច្បាស់លាស់តាមច្បាប់កំណត់ និងប្រកបដោយភាពប៊ិនប្រសប់ក្នុងការដឹកនាំ និងដោះស្រាយបញ្ហាផ្សេងៗសំដៅទៅរកការសម្រេចបាននូវគោលដៅអប់រំ។




***បំណកស្រាយ៖***

តាមរយៈក្រាហ្វិកខាងនើនេះយើងអាចបកស្រាយបានថា សកម្មភាពការងាររបស់គណៈគ្រប់គ្រងក្នុងការដឹកនាំការងារសាលាប្រកបដោយយុទ្ធសាស្ត្រ និងនវានុវត្តន៍គឺសម្រេចបានក្នុងកម្រិតមួយខ្ពស់(តម្លៃមធ្យមលើសពី 3.50) ដែលក្នុងនោះសកម្មភាពការងាររបស់គណៈគ្រប់គ្រងក្នុងការកសាងផែនការអនុវត្ត ផ្សេងៗរបស់សាលាមានភាពល្អប្រសើរ ដែលអាចឆ្លើយតបទៅនឹងគោលនយោបាយថ្មីរបស់ក្រសួង ក្នុងការធ្វើកំណែទម្រង់គុណភាពអប់រំទាំងចំណេះទូទៅ និងផ្នែកបច្ចេកទេស។

តាមរយៈក្រាហ្វិកនេះផងដែរ យើងក៏អាចសន្និដ្ឋានបានថា ការដឹកនាំរបស់គណៈគ្រប់គ្រងសាលាមានភាពរលូន ទៅបានក៏អាស្រ័យដោយមានការចូលរួមសហការណ៍ពីបុគ្គលិកក្រោយឱវាទ ដែលគាំទ្រ និងជឿទុកចិត្តដល់ការសម្រេចចិត្តផ្សេងរបស់នាយក ដោយឈរលើឧត្តមប្រយោជន៍រួមជាធំ។

### *៤.២.២- ភាពជាអ្នកដឹកនាំ និងគ្រប់គ្រង*

ក្នុងនាមជាអ្នកដឹកនាំ ត្រូវប្រកបដោយសក្តានុពល និងគុណវុឌ្ឍិគ្រប់គ្រាន់ទាំងផ្នែកបំណិនទន់ និងផ្នែកបំណិនរឹង។ ភាពជាអ្នកដឹកនាំ ត្រូវបានអភិវឌ្ឍជាលំដាប់តាមរយៈបទពិសោធន៍ការងារ ការប្រាស្រ័យទាក់ទង និងការសិក្សាស្វែងយល់ផ្សេងៗពីអ្នកនៅជុំវិញខ្លួន។ ដើម្បីឱ្យក្លាយខ្លួនទៅជាអ្នកដឹកនាំនិងគ្រប់គ្រងសាលាមួយបានល្អ នាយកសាលានោះត្រូវមាន សមត្ថភាពនៃការគ្រប់គ្រងធនធាន និងប្រព័ន្ធសាលារៀន គ្រប់គ្រងការបំពេញការងាររបស់បុគ្គលិក និងគ្រប់គ្រងកម្មវិធីរបស់បុគ្គលិក និងការគ្រប់ គ្រងកម្មវិធីនិងគម្រោងនានារបស់សាលារៀន ប្រកបដោយ និរន្តរភាពនិងប្រសិទ្ធភាពខ្ពស់។




### *បំណកស្រាយ៖*

តាមរយៈទិន្នន័យដែលបានបង្ហាញនៅក្នុងក្រាហ្វិកខាងលើនេះ បានបង្ហាញថាការអនុវត្តការងារក្នុងភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់នាយកសាលា មានភាពល្អប្រសើរ(តម្លៃមធ្យម 3.83) ដោយក្នុងនោះរួមមាន ការគ្រប់គ្រងធនធានមនុស្សក្នុងអង្គភាពមានរលូននឹងត្រឹមត្រូវតាមនិយាម។

ការប្រើប្រាស់និងគ្រប់គ្រងធនធានហិរញ្ញវត្ថុ ក៏មានភាពសមស្របតាមក្របខណ្ឌគតិយុត្តិនិងមានតម្លាភាព ការគ្រប់គ្រង់ប្រព័ន្ធបរិស្ថានសិក្សា ការគ្រប់គ្រប់លើកការបំពេញការងាររបស់បុគ្គលិកប្រកប ដោយភាពឆ្លើយតបនឹងតម្រូវការផ្សេងៗ ដូចជាការពង្រឹងគុណវុឌ្ឍិរបស់គ្រូបង្រៀនជាដើម គឺ

នាយកអនុវត្តបានក្នុងកម្រិតមួយខ្ពស់ ដែលជាផ្នែកមួយនៃការគ្រប់គ្រងដឹកនាំអង្គភាព ដើម្បីទទួលបានជោគជ័យ សំដៅលើកកម្ពស់ប្រសិទ្ធភាពអប់រំផ្ទៃក្នុងដែលជាគោលបំណងចម្បង មុននឹងឈានទៅសម្រេចបាននូវលទ្ធផលសិក្សារបស់សិស្សតបតាមតម្រូវការទីផ្សារការងារលើផ្នែកបច្ចេកទេស។

### ៤.២.៣- ភាពជាអ្នកដឹកនាំការបង្រៀន និងរៀន

ជាសមត្ថភាពក្នុងការដឹកនាំ អនុវត្តនិងការកែលម្អទៅលើកម្មវិធីសិក្សា បង្កើតបរិស្ថានសិក្សាតាមបែបសិស្សមជ្ឈមណ្ឌល អធិការ និងវាយតម្លៃលើការបំពេញភារកិច្ចរបស់គ្រូបង្រៀន ក៏ដូចជាផ្តល់លទ្ធផលអំពីផែនការសិក្សា។ នាយកសាលារៀនជាប្រតិភូអចិន្ត្រៃយ៍របស់ក្រសួងអប់រំ យុវជន និងកីឡាប្រចាំគ្រឹះស្ថានសិក្សាមួយៗ។ គាត់ជាអ្នកទាក់ទងការងាររវាងសាលារៀន និងថ្នាក់លើ។ នាយកសាលាជាអ្នកឃ្លាំមើល និងជាអ្នកអនុវត្តបទបញ្ជាសិក្សា និងអត្ថបទផ្លូវការទាំងឡាយ។ នាយកសាលារៀនដឹកនាំ គ្រប់គ្រង សកម្មភាពក្នុងសាលារៀន និងធានាឱ្យបាននូវប្រសិទ្ធភាព តាមគោលដៅអប់រំដែលបានគ្រោងទុក។ នាយកសាលារៀនទទួលខុសត្រូវទាំងស្រុង ចំពោះសាលារៀន និងថ្នាក់លើនូវរាល់អ្វីដែលកើត មានឡើងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។




តាមរយៈទិន្នន័យដែលបង្ហាញក្នុងក្រាហ្វិកខាងលើនេះ យើងអាចបកស្រាយបានថា គណៈគ្រប់គ្រងសាលារៀន បានអនុវត្តការងារ ក្នុងភាពជាអ្នកគ្រប់គ្រង ដឹកនាំការបង្រៀននិងរៀនបានក្នុងកម្រិតខ្ពស់ (តម្លៃមធ្យម 3.92) នេះបង្ហាញឱ្យឃើញថាការអនុវត្តការងារបង្រៀនរបស់គ្រូ និងការសិក្សារៀនសូត្ររបស់សិស្សានុសិស្សគឺត្រូវបានគណៈគ្រប់គ្រងយកចិត្តទុកដាក់ តាមដានពីការវិវឌ្ឍ និងជួយសម្របសម្រួលនូវរាល់បញ្ហាប្រឈមផ្សេងៗ។ តាមរយៈក្រាហ្វិកនេះ ការរៀបចំកម្មវិធីបណ្តុះបណ្តាល

ការរៀបចំក្រុមបច្ចេកទេស ការកសាងសមត្ថភាពវិជ្ជាជីវៈរបស់គ្រូបង្រៀន ការតាមដានវាយតម្លៃកែលម្អការបង្រៀន និងការលើកម្ពស់ស្មារតីការងារក្រុម គឺអនុវត្តបានខ្ពស់ដែលជាហេតុធ្វើឱ្យ ការដឹកនាំលើការបង្រៀន និងរៀនរបស់នាយកទទួលបានលទ្ធផលល្អ សមស្របទៅនឹងកំណែទម្រង់ស៊ីជម្រៅរបស់ក្រសួងដែលបានដាក់ចេញ។

### *៤.២.៤- ឧត្តមភាពបុគ្គល*

ជាសមត្ថភាពគ្រប់គ្រងលើប្រសិទ្ធភាពបុគ្គល ទៅលើសកម្មភាពឱ្យ អស់ពីសមត្ថភាព និងលទ្ធភាពដែលអាចធ្វើទៅបាន និងបន្តលើការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាដើម។ នាយកសាលារៀន ត្រូវតែជាបុគ្គលដែលមានចំណេះដឹងជ្រៅជ្រះ មានបទពិសោធន៍គ្រប់គ្រាន់ មានបំណិនល្អក្នុងការដោះស្រាយបញ្ហាផ្សេងៗ មានទំនាក់ទំនងល្អជាមួយបុគ្គលិក សិស្សានុសិស្ស មាតាបិតាសិស្ស និងសហគមន៍ ជាពិសេសជាមួយនឹងដៃគូអភិវឌ្ឍ ដើម្បីកៀគរកជំនួយផ្សេងៗមកកសាងអភិវឌ្ឍសាលារៀន។ សេចក្តីថ្លៃថ្នូរ ភាពហ្មត់ចត់លើការងារ និងមានភាពប៉ិនប្រសប់ក្នុងការដឹកនាំបញ្ញាវន្តក្នុងអង្គភាពរបស់ខ្លួនឱ្យបំពេញការងារប្រកបដោយស្មារតីមនសិការ និងមានទំនួលខុសត្រូវ គឺជាឧត្តមភាពមួយដែលនាយកសាលាចាំបាច់ត្រូវតែមាន។




យោងតាមក្រាហ្វិកដែលបានបង្ហាញខាងលើនេះ យើងឃើញថាលក្ខណៈសម្បត្តិក្នុងការដឹកនាំរបស់នាយកសាលាដែលមានបង្កប់ នូវឧត្តមភាពបុគ្គលទៅលើការងារគឺមានភាពល្អប្រសើរក្នុងកម្រិតខ្ពស់ (តម្លៃមធ្យម 4.03) ដែលជាមូលហេតុមួយនាំឱ្យការសម្រេចបាននូវប្រសិទ្ធភាព ប្រសិទ្ធផលនៃផែនការការងារបានទទួលលទ្ធផលល្អតាមចក្ខុវិស័យ។ ការដឹកនាំមានលក្ខណៈជាគំរូគេក្នុងអង្គភាព

ការបំពេញការងារ និងបែងចែកការងារមានគណនេយ្យភាព ការលើកម្ពស់ការរស់នៅក្នុងសង្គម មោទនភាពលើវិជ្ជជីវៈ ការបង្ហាញជាសាធារណៈនូវលទ្ធផលនៃការគ្រប់គ្រងការងារដោយឥតលាក់លៀម ការកំណត់ការងារជាអទិភាព ការសម្រេចចិត្តប្រកបដោយទំនុកចិត្តខ្ពស់ លើកម្ពស់ការសិក្សាពេញមួយជីវិត ការចូលរួមក្នុងការគាំត្រទស្សនៈវិស័យអប់រំក្នុងតំបន់ និងការគាំទ្រគោលនយោបាយអប់រំជាតិ គឺសុទ្ធតែអនុវត្តបានក្នុងកម្រិតខ្ពស់ ដែលអាចធ្វើឱ្យការងារគ្រប់គ្រង ដឹកនាំអង្គភាពមានលក្ខណៈសមស្របអាចទទួលយកបាន និងជឿជាក់។

### ៤.២.៥- ការចូលរួមពីភាគីពាក់ព័ន្ធ

គឺជាសមត្ថភាពក្នុងការលើកកម្ពស់ការចែករំលែក ការទទួល ខុសត្រូវសម្រាប់ការអភិវឌ្ឍសាលារៀន គ្រប់គ្រងភាពជាដៃគូ និងបណ្ដាញការអប់រំនិងរក្សានិរន្តរភាពនៃទំនាក់ទំនងកិច្ចសហប្រតិបត្តិការជាមួយភាគពីពាក់ព័ន្ធ។ នាយកសាលាគឺជាភ្នាក់ងារដ៏សំខាន់ និងចាំបាច់សម្រាប់ការអភិវឌ្ឍសហគមន៍ជាពិសេសការអភិវឌ្ឍចិត្តគំនិត និងស្មារតី។ នាយកសាលារៀនមានសិទ្ធិចូលរួមគ្រប់សកម្មភាព របស់សហគមន៍ក្នុងគោលបំណង ដើម្បីឆ្លើយតបទៅនឹងគោលការណ៍ "ទាំងអស់គ្នាសម្រាប់ការអបរំ" និង "ការអប់រំសម្រាប់ទាំងអស់គ្នា" *(សៀវភៅណែនាំស្ដីពីតួនាទី និងការងារទទួលខុសត្រូវរបស់នាយក នាយករង និងលេខាធិការ អនុវិទ្យាល័យ របស់ក្រសួងអប់រំ យុវជន និងកីឡា, ថ្ងៃទី០១ ខែមករា ឆ្នាំ ២០១១)*



*បំណកស្រាយ៖*

តាមរយៈក្រាហ្វិកខាងលើនេះ ទិន្នន័យបានបង្ហាញថា ការងារទំនាក់ទំនងក្នុងសហគមន៍ និងការងារ ទំនាក់ទំនងដៃគូអភិវឌ្ឍរបស់គណៈគ្រប់គ្រងសាលារៀន ដើម្បីកសាង និងអភិវឌ្ឍសាលារៀនមានភាពល្អប្រសើរ (តម្លៃមធ្យម 3.92)។ ភាពប្រាស្រ័យទាក់ទងល្អរបស់គណៈគ្រប់គ្រងសាលារៀនរួមមានចំណុចសម្រាប់វាយតម្លៃដូចជា ការកសាងទំនុកចិត្តលើការគ្រប់គ្រងដឹកនាំ រវាងបុគ្គលិក សិស្សានុសិស្ស សហគមន៍មាតាបិតាសិស្ស និងដៃគូអភិវឌ្ឍ ការលើកម្ពស់ការចូលរួមក្នុងសកម្មភាពរបស់សាលាពីសំណាក់សហគមន៍មាតាបិតាសិស្ស ទំនាក់ទំនងប្រកបដោយភាពស្និតស្នាល និងជឿជាក់ ការសម្របសម្រួលនូវសេចក្តីត្រូវការរវាងគ្នានិងគ្នាទៅវិញទៅមក ការទទួលយកនូវមតិយោបល់ផ្សេងៗពីអ្នកពាក់ព័ន្ធនឹងដំណើរការសាលារៀន រក្សាទំនាក់ទំនងល្អ និងដោះស្រាយបញ្ហាប្រកបដោយស្មារតីក្រុម និងគិតពីប្រយោជន៍រួមរបស់សង្គម។ ចំណុចទាំងនេះបានបង្ហាញថា នាយកសាលាបានអនុវត្តទៀងទាត់ និងទទួលបានលទ្ធផលក្នុងកម្រិតមួយខ្ពស់ ដែលជាកត្តាមួយសំខាន់ក្នុងការស្វែងរកការគាំទ្រពីសំណាក់សហគមន៍ ក្នុងកិច្ចដំណើរការសាលារៀនឱ្យកាន់តែល្អប្រសើរឈ្ពោះទៅមុខ។

## ៤.៣- វិភាគជារួមលើសមត្ថភាពគោលទាំង៥របស់នាយកវិទ្យាល័យ

នាយកសាលាចាំបាច់ត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់ សមត្ថភាពខ្ពស់ ភាពច្នៃប្រឌិតរស់រវើក និងការប្រាស្រ័យទាក់ទងល្អក្នុងការដឹកនាំគ្រប់គ្រងសាលារៀន និងការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងប្រសិទ្ធភាព ដើម្បីឆ្លើយតបទៅនឹងបរិបទការអប់រំក្នុងប្រទេស តំបន់ និងសកលលោក។ ដើម្បីក្លាយខ្លួនទៅជា នាយកសាលារៀនល្អ គ្រូបង្រៀនល្អ ត្រូវបង្កើនចំណេះដឹងទូទៅលើស្វ័យសិក្សា សមត្ថភាពនៃការស្រាវជ្រាវ បច្ចេកវិទយាអប់រំ ព័ត៌មានវិទ្យា ភាសាបរទេស ចំណេះដឹងលើការងារគ្រប់គ្រង ភាពជាអ្នកដឹកនាំ មានបំណិនក្នុងការប្រាស័យទាក់ទង និងយល់ដឹងអំពីគោលនយោបាយអប់រំ ព្រមទាំងលិបិតបទដ្ឋានគតិយុត្តិផ្សេងៗ

**ពិភាគជារួមលើសមត្ថភាពគោលរបស់នាយកសាលា**




***បំណកស្រាយ៖***

តាមរយៈក្រាហ្វិកដែលបង្ហាញពីទិន្នន័យ នៃក្របខណ្ឌសមត្ថភាពគោលរបស់នាយកសាលារៀន បានបង្ហាញថា សមត្ថភាពក្នុងការដឹកនាំរបស់នាយកសាលា បើធៀបទៅនឹងសេចក្តីពណ៌នារបស់សៀវភៅមគ្គុទេសសិក្សា ស្តីពីសមត្ថភាពនាយកសាលារៀននៅអាស៊ីអាគ្នេយ៍ និងសៀវភៅស្តង់ដានាយកសាលារៀនរបស់ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រិតការ នៃក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ២០១៧ យើងអាចមើលឃើញថា ការអនុវត្តការងារ និងសមត្ថភាពនៃការដឹកនាំ គ្រប់គ្រងរបស់នាយកសាលាទទួលបានលទ្ធផលល្អ (តម្លៃមធ្យមរួម 3.90) ដែលនេះគឺអាស្រ័យដោយមានការខឹតខំប្រឹងប្រែងរបស់នាយកផ្ទាល់ខ្លួន និងមានកិច្ចសហការល្អពីសំនាក់បុគ្គលិកដែលបានផ្តល់សេចក្តីទុកចិត្តលើការគ្រប់គ្រងរបស់គាត់ និងដោយអនុឡោមតាមគោលការណ៍ថ្មីៗរបស់ក្រសួងក្នុងការធ្វើកំណែទម្រង់លើប្រព័ន្ធការងារគ្រប់គ្រង និងគោលនយោបាយស្តីពីគ្រូបង្រៀន ជាពិសេសគោលនយោបាយស្តីពីការអប់រំបច្ចេកទេសក្នុងយុគសម័យថ្មី ដើម្បីកសាងពលរដ្ឋពេញលេញសម្រាប់សង្គមជាតិ ដែលជាហេតុធ្វើឱ្យនាយកសាលាមានការខិតខំអនុវត្តការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

## ៤.៤- វិភាគលើភាពពេញចិត្តរបស់ភាគីពាក់ព័ន្ធទៅនឹងការបណ្តុះបណ្តាលរបស់សិស្ស នៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី

*៤.៣.១-QII.4 - 9*




***បំណកស្រាយ៖***

យោងតាមដ្យាក្រាមខាងលើ ក្នុងចំណោមអ្នកចូលរួមបំពេញកម្រងសំណួរចំនួន៨៤នាក់ ពួកគាត់មានការពេញចិត្តជាខ្លាំង ទៅលើសមត្ថភាពជំនាញបច្ចេកទេសដែលទទួលបានពីការសិក្សា តម្លៃ **Mean=4.4**។ នេះមានន័យថា ការដឹកនាំលើការបង្រៀន និងរៀនផ្នែកមុខវិជ្ជាឯកទេស ផ្នែកជំនាញបានល្អ។ ដូចគ្នាដែរចំពោះឥរិយាបទរបស់សិស្ស។ ប៉ុន្តែចំពោះចំណេះដឹងទូទៅ( ភាសាខ្មែរ គណិត រូប គីមី ជីវវិទ្យា.......) គឺនៅកម្រិតទាបខ្លាំង ឃើញថាតម្លៃ **Mean=1.75** ម្យ៉ាងវិញទៀតក៏អាចនិយាយបែបនេះផងដែរ គឺតាមរយៈលទ្ធផលនៃការប្រលងបញ្ចប់ការសិក្សាផ្នែកអប់រំបច្ចេកទេស ឆ្នាំទី១ ឆ្នាំទី២ និងការប្រលងសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ ក្នុងឆ្នាំសិក្សា២០១៧-២០១៨ (បើតាមលទ្ធផលនៃការប្រឡងបញ្ចប់ការសិក្សាផ្នែកអប់រំបច្ចេកទេស ឆ្នាំទី១ ឆ្នាំទី២ និងការប្រលងសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ ក្នុងឆ្នាំសិក្សា២០១៧-២០១៨ របស់ក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ឆ្នាំ២០១៨)។ បំណិនទន់ដែលសិស្សទទួលបាន ក៏នៅមានកម្រិតទាបដែរ ខណៈតម្លៃ **Mean=2.14** នេះមានន័យសិស្សផ្នែកអប់រំបច្ចេកទេសនៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី មិនទាន់មានសមត្ថភាព និងការប្រើប្រាស់ជំនាញទន់ (Soft Skills) ជំនាញទន់នេះជាផ្នែកមួយយ៉ាងសំខាន់ ឬជាធាតុមួយដែលជួយ ឬកសាងធនធានមនុស្សឱ្យក្លាយជាធនធានពេញលេញ ឬធនធានសាកល តាមលផលល្អផលមានន័យថាសិស្ស មិនទាន់មានសម្

ភាពគ្រប់គ្រន់ដូចជា៖ (១)- គោលបំណងដៃការសិក្សា។ (២)- អត្ថន័យ នៃការសិក្សា និងការធ្វើការងារផ្នែកបច្ចេកទេសុ។ (៣)-តម្រូងការមូលដ្ឋានគ្រឹះនៃការសិក្សា និងការងារផ្នែកបច្ចេកទេស។ (៤)- វិធានជំរុញការសិក្សាផ្នែកបច្ចេកទេស។ (៥)- ដំណោះស្រាយបញ្ហា។ (៦)- ការងារក្រុម។ (៧)- ទមនៀមទំលាប់ ប្រពៃណី និងវប្បធម៌ជាតិសាសន៍បានច្បាស់លាស់ (៨)- បរិស្ថាននៃការសិក្សាផ្នែកបច្ចេកទេស (៩)- **5 S** និង(១០)- ក្រមសីលធម៌អ្នកសិក្សាផ្នែកបច្ចេកទេស ឬអ្នកធ្វើការខាងផ្នែកបច្ចេកទេសជាដើម (ការសិក្សាគម្រោង របស់សាកលវិទ្យាល័យ Kitakyushu, 2018 គាំទ្រដោយអង្គការ JICA ប្រទេសជប៉ុន)។

### ៤.៤.១-QII.10 - 15




*បំណកស្រាយ៖*

យោងតាមដ្យាក្រាមខាងលើ ក្នុងចំណោមអ្នកចូលរួមបំពេញកម្រងសំណួរចំនួន៨៤នាក់ ពួកគាត់មានការពេញចិត្ត ចំពោះសមត្ថភាពទំនាក់ទំនង សកម្មភាពក្រៅថ្នាក់រៀន (ការតាំងពិព័រណ៍ស្នាដៃផ្នែកអប់រំបច្ចេកទេស ដែលវិទ្យាល័យតែងតែរៀបចំឱ្យមានការតាំងពិព័រណ៍នេះជារៀងរាល់ឆ្នាំ ហើយមានការចាប់អារម្មណ៍ពីសហគមន៍ ) (របាយការណ៍ដំណាច់ឆ្នាំរបស់វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី ឆ្នាំ២០១៨)។ ជាពិសេសសិស្សមានការពេញចិត្តជាខ្លាំង ចំពោះការរៀបចំកម្មសិក្សាជារៀងរាល់ឆ្នាំដែលមានតម្លៃ Mean=4.49 ទៅតាមបណ្តារោងចក្រ សហគ្រាស កសិដ្ឋាន សិប្បកម្ម តាមរយៈការទំនាក់ទំនងរបស់គ្រូបង្រៀន នាយកសាលា និងការសម្របសម្រួលរបស់នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ។ ដោយពួកគាត់បាននិយាយថា ពួកកាត់បាទទួលនូវចំណេះដឹងជំនាញកាន់តែច្បាស់តាមរយៈការដឹកនាំ និងសម្របសម្រួលរបស់គ្រូដឹកនាំ ការដកស្រង់បទពិសោធន៍ ការទទួលបាននូវចំណេះដឹងជំនាញ ពីម្ចាស់ក្រុមហ៊ុន រោងចក្រ សហគ្រាស និងកសិដ្ឋាន។ល។ មួយវិញទៀតការរស់នៅជាក្រុមជាមិត្តមិត្តរួមក្រុម ខណៈការចុះកម្មសិក្សានេះ។

សរុបសេចក្តីមក លទ្ធផលក្រាបខាងលើ សបញ្ជាក់ពីការសម្រេចបាននូវវត្ថុបំណងអប់រំផ្នែកបច្ចេកទេសមួយកម្រិត បើត្បិតមិនបានល្អឥតខ្ចោះក៏ដោយ ហើយវាជាលទ្ធផលជោគជ័យរបស់នាយកវិទ្យាល័យ លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស ដែលពួកគាត់នឹងយកចំណេះជំនាញ ដែលបានពីការសិក្សា កម្មសិក្សាយកទៅអនុវត្តក្នុងជីវភាពប្រចាំថ្ងៃប្រកបដោយទំនុកចិត្ត និងមានប្រសិទ្ធភាពខ្ពស់។

### ៤.៤.១-QII.16 - 21




***បំណកស្រាយ៖***

តាមក្រាបខាងលើ និយាយពីកម្រិតនៃការពេញចិត្ត ឬកម្រិតនៃការឯកភាពរបស់សិស្សលើការចុះទស្សនកិច្ចសិក្សា គឺមានកម្រិតល្អប្រសើរដោយតម្លៃ **M=4.55** នេះមានន័យថាសិស្សទទួលបាននូវចំណេះដឹងជំនាញ បទពិសោធ ការអនុវត្តជាក់ស្តែង ការផ្លាស់ប្តូរនូវឥរិយបថ សេចក្តីថ្លៃថ្នូរ និងការស់នៅជាក្រុមជាដើម។ ចំពោះភាពពេញចិត្តទៅលើការដឹកនាំ និងគ្រប់គ្រង របស់នាយកសាលាតម្លៃ **M=4.42** គឺស្ថិតក្នុងកម្រិតល្អប្រសើរ នេះមានន័យថាការដឹកនាំរបស់នាយកសាលា លើការងារដឹកនាំការបង្រៀន និងរៀន និងទិដ្ឋភាពទូទៅ បានល្អប្រសើរ។ ចំពោះការបង្រងៀនរបស់គ្រូ សិស្សមានកម្រិតពេញចិត្តកម្រិតល្អដែរ ព្រោះតម្លៃ **M=4.02** នេះសបញ្ជាក់ថាគ្រូបង្រៀនសិស្សបានល្អតាមការដឹកនាំរបស់នាយកសាលា ដោយមានផែនការបង្រៀន បានរៀបចំឯកសាររដ្ឋបាលគ្រូ និងបានធ្វើការវាយតម្លៃសមត្ថភាពសិស្សបានជាប្រចាំ។

## ៤.៤- វិភាគលើភាពពេញចិត្តរបស់សិស្សនាក់ទងនៅនឹងសាលារៀន នៅវិទ្យាល័យ ចំណេះទូទៅនិងបច្ចេកទេស ព្រះបាទសម្ដេច ព្រះបរមនាថ នរោត្តមសីហមុនី

### *៤.៤.១- QIII.22.1 – 22.5*




***បំណកស្រាយ៖***

តាមការក្រាបខាងលើ បានបង្ហាញជាលទ្ធផលជាតម្លៃមធ្យម នៃកម្រិតនៃការពេញចិត្តរបស់សិស្សសុវត្ថិភាពក្នុងការសិក្សា **Mean=3.71** ជាតម្លៃល្អកម្រិតខ្ពស់ នេះមានន័យថាសិស្សអង្គុយសិក្សាដោយមានសេចក្ដីសុខ មិនមានការព្រួយបារម្ភពីបញ្ហាអសកម្ម ឬការបង្កជំលោះ ឬការរំខានពីសិស្សដែលមកពីសាលាផ្សេង។ និយាយពីការចង់រៀននៅក្នុងរៀននៅក្នុងវិទ្យាល័យ មានតម្លៃ **Mean= 4.46** លទ្ធផលល្អកម្រិតខ្ពស់។ បរិស្ថាន និងទីធ្លា មានតម្លៃ **Mean=4.06** ។ បរិស្ថានល្អក្នុងថ្នាក់រៀន **Mean=3.81** ល្អកម្រិតខ្ពស់។ អគារសិក្សា និងបន្ទប់សិក្សាគ្រប់គ្រាន់ មានតម្លៃ **Mean=4.63** ល្អកម្រិតខ្ពស់។

### *៤.៤.១- QIII.23.1 – 23.6*




*បំណកស្រាយ៖*

ក្រាបខាងលើបង្ហាញពីតម្លៃមធ្យមនៃកម្រិតឯកភាព ឬការពេញចិត្តរបស់សិស្សលើទិដ្ឋភាពនៃវិទ្យាល័យ ដូចជាបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ មានតម្លៃ Mean=4.14 លទ្ធផលល្អកម្រិតខ្ពស់។ សម្ភារៈពិសោធន៍ និងសម្ភារគាំទ្រការបង្រៀន និងរៀនមានតម្លៃ Mean= 4.02 ល្អកម្រិតខ្ពស់។ បណ្ណាល័យ និងឯកសារស្រាវជ្រាវមានតម្លៃ Mean=4.07 លទ្ធផលល្អកម្រិតខ្ពស់។ ធ្វើពិសោធន៍វិទ្យាសាស្ត្រ មានតម្លៃ Mean=3.36 លទ្ធផលល្អកម្រិតខ្ពស់។ មានកម្មវិធីសិក្សាច្បាស់លាស់ មានតម្លៃ Mean= 4.23 លទ្ធផលល្អកម្រិតខ្ពស់។ មានរោងជាងមូលដ្ឋាន និងសួនប្រតិបត្តិ មានតម្លៃ Mean= 4.46 លទ្ធផលល្អកម្រិតខ្ពស់។ ជារួមយើងឃើញថាកម្រិតនៃការពេញចិត្តរបស់សិស្សមានកម្រិតខ្ពស់ មានន័យថា ការរៀបចំដឹកនាំ និងគ្រប់គ្រងរបស់គ្រូមានលទ្ធលល្អកម្រិតខ្ពស់។

### *៤.៤.១- QIII.23.7 – 23.12*

គុណភាពអប់រំ គឺវាយតម្លៃលើលទ្ធផលនៃការសិក្សារបស់សិស្ស ក្រោយពីការបញ្ចប់ការសិក្សា សិស្សមានសមត្ថភាពដោះស្រាយបញ្ហាក្នុងជីវភាពប្រចាំថ្ងៃ ការប្រកបមុខរបរ ធ្វើជំនួញ ឬក្លាយជាម្ចាស់សហគ្រាសធនតូចធនមធ្យម។ ជាក់ស្ដែងការសិក្សាដែលទទួលបានលទ្ធផល គឺអាស្រ័យដោយចំណែកនៃគុណភាពនាយកសាលារៀន គុណភាពគ្រូបង្រៀន កម្មវិធីសិក្សា និងសម្ភារៈគាំទ្របង្រៀន។




***បំណកស្រាយ៖***

តាមក្រាបខាងលើ អ្នកសិក្សាសង្កេតឃើញថាការរៀន និងបង្រៀននៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសខេត្តកំពង់ឆ្នាំង មានការដឹកនាំរៀបចំការបង្រៀនដោយគោរពតាមទ្រឹស្តីផ្សារភ្ជាប់ទៅនឹងការអនុវត្ត តាមរយៈការបង្រៀនដោយប្រើប្រាស់សម្ភារៈឧបទ្ទេស មានតម្លៃ **Mean=3.87** ល្អកម្រិតខ្ពស់។ បន្ទប់ពិសោធវិទ្យាសាស្រ្ត មានតម្លៃ **Mean=3.95** ល្អកម្រិតខ្ពស់។ ប្រព័ន្ធប្រកាសអាសន្ន មានតម្លៃ **Mean=3.13** កម្រិតមធ្យម នេះមានន័យថាការរៀបចំមិនទាន់បានល្អ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន
# និងសំណូមពរ

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ៥.១- សេចក្តីសន្និដ្ឋាន

ផ្អែកលើទិន្នន័យដែលបានបង្ហាញខាងលើ យើងអាចសន្និដ្ឋានបានថា ការគ្រប់គ្រង និងដឹកនាំការអប់រំបច្ចេកទេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅកម្ពុជាករណីសិក្សា នៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ព្រះបាទសម្តេច ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី ទទួលបានលទ្ធផលល្អតាមរយៈការដឹកនាំ និងគ្រប់គ្រងដោយបានអនុលោមទៅតាមក្របខណ្ឌស្តង់ដាសមត្ថភាពគោលរបស់នាយកអាស៊ីអាគ្នេយ៍ គឺ(១)- គំនិតប្រកបដោយយុទ្ធសាស្ត្រ និងនវានុវត្តន៍ គឺនាយកសាលាបានដឹកនាំ និងរៀបចំធ្វើតារាងទិសដៅយុទ្ធសាស្ត្រ និងដោយមានការចូលរួមកសាងពីសហគមន៍ក្នុងការអភិវឌ្ឍផែនការយុទ្ធសាស្ត្រ បានបង្ហាញទស្សនវិស័យសាលារៀន និងធ្វើជាគម្រូល្អនៃតម្លៃការងារ និងការអនុវត្តប្រចាំថ្ងៃ បានប្រើភស្តុតាងផ្សេងៗជាច្រើនដើម្បីគាំទ្រ ត្រួតពិនត្យ និងវាយតម្លៃ និងបានកែម្អផែនការយុទ្ធសាស្ត្រ បានអនុវត្តការពិនិត្យឡើងវិញជាប្រចាំនៃការអនុវត្តគម្រោង ឬកម្មវិធី និងបានប្រើប្រាស់លទ្ធផលក្នុងការណែនាំបញ្ហា និងការព្រួយបារម្ភពីការអនុវត្តផែនការនានា បានដឹកនាំដំណើរការផ្លាស់ប្តូរសំដៅលើការអនុវត្ត និងការអភិវឌ្ឍគោលវិធីផ្សេងៗ បានដឹកនាំ និងធ្វើឱ្យមាននិរន្តរភាពនៃការច្នៃប្រឌិត ការបង្កើតថ្មី នៅក្នុងកម្មវិធីសាលា ដើម្បីសម្រេចនូវលទ្ធផលខ្ពស់ជាងមុន។ រាល់ការសម្រេចចិត្តក្នុងការងារផ្សេងៗតែងតែមានការពិភាក្សា និងជូនដំណឹងដល់លោកគ្រូ អ្នកគ្រូឱ្យបានដឹង និងមានការឯកភាព។ (២)- ភាពជាអ្នកដឹកនាំ និងគ្រប់គ្រង នាយកសាលាមានការប្រមើលមើល និងបានគ្រប់គ្រងធនធាន និងប្រព័ន្ធនៃសាលារៀនបានកម្រិតល្អ បានគ្រប់គ្រង និងប្រើប្រាស់ហិរញ្ញវត្ថុបានត្រឹមត្រូវ តាមរយៈមានការរៀបចំជាគណៈកម្មការ និអនុគណៈកម្មការយ៉ាងត្រឹមត្រូវក្នុងការគ្រប់គ្រង និងប្រើប្រាស់ថវិកាសាលារៀន បានគ្រប់គ្រង ថែរក្សា និងការពារបរិស្ថានសាលារៀន តាមរយៈការរៀបចំឱ្យមានគណៈកម្មការក្នុងការបោសសំអាតតាមអគារ បន្ទប់សិក្សា និងទីធ្លារសាលារៀន មានសន្តិសុខ អនាម័យ សណ្តាប់ធ្នាប់ ការរៀបចំក្រុមយុវជនកាកបាទក្រហម និងយុវជនកាយរឹទ្ធិ ក្នុងការចូលរួមសម្របសម្រួលការងារសន្តិសុខ សណ្តាប់ធ្នាប់សាលារៀនជាដើម។ បានគ្រប់គ្រងលើការបំពេញការងាររបស់បុគ្គលិក តាមរយៈការរៀបចំសៀវភៅវត្តមានគ្រូ និងមានការអនុវត្តជាប្រចាំ ការកោះហៅគ្រូដែលមានការអនុវត្តមានច្រើនមកធ្វើការណែនាំ និងធ្វើកិច្ចសន្យា ការកសាងឯកសារលុបឈ្មោះគ្រូបង្រៀនដែលអសកម្មខ្លាំងក្នុងការបង្រៀនទៀតផង។ ការគាំទ្រ និងផ្តល់ឱកាសសម្រាប់បុគ្គលិកក្រោមឱវាទក្នុងការកសាង អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈតាមរយៈការផ្តល់ឱកាសដល់គ្រូបង្រៀនដែលសកម្មឱ្យទៅបន្តការសិក្សា ឬទស្សនកិច្ចសិក្សាក្នុង ឬក្រៅប្រទេសជាដើម។ ការផ្សព្វផ្សាយដំណឹងអាហារូបរណ៍ ការចែករំលែកចំណេះដឹង ការបង្ហាញ និងលើកទឹកចិត្តគ្រូឱ្យចូលរួមប្រលងវត្តពន្លឿនតាមគោលការណ៍របស់ក្រសួង និងមានការលើកទឹកចិត្តគ្រូបង្រៀន

បានបង្ហាញពីភាពក្លាហានក្នុងការងារដឹកនាំ និងគ្រប់គ្រងសាលារៀន។ (៣)- ភាពជាអ្នកដឹកនាំ ការបង្រៀន និងរៀន ទទួលបានលទ្ធផលល្អ នាយកសាលារៀនបានគ្រប់គ្រងការអនុវត្តកម្មវិធីសិក្សា តាមរយៈការរៀបចំឱ្យមានការតាមដាន និងការធ្វើវឌ្ឍនភាពនៃការសិក្សាជាប្រចាំតាមជំនាញ ឯកទេស តាមឆ្នាំសិក្សា និងតាមថ្នាក់ស្របនីមួយៗ បានរៀបចំគម្រូ សម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃ ការលើកកម្ពស់ស្មារតីការងារជាក្រុម តាមរយៈលើកទឹកចិត្តឱ្យគ្រូបង្រៀនបង្កើតគម្រោង និងការពិសោធន៍ការកែលម្អការបង្រៀន តាមរយៈការចុះអធិការកិច្ច និងការផ្តល់ការកែម្អ ការលើកកម្ពស់ការប្រើប្រាស់សម្ភារៈសិក្សា តាមរយៈការផ្តល់ និងផ្គត់ផ្គង់សម្ភារឧបទ្ទេសឱ្យគ្រប់គ្រាន់ និងពិនិត្យការប្រើប្រាស់ក្នុងពេលបង្រៀន និងរៀន ការលើកទឹកចិត្តគ្រូឱ្យកាសាងឯកសារស្នាដៃស្រាវជ្រាវសម្រាប់ដាក់ក្នុងបណ្ណាល័យ និងផ្តល់ជាថវិកាក្នុងការបោះពុម្ព(បើបានរៀបចំ)។ (៤)- ឧត្តមភាពបុគ្គល នាយកសាលាបានដឹកនាំ និងធ្វើជាគម្រូល្អក្នុងសាលារៀន បានបង្ហាញពីគណនេយ្យភាព តម្លាភាព តាមរយៈការប្រជុំផ្សព្វផ្សាយពីផែនការចំណូលចំណាយ បិទផ្សាយពីចំណូលចំណាយ ការចែករំលែក ការបង្ហាញនូវការរស់នៅប្រកបដោយសុខភាពល្អ តុល្យភាព តាមរយៈការរៀបចំខ្លួនសមរម្យការស្លៀកពាក់ ភាពអនាម័យក្នុងការរស់នៅ ស្ថានភាពជីវភាព ភាពចុះសម្រុងគ្នាក្នុងគ្រួសារ និងសង្គម និងកត្តាសុខភាព ការបង្ហាញពីមោទនភាព ការគោរព ស្រលាញ់វិជ្ជាជីវៈ បង្ហាញពីស្នាដៃ និងលទ្ធផលនៃការគ្រប់គ្រង និងដឹកនាំការងារផ្សេងៗដែលបានសម្រេច ការគ្រប់គ្រង និងពិនិត្យលើការងារជាអាទិភាព ការពន្យល់ពិហេតុផលនៃការសម្រេចចិត្ត ការពពិភាក្សាប្រឹក្សា និងការដោះស្រាយបញ្ហា ការគាំទ្រនូវទស្សនវិស័យអាស៊ាន និងដៃគូពាក់ព័ន្ធ តាមរយៈការស្វែងរក និងផ្សារភ្ជាប់ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ។ និងទី(៥)- ការចូលរួមពីភាគីពាក់ព័ន្ធទទួលបានលទ្ធផលល្អ នាយកសាលាបានបង្កើតទំនុកចិត្ត និងការដឹកនាំក្រុម និងសហគមន៍ តាមរយៈការឱ្យមានការចូលរួមពីមាតាបិតាសិស្ស ការផ្តល់ឱ្យកាសឱ្យមាតាបិតាសិស្សបានដឹងពីលទ្ធផលសិក្សារបស់កូនៗ ការងារប្រជុំជាមួយមាតាបិតាសិស្សនៅដើមឆ្នាំសិក្សា និងនៅមុនការប្រលងបញ្ចប់ឆ្នាំសិក្សា ការផ្ញើទំនាក់ទំនងតាមរយៈគ្រូបន្ទុកថ្នាក់ ការផ្តល់ព័មានសិក្សា និងលទ្ធផលសិក្សា។ ការពង្រឹងការចូលរួមរបស់សហគមន៍ តាមរយៈការរៀបចំឱ្យមានការតាំងពិព័រណ៍ស្នាដៃសិស្សជារៀងរាល់ឆ្នាំ និងសកម្មភាពសង្គមផ្សេងៗ និងការបង្កើតទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពខ្ពស់ជាមួយដៃគូពាក់ព័ន្ធ តាមរយៈការសម្របសម្រួល និងការចូលរួមប្រកបដោយសមានចិត្ត និងទឹកចិត្តលើការងារ និងផលប្រយោជន៍រួម។ ការជម្រុញការបង្កើតមតិ ដោយការស្របគ្នា និងការគ្រប់គ្រងលើការខ្វែងគំនិតគ្នា និងការដោះស្រាយបញ្ហាដោយសន្តិវិធី និបានធ្វើទំនាក់ទំនង ពីតម្រូវការ សកម្មភាពសាលារៀន បង្ហាញលទ្ធផល ដល់សហគមន៍ជាអាទិ៍។

សរុបសេចក្តីមក អ្នកសិក្សាអាចសន្និដ្ឋានបានថា ស្ថានភាព និងការគ្រប់គ្រង និងដឹកនាំការងារអប់រំបច្ចេកទេស បានល្អ និងស័ក្តិសមជាវិទ្យាល័យគម្រូមួយ សម្រាប់ជាលទ្ធផលរួមចំណែកគាំទ្រ និងលើកកម្ពស់ការកសាង និងអភិវឌ្ឍការងារអប់រំផ្នែកបច្ចេកទេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា។ ការកសាងធនធានផលិតសម្រាប់ជាមូលដ្ឋានក្នុងការគាំទ្រសេដ្ឋកិច្ចជាតិ ឱ្យសម្រេចបាននូវគោលដៅប្រទេសទទួលបានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងក្លាយជាប្រទេសទទួលបាទប្រាក់ចំណូលខ្ពស់ ឬហៅថាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០។ ការដឹកនាំ និងគ្រប់គ្រងការអប់រំបច្ចេកទេសរបស់នាយកដែលទទួលបានលទ្ធផលល្អ ឆ្លើយតបតាមរយៈលទ្ធនៃការសិក្សារបស់សិស្សផ្នែកអប់រំបច្ចេកទេស លទ្ធផលនៃការប្រលងបញ្ចប់ការសិក្សា ឆ្នាំទី១ ឆ្នាំទី២ និងលទ្ធផលនៃការប្រលងសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ ក្នុងឆ្នាំសិក្សា២០១៧-២០១៨ គឺសិស្សប្រលងជាប់បាន**៩៦%**។ សិស្សផ្នែកអប់រំវិជ្ជាជីវៈនៅពេលបញ្ចប់ការសិក្សាមានឱកាសក្នុងការស្វែងរកការងារ តាមក្រុមហ៊ុន អាចបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សាតាមជំនាញ និងទទួលបានអាហារូបករណ៍ទៅបន្តការសិក្សានៅប្រទេសថៃ អាចប្រកបមុខរបរ ចិញ្ចឹមជីវិតផ្ទាល់ខ្លួនបាន និងសញ្ញាបត្រមានតម្លៃស្មើសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំណេះទូទៅ។

ទន្ទឹមនឹងការទទួលបានលទ្ធផលល្អច្រើននៅលើការងារគ្រប់គ្រង និងដឹកនាំ ក៏មានបញ្ហាប្រឈមមួយចំនួនដែលគួរឱ្យកត់សំគាល់ដែរដូចជា(១)- លទ្ធផលនៃការសិក្សារបស់សិស្សលើមុខវិជ្ជាចំណេះទូទៅគឺនៅមានកម្រិតទាប។ (២)- ការរៀបចំ និងការប្រើប្រាស់ឧបករណ៍ និងប្រព័ន្ធសុវត្ថិភាពក្នុងសាលារៀន។ (៣)- សមត្ថភាពលើបំណិនទន់របស់សិស្ស។ **ដំណោះស្រាយលើបញ្ហា**(១)- គឺ**ទីមួយ**ពិនិត្យ និងការៀបចំប្រព័ន្ធអធិការកិច្ចផ្ទៃក្នុងលើគ្រូបង្រៀនមុខវិជ្ជាចំណេះទូទៅ តាមរយៈពិនិត្យមើលលើ ការរៀបចំ និងប្រើប្រាស់សៀវភៅរដ្ឋបាលគ្រូ ដូចជាសៀវភៅបញ្ជីឈ្មោះសិស្ស សៀវភៅពិន្ទុ សៀវភៅសម្រង់អត្តបទ សៀវភៅកិច្ចតែងការបង្រៀន សៀវភៅកំណត់ហេតុប្រជុំរួម សៀវភៅកណត់ហេតុប្រជុំបច្ចេកទេស សៀវភៅក្លេបង្រៀន **ទីពីរ** ពិនិត្យមើលលើខ្លឹមសារមេរៀន ការគោរពតាមគោលការណ៍ជាំហានទាំងប្រាំក្នុងកិច្ចតែងការ និង**ទីបី** ពិនិត្យមើលលើវិធីសាស្រ្តបង្រៀនរបស់គ្រូបង្រៀន។

## ៥.២- អនុសាសន៍ និងសំណូមពរ

❖ **ចំពោះសាលារៀន**

- អនុវត្តការធ្វើអធិការកិច្ចផ្ទៃក្នុង ការវាយតម្លៃ និងការកែលម្អការបង្រៀន និងរៀន
- ពិនិត្យតាមដាននូវការប្រើប្រាស់សម្ភារៈឧបទ្ទេសសម្រាប់ការបង្រៀន និងរៀនរបស់គ្រូ
- ពិនិត្យតាមដាន និងវាយតម្លៃការងារប្រជុំបច្ចេកទេសតាមមុខវិជ្ជា និងជំនាញឯកទេស
- បង្កើតឱ្យមានការធ្វើថ្នាក់និទស្សន៍ និងអនុវត្តតាមផែនការ

- ព្យាយាមផ្តល់ឱកាសដល់គ្រូដែលជាសមាជិកក្នុងក្រុមតាមមុខវិជ្ជាបានចូលរួមមើលការបង្រៀនរបស់គ្រូដទៃ
- ដឹកនាំសិស្សបង្កើតគម្រោងសិក្សាតាមមុខជំនាញ ថ្នាក់ស្រប និងរៀបចំបាយការណ៍
- រៀបចំប្រព័ន្ធប្រកាសអាសន្ន និងការពារហានិភ័យផ្សេងៗ
- រៀបចំប្រអប់សង្គ្រោះបឋម និងថ្នាំ គ្រប់គ្រង និងប្រើប្រាស់ឱ្យបានល្អ
- ពង្រឹងវិន័យ សណ្តាប់ធ្នាប់គ្រូ និងសិស្ស

❖ **ចំពោះមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡាស្រុក**

- ចូលរួមក្នុងការអនុវត្តអធិការកិច្ចផ្ទៃក្នុង
- ចូលរួមក្នុងការគាំទ្របន្ថែមទៀតក្នុងសកម្មភាពរៀបចំ និងតាមដានការអនុវត្តផែនការអភិវឌ្ឍសាលារៀន

❖ **ចំពោះក្រសួងអប់រំ យុវជន និងកីឡា**

- ពង្រឹការចុះអធិការកិច្ចផ្ទៃក្រៅ ពិសេសចុះមើលលើការបង្រៀនផ្ទាល់របស់គ្រូ
- ពន្លឿនការទម្លាក់បញ្ចប់ថវិកាគាំទ្រសាលារៀនចាប់ពីដើមឆ្នាំ២០១៨-២០១៩
- ផ្តល់សិទ្ធិ និងកញ្ចប់ចិកាដល់សាលារៀនផ្ទាល់
- មជ្ឈការការងារឱ្យទៅសាលារៀន លើការងារគ្រប់គ្រង ចាត់តាំង ការជ្រើសរើសគណៈគ្រប់គ្រង
- រៀបចំកម្មវិធីបំប៉នសមត្ថភាពគ្រូបង្រៀនលើការប្រើប្រាស់សម្ភារបរិក្ខារបច្ចេកទេសសម្រាប់ការបង្រៀន និងរៀន
- ពន្លឿនការរៀបចំសៀវភៅសិក្សគោលផ្នែកអប់រំបច្ចេកទេសលើជំនាញដែលខ្វះ
- រៀបចំ និងដាក់បញ្ចូលនូវឯកសារមេរៀនជំនាញទន់ និងការគ្រប់គ្រងសង្វាក់ផលិតកម្មក្នុងកម្មវិធីសិក្សា
- ជាចាំបាច់ត្រូវតែមាននាយករងម្នាក់ដែលទទួលបន្ទុកការងារអប់រំបច្ចេកទេស និងត្រូវគុណវុឌ្ឍិត្រឹមកម្រិតបរិញ្ញាបត្រផ្នែកបច្ចេកទេសឡើងទៅ ដើម្បីឱ្យមានមូលដ្ឋានគ្រឹះក្នុងការងារគ្រប់គ្រង ដឹកនាំ និងរៀបចំទុកដាក់សម្ភារពិសោធ
- កំណត់គុណវុឌ្ឍិរបស់នាយកវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ត្រូវតែមានសញ្ញាបត្រផ្នែកបច្ចេកទេសចាប់ពីកម្រិតសញ្ញាបត្រឡើងទៅ។

❖ **ចំពោះអ្នកសិក្សាក្រោយៗ**

សិក្សាស្រាវជ្រាវបន្ត ឱ្យកាន់តែស៊ីជម្រៅជាងនេះដោយធ្វើការជ្រើសរើសសំណាកសំភាសន៍បន្ថែមទៀតពីសហគមន៍ គណៈទ្រទ្រង់សាលា និងមាតាបិតាសិស្សដើម្បីប្រមូល

បានធាតុចូលកាន់តែច្បាស់លាស់ និងធ្វើការពង្រីកសំណាកទៅកាន់វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ផ្សេងៗទៀត ក្នុងព្រះរាជាណាចក្រកម្ពុជា។

# ឯកសារយោង៖


(១)- ច្បាប់អប់រំឆ្នាំ២០១៧ របស់ក្រសួងងប់រំ យុវជន និងកីឡា

(២)- វចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត

(៣)- គោលដៅអភិវឌ្ឍប្រទេសរបស់រាជរដ្ឋាភិបាល

(៤)- របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០១៦ ស្តីពីការអនុវត្តផែនការអភិវឌ្ឍយុទ្ធសាស្ត្រឆ្នាំ ២០១៤-២០១៨ និងធ្វើចំណោលសម្រាប់ឆ្នាំ២០២០

(៥)- គោលនយោបាយអប់រំបច្ចេកទេសឆ្នាំ២០១៣ របស់ក្រសួងអប់រំ យុវជន និងកីឡា

(៦)- របាយការណ៍ក្រសួងអប់រំ យុវជន និងកីឡា ផ្ញើជូនអង្គការ UNESCO

(៧)- របាយការណ៍សន្និបាទអប់រំ នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា ២០១៨

(៨)- ឯកសារក្របខណ្ឌស្តង់ដាសមត្ថភាពគោលនាយកសាលាអាស៊ីអាគ្នេយ៍(Seameo Innotech,2016)

(៩)- ឯកសារស្តង់ដាវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស នាយកដ្ឋានតម្រង់ទិសវិទ្យាជីវៈ ក្រសួង អប់រំ យុវជន និងកីឡា ឆ្នាំ២០១៨

(១០)- UNESCO – UNEVOC International Cetre for technical and Vocational Education

(១១)- UNESCO TVET(2010-2015)

(១២)- យុទ្ធសាស្ត្រចតុកោណដំនាក់កាលទី៤ នីតីកាលទី៦ នៃព្រះរាជាណាចក្រកម្ពុជា

(១៣)- ផែនការយុទ្ធសាស្ត្ររបស់នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈឆ្នាំ(២០១៤-២០១៨)

(១៤)- ផែនការយុទ្ធសាស្ត្ររបស់នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈឆ្នាំ(២០១៩-២០២៣)

(១៥)- របាយការណ៍បូកសរុបការងារអប់រំបច្ចេកទេសរបស់នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ

(១៦)- ការពន្យល់ពីស្តីពីការផ្តើមផែនការកម្ម សម្រាប់មន្ត្រីគ្រប់គ្រងអប់រំ ១៩៩៨ MoEYS, នាយកដ្ឋានផែនការ p.47

(១៧)- សៀវភៅកំណែទម្រង់វិស័យអប់រំនៅកម្ពុជា មាគ៌ាឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាព ហង់ ជួន ណារ៉ុន ២០១៦

(១៨)- ឯកសារ Presentation របស់ឯកឧត្តមបណ្ឌិត ហង់ ជួន ណារ៉ុន ២០១៨

(១៩)- របាយការណ៍ការសិក្សាគម្រោងរបស់សាកលវិទ្យាល័យ Kitakyushu, JICA ប្រទេសជប៉ុន 2018

(២០)- Kotter, (1990)

(21)- http://srpchandeth.wordpress.com

(22)- Khedeka, (2014)

(23)- អ្នកដឹកនាំ (ឡាវស៊ី)

(24)- អ្នកដឹកនាំ (លីន ប៉ូចឹលែល)

(25)- Boon and Kurtz, (1992)

(26)- Hanushek and Woessman, (2008)

(27)- Hunter, (1985)

(28)- Hanrry Truman, (1997)

(29)- Adolf Hitler, (1925)

(30)- Fairholm, (1991)

(31)- Ibid, p.39

(32)- Henry Mintzberg

(33)- Bamberger, (2012)

(34)- Ary et Berg, (2009)

(35)- Gray, (2009)

(36)- Merriam, (1998)

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ១

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## កម្រងសំណួរសិក្សាស្រាវជ្រាវសម្រាប់ការសរសេរនិក្ខេបបទ
## ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ

## កម្រងសំណួរសម្រាប់គ្រូ

ខ្ញុំបាទឈ្មោះ ប៉ែល ប៊ុណ្ណារិទ្ធិ ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ ជំនាន់ទី៥ របស់វិទ្យាស្ថានជាតិអប់រំ ( NIE ) ក្នុងឆ្នាំសិក្សា(២០១៦.២០១៨) ដែលកំពុងសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី " **ការគ្រប់គ្រង និងដឹកនាំ ការអប់រំបច្ចេកទេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា "ករណីសិក្សាវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី ខេត្តកំពង់ឆ្នាំង** ។ ការស្រាវជ្រាវនេះ មានគោលបំណងរកឱ្យឃើញពីរបៀបនៃការគ្រប់គ្រង និងដឹកនាំរបស់ គណៈគ្រប់គ្រងវិទ្យាល័យ ចំណេះទូទៅនិងបច្ចេកទេស សម្រាប់ធ្វើការអភិវឌ្ឍការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈនៅកម្ពុជា។ ដូច្នេះសូមលោក លោកស្រី មេត្តាផ្តល់ព័ត៌មានពិត ដល់ការសិក្សាស្រាវជ្រាវរបស់ខ្ញុំ។ ព័ត៌មានទាំងអស់នេះមានសារសំខាន់ណាស់សម្រាប់ចូលរួមចំណែកក្នុងការអភិវឌ្ឍការអប់រំបច្ចេកទេស និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅកម្ពុជាពេលអនាគត។

ខ្ញុំបាទ សូមធានាអះអាងថា នឹងរក្សាការសម្ងាត់ចំពោះរាល់ព័ត៌មានដែលបានផ្តល់ឱ្យ ហើយព័ត៌មានទាំងអស់នេះ ត្រូវបានយកទៅប្រើប្រាស់ ក្នុងគោលបំណងនៃការស្រាវជ្រាវតែប៉ុណ្ណោះ។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោក-លោកស្រី ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបំពេញកម្រងសំណួរនេះ និងសូមគោរពជូនពរ លោក លោកស្រី ព្រមទាំងក្រុមគ្រួសារប្រកបដោយសុខភាពល្អបរិបូរណ៍ សេចក្តីសុខ សុភមង្គល រកទទួលទានមានបានកើតកាលវាគុម្ព ត្រជាក់ត្រជុំ សុខដុមរមនា និងសម្រេចបានជោគជ័យគ្រប់ភារកិច្ចជានិច្ចនិរន្តរ៍។

សូមបំពេញព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក និងជ្រើសរើសចម្លើយតែមួយគត់ ដែលលោក អ្នក យល់ថាត្រឹមត្រូវដោយគូសសញ្ញា✓ក្នុងប្រអប់ ❑ និងបំពេញបន្ថែមក្នុងសញ្ញា.........ខាងក្រោម៖

**I. ព័ត៌មានផ្ទាល់ខ្លួនរបស់លោកគ្រូ អ្នកគ្រូ**

១. ភេទរបស់លោក អ្នក?

A - ❑ ប្រុស

B - ❑ ស្រី

២. តើលោក អ្នកមានអាយុប៉ុន្មានឆ្នាំ?

A - ❑ លើសពី៥០ឆ្នាំឡើងទៅ

B - ❑ ចន្លោះពី៣៩ឆ្នាំ ដល់៤៩ឆ្នាំ

C - ❑ ចន្លោះពី៣០ ទៅ ៣៩

D - ❑ ចន្លោះពី២០ ទៅ២៩

E - ❑ តិចជាង២០ឆ្នាំ

៣. ស្ថានភាពគ្រួសារ

A - ❑ នៅលីវ

B - ❑ រៀបការរួច

C - ❑ ពោះម៉ាយ ឬមេម៉ាយ

៤. ចំនួនសមាជិកក្នុងគ្រួសារ?

A - ❑ ច្រើនជាង៨នាក់

B - ❑ ចន្លោះពី៦ទៅ៨នាក់

C - ❑ ចន្លោះពី៤ទៅ៦នាក់

D - ❑ ចន្លោះពី២ទៅ៤នាក់

E - ❑ តិចជាង២នាក់

៥. ចូរបញ្ជាក់ពីកម្រិតសញ្ញាបត្ររបស់លោក អ្នក?

A - ❑ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

B - ❑ បរិញ្ញាបត្ររង

C - ❑ បរិញ្ញាបត្រ

D - ❑ បរិញ្ញាបត្រជាន់ខ្ពស់

E - ❑ បណ្ឌិត

៦. តើប្រាក់ចំណូលរបស់លោក អ្នកមានចំនួនប៉ុន្មានដុល្លារក្នុងមួយខែ?

A - ❑ ក្រោម៣០០ដុល្លារ

B - ❑ ពី៣០០ ទៅ៤០០ដុល្លារ

C - ❑ ពី៤០០ ទៅ៥០០ដុល្លារ

D - ❑ ពី៥០០ ទៅ៦០០ដុល្លារ

E - ❑ លើសពី៦០០ដុល្លារ

II. **ព័ត៌មានអំពីការងារ**

៧. ក្នុងឆ្នាំសិក្សា ២០១៧-២០១៨ តើលោក អ្នក បង្រៀនសិស្ស ថ្នាក់ ឆ្នាំទីប៉ុន្មានខ្លះ?

A - ❑ ឆ្នាំទី១

B - ❑ ឆ្នាំទី២

C - ❑ ឆ្នាំទី៣

D - ❑ ចំណោះទូទៅ ថ្នាក់ទី១០

E - ❑ ចំណោះទូទៅ ថ្នាក់ទី១១

F - ❑ ចំណោះទូទៅ ថ្នាក់ទី១២

៨. តើលោក-លោកស្រី បានឆ្លងកាត់វគ្គបណ្តុះបណ្តាលគរុកោសល្យ គ្រូបង្រៀនកម្រិតណា?

A - ❑ គ្រូបង្រៀនបឋមសិក្សា

B - ❑ គ្រូបង្រៀនកម្រិតមូលដ្ឋាន

C - ❑ គ្រូបង្រៀនកម្រិតឧត្តម

D - ❑ គ្រូបង្រៀនកម្រិតឧត្តមផ្នែកជំនាញបច្ចេកទេស

E - ❑ ផ្សេងៗ

៩. តើលោក-លោកស្រីនៅវិ.ច.ប.ទ ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី បានប៉ុន្មានឆ្នាំហើយ?

A - ❑ តិចជាង៣ឆ្នាំ

B - ❑ ចាប់ពី៣ឆ្នាំ ដល់៥ឆ្នាំ

C - ❑ ចាប់ពី៥ ដល់១០ឆ្នាំ

D - ❑ ចាប់ពី១០ឆ្នាំឡើងទៅ

១០. តើលោក-លោកស្រី ធ្លាប់បានទៅទស្សនកិច្ចសិក្សានៅប្រទេសក្រៅ ឬទេ?

A - ❑ ធ្លាប់

B - ❑ មិនធ្លាប់

១១. តើលោក-លោកស្រី ធ្លាប់បានចូលរួមដឹកនាំសិស្សចុះកម្មសិក្សានៅក្នុងប្រទេស ឬក្រៅប្រទេស ឬទេ?

A - ❑ ធ្លាប់

B - ❑ មិនធ្លាប់

III. **ព័ត៌មានអំពីការគ្រប់គ្រងសិស្ស**

១២. តើនៅដើមឆ្នាំសិក្សា សិស្សរបស់លោក អ្នក មានកម្រិតខ្សោយកម្រិតណា?

A - ❑ ក្រោម២៥%

B - ❑ ចាប់ពី២៥% ដល់៥០%

C - ❑ ចាប់ពី៥០% ដល់៧៥%

D - ❑ ចាប់ពី៧៥% ដល់១០០%

១៣. នៅចុងឆ្នាំសិក្សា តើសិស្សរបស់លោកអ្នកមានសមត្ថភាពឡើងថ្នាក់កម្រិតណា?

A - ❑ ក្រោម២៥%

B - ❑ ចាប់ពី២៥% ដល់៥០%

C - ❑ ចាប់ពី៥០% ដល់៧៥%

D - ❑ ចាប់ពី៧៥% ដល់១០០%

១៤. តាមយោបល់របស់លោក អ្នក តើក្នុងមួយថ្ងៃមានសិស្សអវត្តមានប៉ុន្មានភាគរយ?

A - ❑ តិចជាង៥%

B - ❑ ចាប់ពី៥% ដល់១០%

C - ❑ ចាប់ពី១០% ដល់១៥%

D - ❑ លើសពី១៥%

១៥. តើក្នុង១ឆ្នាំសិក្សា មានសិស្សបោះបង់ការសិក្សាប៉ុន្មានភាគរយ?

A - ❑ តិចជាង៥%

B - ❑ ចាប់ពី៥% ដល់១០%

C - ❑ ចាប់ពី១០% ដល់១៥%

D - ❑ លើសពី១៥%

១៦. តើលោក អ្នកគិតថាសិស្សចង់រៀននៅវិ.ច.ប.ទ ព្រះបាទសម្ដេច ព្រះបរមនាថ នរោត្តមសីហមុនី កម្រិតណាដែរ?

A - ❑ តិចជាង៥%

B - ❑ ចាប់ពី៥% ដល់១០%

C - ❑ ចាប់ពី១០% ដល់១៥%

D - ❑ ចាប់ពី១៥% ដល់៥០%

E - ❑ លើសពី៥០%

១៧. តើលោក អ្នកធ្លាប់បានចូលរួមប្រជុំក្រុមប្រឹក្សាថ្នាក់ដែរ ឬទេ?

A - ❑ មិនបានចូលរួម

B - ❑ បានចូលរួមខ្លះ មិនបានចូលរួមខ្លះ

C - ❑ បានចូលរួមទៀងទាត់

១៨. តើលោក អ្នកធ្លាប់បានចូលរួមប្រជុំតម្រង់ទិសសិស្សដែរ ឬទេ?

A - ❑ មិនបានចូលរួម

B - ❑ បានចូលរួមខ្លះ មិនបានចូលរួមខ្លះ

C - ❑ បានចូលរួមទៀងទាត់

IV. **ព័ត៌មានពីការងារបច្ចេកទេស**

១៩. តើលោក អ្នកយល់ថាចំនួនម៉ោងក្នុងកម្មវិធីសិក្សាប្រចាំឆ្នាំយ៉ាងដូចម្ដេច?

A - ❑ តិចពេក

B - ❑ មិនតិច មិនច្រើន

C - ❑ ច្រើនពេក

២០. តើលោក អ្នកបង្រៀនទាន់កម្មវិធីសិក្សា ឬទេ?

A - ❑ បង្រៀនមិនទាន់ ៖មូលហេតុ......................................................................................

B - ❑ បង្រៀនទាន់ខ្លះ មិនទាន់ខ្លះ ៖ ...............................................................................................

C - ❑ បង្រៀនទាន់កម្មវិធីល្អ

២១. តើលោក អ្នកបានចូលរួមប្រជុំបច្ចេកទេសមុខវិជ្ជា ឬមុខជំនាញតាមផ្នែកដែរ ឬទេ?

A - ❑ មិនបានចូលរួម

B - ❑ បានចូលរួមខ្លះ មិនបានចូលរួមខ្លះ

C - ❑ បានចូលរួមទៀងទាត់

២២. តើលោក អ្នក យល់ថាការប្រជុំបច្ចេកទេសមុខវិជ្ជា ឬមុខជំនាញមានសារសំខាន់ដែរ ឬទេ?

A - ❑ មិនសំខាន់អ្វីទាល់តែសោះ

B - ❑ មិនសំខាន់

C - ❑ សំខាន់ខ្លះ មិនសំខាន់ខ្លះ

D - ❑ សំខាន់

E - ❑ សំខាន់ខ្លាំងណាស់

ហេតុអ្វី.......................................................................................................................................

.........................................................................................................................................។

២៣. តើលោក អ្នកធ្លាប់ត្រូវបានទទួលការចុះអង្កេតមើលការបង្រៀនពីគណៈគ្រប់គ្រង ឬទេ?

A - ❑ មិនធ្លាប់

B - ❑ ធ្លាប់

២៤. តើលោក អ្នកទទួលការអង្កេតថ្នាក់ប៉ុន្មានដងក្នុងមួយឆ្នាំសិក្សា?

A - ❑ តិចជាង២ដង

B - ❑ ចាប់ពី២ ទៅ៥ដង

C - ❑ លើសពី៥ដង

២៥. តើលោក អ្នក ធ្លាប់ត្រូវបាន គ្រូដទៃមើលការបង្រៀនដែរ ឬទេ?

A - ❑ មិនធ្លាប់

B - ❑ ធ្លាប់

២៦. តើលោក អ្នក ធ្លាប់បានចូលមើលការបង្រៀនរបស់គ្រូដទៃដែរ ឬទេ?

A - ❑ មិនធ្លាប់

B - ❑ ធ្លាប់

២៧. តើលោក អ្នក យល់ថាការបង្រៀនថ្នាក់និទស្សន៍សម្រាប់គ្រូបង្រៀនសំខាន់ដែរ ឬទេ?

A - ❑ មិនសំខាន់អ្វីទាល់តែសោះ

B - ❑ មិនសំខាន់

C - ❑ សំខាន់ខ្លះ មិនសំខាន់ខ្លះ

D - ❑ សំខាន់

E - ❑ សំខាន់ខ្លាំងណាស់

ហេតុអ្វី?.......................................................................................................................................

២៨. តើលោក អ្នក មានបានរៀបចំកិច្ចតែងការបង្រៀន តាមថ្នាក់ស្របសម្រាប់ការបង្រៀន ឬទេ?

A - ❑ មិនបានរៀបចំ

B - ❑ បានរៀបចំខ្លះ មិនបានរៀបចំខ្លះ

C - ❑ បានរៀបចំត្រឹមត្រូវ និងទៀងទាត់

២៩. តើលោក អ្នកគិតថា ១សប្តាហ៍ ត្រូវចំណាយពេលប៉ុន្មានម៉ោងសម្រាប់ការធ្វើកិច្ចតែងការបង្រៀន?

A - ❑ តិចជាង៥ម៉ោង

B - ❑ ចាប់ពី៥ម៉ោង ដល់៧ម៉ោង

C - ❑ ចាប់ពី៧ម៉ោង ដល់៩ម៉ោង

D - ❑ ចាប់ពី៩ម៉ោង ដល់១១ម៉ោង

E - ❑ ច្រើនចាង១១ម៉ោង

៣០. តើលោក អ្នក មានបានរៀបចំសៀវភៅរដ្ឋបាលគ្រូ តាមថ្នាក់ស្របសម្រាប់ការបង្រៀន ឬទេ?

A - ❑ មិនបានរៀបចំ

B - ❑ បានរៀបចំខ្លះ មិនបានរៀបចំខ្លះ

C - ❑ បានរៀបចំត្រឹមត្រូវ និងទៀងទាត់

៣១. តើលោក អ្នក ធ្វើការវាយតម្លៃសមត្ថភាពសិស្សបានកម្រិតណា?

A - ❑ មិនបានរៀបចំ

B - ❑ បានរៀបចំខ្លះ មិនបានរៀបចំខ្លះ

C - ❑ បានរៀបចំត្រឹមត្រូវ និងទៀងទាត់

៣២. តើលោក អ្នក បានជួយសិស្សដែលរៀនយឺតដែរ ឬទេ?

A - ❑ មិនបានជួយ

B - ❑ បានជួយខ្លះ មិនបានជួយខ្លះ

C - ❑ បានជួយជាប្រចាំ

ជួយដោយរបៀបណា?..........................................................................................

៣៣. តើលោក អ្នកបានដឹកនាំសិស្សបង្កើតគម្រោងសិក្សា (ផ្នែកអប់រំបច្ចេកទេស) ដែរ ឬទេ?

A - ❑ មិនបានដឹកនាំ

B - ❑ បានដឹកនាំខ្លះ មិនបានដឹកនាំខ្លះ

C - ❑ បានដឹកនាំជាប្រចា

## V. ព័ត៌មានពីសមត្ថភាព គ្រប់គ្រង និងដឹកនាំការអភិវឌ្ឍវិទ្យាល័យ

ការវាយតម្លៃតាមរយៈការផ្តល់ពិន្ទុ មានគោលបំណងកម្រិតពីលទ្ធផលនៃការគ្រប់គ្រង ដឹកនាំ និងអនុវត្តការផ្តល់សេវាអប់រំបច្ចេកទេស ដែលអាចអោយសាលារៀនធ្វើស្វ័យវាយតម្លៃ និងអនុញ្ញាតឲ្យភ្នាក់ងារវាយតម្លៃពីខាងក្រៅចូលរួមកែលម្អការអនុវត្តរបស់សាលារៀន។ អត្ថន័យនៃតម្លៃដែលបានបែងចែកជា៥កម្រិតដូចខាងក្រោម៖

- កម្រិតទី១ អនុវត្តបានពី ០-២០% នៃសូចនាករដែលបានកំណត់
- កម្រិតទី២ អនុវត្តបានពី ២១-៤០% នៃសូចនាករដែលបានកំណត់
- កម្រិតទី៣ អនុវត្តបានពី ៤១-៦០% នៃសូចនាករដែលបានកំណត់
- កម្រិតទី៤ អនុវត្តបានពី ៦១-៨០% នៃសូចនាករដែលបានកំណត់
- កម្រិតទី៥ អនុវត្តបានពី ៨១-១០០% នៃសូចនាករដែលបានកំណត់

គំនិតជាយុទ្ធសាស្រ្ត និងនវានុវត្តន៍៖ សមត្ថភាពនៃការរៀបចំទិសដៅជាយុទ្ធសាស្រ្តសម្រាប់សាលារៀន ការសម្រេចចិត្តនាំឱ្យមានការផ្លាស់ប្តូរ និងនវានុវត្តន៍) របស់គណៈគ្រប់គ្រងរបស់លោក អ្នក?

ភាពជាអ្នកដឹកនាំ គ្រប់គ្រង៖ សមត្ថភាពនៃការគ្រប់គ្រងធនធាន និងប្រព័ន្ធសាលារៀន ការគ្រប់គ្រងការបំពេញការងាររបស់បុគ្គលិក ការគ្រប់គ្រងការបំពេញកម្មវិធីរបស់បុគ្គលិក ការគ្រប់គ្រងកម្មវិធី និងគម្រោងនានារបស់សាលារៀនប្រកបដោយនិរន្តរភាព។

ភាពជាអ្នកដឹកនាំការបង្រៀន និងរៀន៖ សមត្ថភាពនៃការដឹកនាំក្នុងការអនុវត្ត និងកែលម្អនូវកម្មវិធីសិក្សា បង្កើតកម្មវិធីសិក្សាតាមបែបសិស្សមជ្ឈមណ្ឌល អធិការ និងវាយតម្លៃលើការបំពេញភារកិច្ចរបស់គ្រូបង្រៀន ក៏ដូចជាផ្តល់ជាលទ្ធផលអំពីផែនការសិក្សា។

ឧត្តមភាពផ្ទាល់ខ្លួន៖ សមត្ថភាពនៃការគ្រប់គ្រងលើសមត្ថភាពបុគ្គលទៅលើសកម្មភាពឱ្យអស់ពីសមត្ថភាព និងលទ្ធភាពដែលអាចធ្វើទៅបាន និងបន្តអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈរបស់គណៈគ្រប់គ្រងលោក លោកស្រី។

ការចូលរួមពីភាគីពាក់ព័ន្ធ៖ សមត្ថភាពក្នុងការលើកកម្ពស់ ការចែករំលែក ការទទួលខុសត្រូវសម្រាប់ការអភិវឌ្ឍសាលារៀន គ្រប់គ្រងភាពជាដៃគូ និងបណ្តាញការអប់រំ និងរក្សានិរន្តរភាពនៃទំនាក់ទំនងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ របស់គណៈគ្រប់គ្រងសាលារបស់លោក លោកស្រី។

## 1. គំនិតប្រកបដោយយុទ្ធសាស្ត្រ និងចក្ខុវិស័យ

៣៤. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រី បានដឹកនាំរៀបចំ ធ្វើតារាងទិសដៅយុទ្ធសាស្ត្រ របស់សាលារៀនបានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៣៥. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រី ធ្វើការជាមួយសាលារៀន និងសហគមន៍ ពាក់ព័ន្ធក្នុងការអភិវឌ្ឍផែនការយុទ្ធសាស្ត្រសាលារៀនបានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៣៦. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រី ដឹកនាំក្នុងការអភិវឌ្ឍផែនការយុទ្ធសាស្ត្រសាលារៀនបានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៣៧. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រី បានបង្ហាញទស្សនវិស័យសាលារៀន និងធ្វើជាគម្រូនៃតម្លៃការងារ និងការអនុវត្តប្រចាំថ្ងៃបានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៣៨. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រី បានប្រើប្រាស់ភស្តុតាងច្រើនផ្សេងៗគ្នា ដើម្បីគាំទ្រ ត្រួតពិនិត្យ វាយតម្លៃ និងកែលម្អផែនការយុទ្ធសាស្ត្រ បានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៣៩. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រី បានអនុវត្តការពិនិត្យឡើងវិញជាប្រចាំនៃការអនុវត្តន៍គម្រោង ឬកម្មវិធី និងប្រើប្រាស់លទ្ធផលក្នុងការណែនាំពីបញ្ហា និងការព្រួយបារម្ភពីការអនុវត្តន៍ផែនការបានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៤០. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រី ដឹកនាំដំណើរការផ្លាស់ប្តូរសំដៅទៅលើការអនុវត្ត និងអភិវឌ្ឍគោលវិធី ប្រព័ន្ធរចនាសម្ព័ន្ធថ្មីបានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៤១. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រី ធ្វើឱ្យមាននិរន្តរភាពគំនិតច្នៃប្រឌិត និងការបង្កើតថ្មី នៅក្នុងកម្មវិធីសាលា ដើម្បីសម្រេចនូវលទ្ធផលសិក្សាខ្ពស់ជាងមុនបានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៤២. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រី ធ្វើការសម្រេចចិត្តដោយជូនដំណឹងបានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៤៣. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រី បានដឹកនាំផ្លាស់ប្តូរ និងធ្វើការបង្កើតថ្មីបានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

## 2. ភាពជាអ្នកដឹកនាំ និងគ្រប់គ្រង

៤៤. តើគណៈគ្រប់គ្រងសាលា របស់លោក លោកស្រី បានគ្រប់គ្រងធនធាន និងប្រព័ន្ធនៃសាលារៀន បានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៤៥. តើគណៈគ្រប់គ្រងសាលាបានគ្រប់គ្រង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុ បានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៤៦. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រីបានគ្រប់គ្រងលើបរិស្ថានសិក្សា បានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៤៧.តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រីគ្រប់គ្រងលើនីតិវិធី និងប្រព័ន្ធផ្សេងៗ បានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៤៨. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រីគ្រប់គ្រងការបំពេញការងាររបស់បុគ្គលិក បានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៤៩. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រីគ្រប់គ្រងលើតម្រូវការបុគ្គលិកសាលារៀនបានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៥០. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រីផ្តល់ការគាំទ្រដល់ការអភិវឌ្ឍវិជ្ជាជីវៈរបស់បុគ្គលិក បានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៥១. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រីទទួលស្គាល់ការបំពេញការងាររបស់បុគ្គលិក និងលើកទឹកចិត្តបានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៥២. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រីបង្ហាញពីជំនាញគ្រប់គ្រងកម្មវិធី និងគម្រោងអភិវឌ្ឍសាលារៀនបានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៥៣. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រីលើកកម្ពស់កម្មវិធី និងគម្រោងដែលផ្តោតលើសាលារៀនសម្រាប់ការគាំទ្រការអភិវឌ្ឍដោយនិរន្តរភាពបានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៥៤. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រីបង្ហាញពីជំនាញគ្រប់គ្រងកម្មវិធី និងគម្រោងអភិវឌ្ឍសាលារៀនបានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៥៥. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រី បានលើកកម្ពស់កម្មវិធី និងគម្រោងដែលផ្តោតលើសាលារៀនសម្រាប់គាំទ្រការអភិវឌ្ឍប្រកបដោយនិរន្តរភាពបានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

### 3. ភាពជាអ្នកដឹកនាំការបង្រៀន និងរៀន

៥៦. តើគណៈគ្រប់គ្រងសាលាគ្រប់គ្រងការអនុវត្តកម្មវិធីសិក្សាបានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៥៧. តើគណៈគ្រប់គ្រងសាលាលើកកម្ពស់សកម្មភាពសិក្សាសិស្សមជ្ឈមណ្ឌលបានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៥៨. តើគណៈគ្រប់គ្រងសាលាបានលើកកម្ពស់បរិស្ថានសាលារៀន ដែលអាចរួមបញ្ចូលសុវត្ថិភាព និងសុខភាពបានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៥៩. តើគណៈគ្រប់គ្រងសាលាលើកកម្ពស់វប្បធម៌សន្តិភាព និងការគោរពលក្ខណៈផ្សេងៗគ្នាបានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៦០. តើគណៈគ្រប់គ្រងសាលាបានដាក់ចេញនូវគំរូសមស្របមួយ លើការត្រួតពិនិត្យ និងវាយតម្លៃបានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៦១. តើគណៈគ្រប់គ្រងសាលាបានបណ្តុះការអប់រំប្រធានក្រុមបច្ចេកទេស បានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៦២. តើគណៈគ្រប់គ្រងសាលាលើកកម្ពស់ស្មារតីធ្វើការងារជាក្រុមក្នុងការដឹកនាំជាសិក្សាធិការ បានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៦៣. តើគណៈគ្រប់គ្រងសាលាគ្រប់គ្រងលើការវាយតម្លៃដើម្បីកែលម្អការរៀន និងបង្រៀនបានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៦៤. តើគណៈគ្រប់គ្រងសាលាលើកកម្ពស់ការប្រើប្រាស់សម្ភារឧបទ្ទេស ឧបករណ៍បិសោធ ក្នុងពេលបង្រៀន និងរៀន បានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៦៥. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រី គ្រប់គ្រងលើការងារវាយតម្លៃ ដើម្បីកែលម្អការបបង្រៀន និងរៀន បានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

**4. ឧត្តមភាពបុគ្គលរបស់គណៈគ្រប់គ្រង**

៦៦. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រី ដឹកនាំ និងគ្រប់គ្រងដោយធ្វើជាគំរូល្អក្នុងសារៀនបានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៦៧. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រី បង្ហាញពីគណនេយ្យភាព និងតម្លាភាព បានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៦៨. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រី អនុវត្តរបៀបរស់នៅប្រកបដោយសុខភាពល្អ និងតុល្យភាព បានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៦៩. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រី មានមោទនភាពលើវិជ្ជាជីវៈបានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៧០. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រី បង្ហាញលទ្ធផលនៃការគ្រប់គ្រង បានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៧១. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រី គ្រប់គ្រងលើការងារជាអាទិភាព បានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៧២. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រី ពន្យល់ពីការសម្រេចចិត្តក្នុងការដោះស្រាយបញ្ហាប្រឈមនានា បានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៧៣. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រី មានទំនួលខុសត្រូវលើការសិក្សាពេញមួយជីវិត បានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៧៤. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រី គាំទ្រនូវតម្លៃ និងទស្សនវិស័យអាស៊ាន និងដៃគូពាក់ព័ន្ធ បានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៧៥. តើគណៈគ្រប់គ្រងសាលាគាំទ្រគោលនយោបាយអប់រំជាតិគឺការកសាងធនធានពេញ បានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

### 5. ការចូលរួមពីភាគីពាក់ព័ន្ធ

៧៦. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រី បង្កើតទំនុកចិត្ត និងដឹកនាំក្រុម សហគមសម្រាប់កែលម្អសាលារៀន និងដៃគូពាក់ពាន់ បានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៧៧.តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រី ពង្រឹងការចូលរួមពីសហគមក្នុងការលើកកម្ពស់ដំណើការរបស់សាលារៀន បានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៧៨.តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រី ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពខ្ពស់ ជាមួយភាគីពាក់ព័ន្ធផ្សេងៗបានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៧៩.តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រី សម្របសម្រួលភាពជាដៃគូ និងសកម្មភាពសាលារៀន និងសហគមន៍បានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៨០. តើគណៈគ្រប់គ្រងសាលារបស់លោក លោកស្រី ជម្រុញការបង្កើតមតិ ដោយការស្របគ្នា ឬមតិរួម បានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៨១. តើគណៈគ្រប់គ្រងសាលាគ្រប់គ្រងលើការខ្វែងគំនិតគ្នា និងអនុវត្តជំនាញចរចារ និងដោះស្រាយបញ្ហា បានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

៨២. តើគណៈគ្រប់គ្រងសាលាទំនាក់ទំនងពីសកម្មភាពរបស់សាលារៀន ដល់ភាគីពាក់ព័ន្ធ បានកម្រិតណា?

□ ១ □ ២ □ ៣ □ ៤ □ ៥

## V. ការគ្រប់គ្រងហិរញ្ញវត្ថុ

៨៣. តើប្រភពថវិកាដែលសម្រាប់គាំទ្រដំណើរការសាលារៀនរបស់លោក លោកស្រីបានមកពីណា?

A - ❑ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

B - ❑ ដៃគូជំនួយៗ ជាតិ និងអន្តរជាតិ

C - ❑ កញ្ចប់ថវិកាជាតិគាំទ្រវិស័យអប់រំ

D - ❑ ផ្សេងៗ

៨៤. តើក្នុងសិស្សផ្នែកបច្ចេកទេសម្នាក់ទទួលបានថវិកាគាំទ្រប៉ុន្មានរៀលក្នុងមួយឆ្នាំសិក្សា?

A - ❑ តិចជាង២០០០០០រៀល

B - ❑ ៣០០០០០រៀល

C - ❑ ៥០០០០០រៀល

D - ❑ ៦០០០០០រៀល

E - ❑ ច្រើនជាង៦០០០០០រៀល

៨៥. តើគណៈគ្រប់គ្រងរបស់លោក អ្នកបានរៀបចំបែងចែកគណៈកម្មការគ្រប់គ្រងថវិកាដែរ ឬទេ?

A - ❑ មិនបានរៀបចំ

B - ❑ បានរៀបចំខ្លះ មិនបានរៀបចំខ្លះ

C - ❑ បានរៀបចំ

D - ❑ បានរៀបចំយ៉ាងត្រឹមត្រូវ

៨៦. តើគណៈគ្រប់គ្រងរបស់លោក អ្នកបានរៀបចំ និងដឹកនាំប្រជុំផ្សព្វផ្សាយ ពីថវិកាសាលារៀនដែរ ឬទេ?

A - ❑ មិនបានរៀបចំ

B - ❑ បានរៀបចំខ្លះ មិនបានរៀបចំខ្លះ

C - ❑ បានរៀបចំ

D - ❑ បានរៀបចំយ៉ាងត្រឹមត្រូវ

៨៧. តើគណៈគ្រប់គ្រងរបស់លោក អ្នក បានរៀបចំផែនការយុទ្ធសាស្ត្រថវិកាដែរ ឬទេ?

A - ❑ មិនបានរៀបចំ

B - ❑ បានរៀបចំខ្លះ មិនបានរៀបចំខ្លះ

C - ❑ បានរៀបចំ

D - ❑ បានរៀបចំយ៉ាងត្រឹមត្រូវ

៨៨. តើគណៈគ្រប់គ្រងរបស់លោក អ្នក មានបារៀបចំកិច្ចបញ្ជីការគណនេយ្យសាលារៀនដែរ ឬទេ?

A - ❑ មិនបានរៀបចំ

B - ❑ បានរៀបចំខ្លះ មិនបានរៀបចំខ្លះ

C - ❑ បានរៀបចំ

D - ❑ បានរៀបចំយ៉ាងត្រឹមត្រូវ

៨៩. តើគណៈគ្រប់គ្រងរបស់លោក អ្នកបានរៀបចំតារាងតម្លាភាពថវិកាសាលារៀនដែរ ឬទេ?

A - ❑ មិនបានរៀបចំ

B - ❑ បានរៀបចំខ្លះ មិនបានរៀបចំខ្លះ

C - ❑ បានរៀបចំ

D - ❑ បានរៀបចំយ៉ាងត្រឹមត្រូវ

៩០. (បើបានរៀបចំ) តើគណៈគ្រប់គ្រងលោក អ្នក បានបិទផ្សាយជាសាធារណៈក្នុងសាលារៀន ឬទេ?

A - ❑ មិនបានបិទផ្សាយ

B - ❑ បានបិទផ្សាយខ្លះ មិនបានបិទផ្សាយខ្លះ

C - ❑ បានរៀបចំបិទផ្សាយ

D - ❑ បានរៀបចំបិទផ្សាយយ៉ាងត្រឹមត្រូវ

៩១. តើគណៈគ្រប់គ្រងរបស់លោក អ្នកបានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងថវិកាសាលារៀនដែរ ឬទេ?

A - ❑ មិនបានរៀបចំ

B - ❑ បានរៀបចំខ្លះ មិនបានរៀបចំខ្លះ

C - ❑ បានរៀបចំ

D - ❑ បានរៀបចំយ៉ាងត្រឹមត្រូវ

៩២. តើរាល់ការចំណាយថវិកា គណៈគ្រប់គ្រងរបស់លោក អ្នកបានធ្វើរបាយការណ៍ តារាងសកម្មភាព និងវិក័យបត្រចំណាយត្រឹមត្រូវ ឬទេ?

A - ❑ មិនបានរៀបចំ

B - ❑ បានរៀបចំខ្លះ មិនបានរៀបចំខ្លះ

C - ❑ បានរៀបចំ

D - ❑ បានរៀបចំយ៉ាងត្រឹមត្រូវ

៩៣. តើគណៈគ្រប់គ្រងរបស់លោក អ្នក បានរៀបចំបញ្ជីតាមដានការប្រើប្រាស់ថវិកាដែរ ឬទេ?

A - ❑ មិនបានរៀបចំ

B - ❑ បានរៀបចំខ្លះ មិនបានរៀបចំខ្លះ

C - ❑ បានរៀបចំ

D - ❑ បានរៀបចំយ៉ាងត្រឹមត្រូវ

### VI. **ទស្សនៈផ្សេងៗ**

៩៤.តើលោក-លោកស្រីយល់ឃើញយ៉ាងណាបន្ថែមទៀតពីទិដ្ឋភាពរួមលើការគ្រប់គ្រង និងដឹកនាំសាលារៀនរបស់គណៈគ្រប់គ្រងសាលារៀន លោកអ្នក សម្រាប់ការចូលរួមក្នុងការធានាគុណភាពអប់រំនៅកម្ពុជា?

### V. **សំណូមពរផ្សេងៗ**

.....................................................................................................................................................

**សូមអរគុណ**!

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**កម្រងសំណួរសិក្សាស្រាវជ្រាវសម្រាប់ការសរសេរនិក្ខេបបទ**
**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ**

# កម្រងសំណួរសម្រាប់នាយកសាលារៀន

ខ្ញុំបាទ ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ ជំនាន់ទី៥ របស់វិទ្យាស្ថានជាតិអប់រំ ( NIE ) ក្នុងឆ្នាំសិក្សា (២០១៦.២០១៨) ដែលកំពុងសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី ″ **ការគ្រប់គ្រង និងដឹកនាំ ការអប់រំផ្នែកបច្ចេកទេសកម្រិតមធ្យមសិក្សាទុតិយភូមិនៅកម្ពុជា ″ករណីសិក្សា វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី ខេត្តកំពង់ឆ្នាំង** ។ ការស្រាវជ្រាវនេះ មានគោលបំណងរកឱ្យឃើញពីរបៀបនៃការគ្រប់គ្រង និងដឹកនាំរបស់ គណៈគ្រប់គ្រងវិទ្យាល័យ ចំណេះទូទៅ និងបច្ចេកទេស សម្រាប់ធ្វើការអភិវឌ្ឍការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈនៅកម្ពុជា។ ដូច្នេះសូមលោក លោកស្រី មេត្តាផ្តល់ព័ត៌មានពិត ដល់ការសិក្សាស្រាវជ្រាវរបស់ខ្ញុំ។ ព័ត៌មានទាំងអស់នេះមានសារសំខាន់ណាស់ សម្រាប់ចូលរួមចំណែកក្នុងការអភិវឌ្ឍការអប់រំបច្ចេកទេស និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅកម្ពុជាពេលអនាគត។

ខ្ញុំបាទ សូមធានាអះអាងថា នឹងរក្សាការសម្ងាត់ចំពោះរាល់ព័ត៌មានដែលបានផ្តល់ឱ្យ ហើយព័ត៌មានទាំងអស់នេះ ត្រូវបានយកទៅប្រើប្រាស់ ក្នុងគោលបំណងនៃការស្រាវជ្រាវតែប៉ុណ្ណោះ។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោក-លោកស្រី ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបំពេញកម្រងសំណួរនេះ និងសូមគោរពជូនពរ លោក លោកស្រី ព្រមទាំងក្រុមគ្រួសារប្រកបដោយសុខភាពល្អបរិបូរណ៍ សេចក្តីសុខ សុភមង្គល រកទទួលទានមានបានកើតកាលវាគុម្ភ ត្រជាក់ត្រជុំ សុខដុមរមនា និងសម្រេចបានជោគជ័យគ្រប់ភារកិច្ចជានិច្ចនិរន្តរ៍។

សូមបំពេញព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ដោយគូសសញ្ញា✓ក្នុងប្រអប់ និងបំពេញបន្ថែមក្នុងសញ្ញា.....ខាងក្រោម។
កាលបរិច្ឆេទ៖..................................................
ឈ្មោះសាលា៖..........................................................................................................
ភូមិ....................... ឃុំ....................... ស្រុក......................... ខេត្ត...............................។
ចំនួនគ្រូសរុប.................................................ស្រី..........នាក់
ចំនួនគ្រូផ្នែកបច្ចេកទេស ..........................ស្រី...........នាក់
ចំនួនមុខវិជ្ជាបច្ចេកទេស .....................................................................................................
ចំនួនបុគ្គលិកការិយាល័យ ..........................ស្រី..........នាក់
ចំនួនអគារសិក្សា ................................................
ចំនួនសិស្សសរុប ...........................ស្រី..........នាក់
ចំនួនសិស្សផ្នែកចំណេះទូទៅ ..........................ស្រី..........នាក់
ចំនួនថ្នាក់ផ្នែកចំណេះទូទៅ ................................................

ចំនួនសិស្សផ្នែកបច្ចេកទេស ............................ស្រី..........នាក់

ចំនួនថ្នាក់ផ្នែកបច្ចេកទេស .................................................

## I. ព័ត៌មានផ្ទាល់ខ្លួន

១. ភេទរបស់លោក អ្នក?

A - ❑ ប្រុស

B - ❑ ស្រី

២. តើលោក អ្នកមានអាយុប៉ុន្មានឆ្នាំ?

A - ❑ លើសពី៥០ឆ្នាំឡើងទៅ

B - ❑ ចន្លោះពី៣៩ឆ្នាំ ដល់៤៩ឆ្នាំ

C - ❑ ចន្លោះពី៣០ ទៅ ៣៩

D - ❑ ចន្លោះពី២០ ទៅ២៩

E - ❑ តិចជាង២០ឆ្នាំ

៣. ស្ថានភាពគ្រួសារ

A - ❑ នៅលីវ

B - ❑ រៀបការរួច

C - ❑ ពោះម៉ាយ ឬមេម៉ាយ

៤. ចំនួនសមាជិកក្នុងគ្រួសារ?

A - ❑ ច្រើនជាង៨នាក់

B - ❑ ចន្លោះពី៦ទៅ៨នាក់

C - ❑ ចន្លោះពី៤ទៅ៦នាក់

D - ❑ ចន្លោះពី២ទៅ៤នាក់

E - ❑ តិចជាង២នាក់

៥. ចូរបញ្ជាក់ពីកម្រិតសញ្ញាបត្ររបស់លោក អ្នក?

A - ❑ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

B - ❑ បរិញ្ញាបត្ររង

C - ❑ បរិញ្ញាបត្រ

D - ❑ បរិញ្ញាបត្រជាន់ខ្ពស់

E - ❑ បណ្ឌិត

F - ❑ ផ្សេងៗ សូមបញ្ជាក់.................................................

៦. តើប្រាក់ចំណូលរបស់លោក អ្នកមានចំនួនប៉ុន្មានដុល្លារក្នុងមួយខែ?

A - ❑ ក្រោម៣០០ដុល្លារ

B - ❑ ពី៣០០ ទៅ៤០០ដុល្លារ

C - ❑ ពី៤០០ ទៅ៥០០ដុល្លារ

D - ❑ ពី៥០០ ទៅ៦០០ដុល្លារ

E - ❑ លើសពី៦០០ដុល្លារ

៧. តើលោក អ្នក កំពុងគ្រប់គ្រង ផ្នែកមួយណានៃសាលារៀន?

A - ❑ ក្តាប់រួម

B - ❑ គ្រប់គ្រងផ្នែកអប់រំបច្ចេកទេស

C - ❑ គ្រប់គ្រងផ្នែកអប់រំចំណេះទូទៅ

D - ❑ ផ្សេងៗ សូមបញ្ជាក់.................................................

៨. ជាមធ្យមតើមានសិស្សប៉ុន្មាននាក់ក្នុងមួយថ្នាក់ (ផ្នែកអប់រំបច្ចេកទេស)?

A - ❑ តិចជាង១៥នាក់

B - ❑ ពី១៥ ទៅ២០នាក់

C - ❑ ពី២០ ទៅ២៥នាក់

D - ❑ ពី២៥ ទៅ៣០នាក់

E - ❑ លើសពី៣០នាក់

៩. តើសិស្សនៅក្នុងវិទ្យាល័យរបស់លោកអ្នក មានអាយុចាប់ពីប៉ុន្មាន? គិតត្រឹមថ្នាក់ទី១០ ឬឆ្នាំទី១

A - ❑ ក្រោម១៦ឆ្នាំ

B - ❑ ១៦ឆ្នាំ ដល់១៨ឆ្នាំ

C - ❑ ពី១៨ឆ្នាំ ដល់២០ឆ្នាំ

D - ❑ ពី២០ឆ្នាំ ដល់២២ឆ្នាំ

E - ❑ លើសពី២២ឆ្នាំ

១០. តើលោក អ្នកធ្លាប់ទទួលការបណ្តុះបណ្តាលជាគ្រូបង្រៀនដែរ ឬទេ?

A - ❑ ធ្លាប់

B - ❑ មិនធ្លាប់

១១. បើធ្លាប់ តើលោក អ្នកធ្លាប់ទទួលការបណ្តុះបណ្តាលជាគ្រូបង្រៀនកម្រិតណា?

A - ❑ គ្រូបង្រៀនបឋមសិក្សា

B - ❑ គ្រូបង្រៀនកម្រិតមូលដ្ឋាន

C - ❑ គ្រូបង្រៀនកម្រិតឧត្តម

D - ❑ គ្រូបង្រៀនបច្ចេកទេសកម្រិតឧត្តម

E - ❑ ផ្សេងៗ សូមបញ្ជាក់...............................................................................................។

១២. តើលោក អ្នកគ្រប់គ្រងនៅវិចបទ ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនីនេះរយៈពេលប៉ុន្មានឆ្នាំហើយ?

A - ❑ តិចជាង៣ឆ្នាំ

B - ❑ ចន្លោះពី៣ឆ្នាំ ទៅ៥ឆ្នាំ

C - ❑ ចន្លោះពី៥ឆ្នាំ ទៅ១០ឆ្នាំ

D - ❑ ចន្លោះពី១០ឆ្នាំ ទៅ១៥ឆ្នាំ

F - ❑ លើសពី១៥ឆ្នាំ

១៣. តើលោក អ្នក ធ្លាប់បានទៅទស្សនកិច្ចសិក្សា នៅក្នុង ឬក្រៅប្រទេសដែរ ឬទេ?

A - ❑ ធ្លាប់ ប្រទេសណាខ្លះ.................................................................................................

B - ❑ មិនធ្លាប់

១៤. តើលោក អ្នកបានឆ្លងកាត់វគ្គបណ្តុះបណ្តាលសមត្ថភាពនាយកនៅNIE ដែរ ឬទេ?

A - ❑ បាន

B - ❑ មិនបាន

១៥. តើលោក អ្នកធ្លាប់ចូលរួមវគ្គបណ្តុះបណ្តាលសមត្ថភាពនាយកបន្ថែមដែរ ឬទេ?

A - ❑ ធ្លាប់ បើធ្លាប់ប៉ុន្មានដង..........................................................................

B - ❑ មិនធ្លាប់

## II. គ្រប់គ្រងកិច្ចការសិស្ស

១៦. តាមយោបល់លោក អ្នក ក្នុងមួយថ្ងៃមានសិស្សអវត្តមានប៉ុន្មានភាគរយ?

A - ❑ តិចជាង២%

B - ❑ ចន្លោះពី២% ទៅ៤%

C - ❑ ចន្លោះពី៤% ទៅ៦%

D - ❑ ចន្លោះពី៦% ទៅ៨%

E - ❑ លើសពី៨%ឡើងទៅ

១៧. តាមយោបល់អ្នក តើក្នុងមួយឆ្នាំសិក្សាសិស្សបោះបង់ការសិក្សាមានប៉ុន្មានភាគរយ?

A - ❑ តិចជាង២%

B - ❑ ចន្លោះពី២% ទៅ៥%

C - ❑ ចន្លោះពី៥% ទៅ៨%

D - ❑ ចន្លោះពី៨% ទៅ១០%

E - ❑ លើសពី១០%ឡើងទៅ

១៨. តើសិស្សរបស់លោក អ្នកបានចុះកម្មសិក្សាប៉ុន្មានភាគរយ?

A - ❑ តិចជាង២០%

B - ❑ ចន្លោះពី២០% ទៅ៤០%

C - ❑ ចន្លោះពី៤០% ទៅ៦០%

D - ❑ ចន្លោះពី៦០% ទៅ៨០%

E - ❑ លើសពី៨០%ឡើងទៅ

១៩. នៅចុងឆ្នាំសិក្សាសិស្សរបស់លោក-អ្នកមានសមត្ថភាពប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិភូមិប៉ុន្មានភាគរយ? (សម្រាប់ផ្នែកចំណេះទូទៅ)

A - ❑ តិចជាង២០%

B - ❑ ចន្លោះពី២០% ទៅ៤០%

C - ❑ ចន្លោះពី៤០% ទៅ៦០%

D - ❑ ចន្លោះពី៦០% ទៅ៨០%

E - ❑ លើសពី៨០%ឡើងទៅ

២០. នៅចុងឆ្នាំសិក្សាសិស្សរបស់លោក-អ្នកមានសមត្ថភាពប្រឡងជាប់សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ ប៉ុន្មានភាគរយ? (សម្រាប់ផ្នែកបច្ចេកទេស)

A - ❑ តិចជាង២០%

B - ❑ ចន្លោះពី២០% ទៅ៤០%

C - ❑ ចន្លោះពី៤០% ទៅ៦០%

D - ❑ ចន្លោះពី៦០% ទៅ៨០%

E - ❑ លើសពី៨០%ឡើងទៅ

២១. នៅចុងឆ្នាំសិក្សា តើសិស្សរបស់លោក អ្នក បានទទួលការងារធ្វើប៉ុន្មានភាគរយ?

A - ❑ តិចជាង២០%

B - ❑ ចន្លោះពី២០% ទៅ៤០%

C - ❑ ចន្លោះពី៤០% ទៅ៦០%

D - ❑ ចន្លោះពី៦០% ទៅ៨០%

E - ❑ លើសពី៨០%ឡើងទៅ

២២. នៅពេលសិស្សបញ្ចប់ការសិក្សានៅវិទ្យាល័យ សិស្សលោក អ្នក បានបន្តការសិក្សាបានប៉ុន្មានភាគរយ?

A - ❑ តិចជាង២០%

B - ❑ ចន្លោះពី២០% ទៅ៤០%

